សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ច្បាប់ និងគោលនយោបាយរបស់រដ្ឋាភិបាល ពាក់ព័ន្ធនឹងបញ្ហាប្រែប្រួលអាកាសធាតុ

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ក. អេង សុជាត្តា**
**ក. លី លីលីន**

សាស្ត្រាចារ្យណែនាំ
លោក **ឃឹម គិរី**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ៩ (និស្សិតអាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១២
ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **អេង សុជាត្តា** និង **លី លីលីន** ជានិស្សិតជំនាន់ទី៩ នៃមហាវិទ្យាល័យរដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកមានគុណរបស់យើងខ្ញុំដែលមានគុណបំណាច់ដ៏ធំធេង និងឧត្តុង្គឧត្តមមិនអាចកាត់ថ្លៃបាន ដែលលោកបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំ ឲ្យដំបូន្មានល្អសម្រាប់យើងខ្ញុំតាំងពីតូច រហូតដឹងក្តី។ ការយកចិត្តទុកដាក់របស់លោកធ្វើឲ្យយើងខ្ញុំមានលទ្ធភាពបន្តការសិក្សា ចូលរួមក្នុងសកម្មភាពសង្គម ស្គាល់អំពើល្អ អាក្រក់។ ក្រៅពីនេះលោកបានលះបង់កម្លាំងកាយ ចិត្ត ស្មារតី និងសម្ភារៈដើម្បីធ្វើឲ្យយើងខ្ញុំមានកម្លាំងចិត្ត និងអាចបន្តការសិក្សារហូតមកដល់កម្រិតបរិញ្ញាបត្រនេះ ហើយត្រៀមខ្លួនក្នុងការបម្រើតបស្នងលោក និងសង្គមជាតិផងដែរ។

ទន្ទឹមនឹងនេះ យើងខ្ញុំ សូមថ្លែងអំណរគុណដល់ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យ គណៈគ្រប់គ្រង លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ដែលបានខិតខំណែនាំ អប់រំ និងផ្តល់ចំណេះដឹងល្អៗសម្រាប់យើងខ្ញុំជានិស្សិតតាំងពីដំបូង រហូតមកដល់ពេលនេះដោយមិនខ្លាចការនឿយហត់។

យើងខ្ញុំ ក៏សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលដែលបានបន្តយកចិត្តទុកដាក់ក្នុងកំណែទម្រង់លើវិស័យជាច្រើន ជាពិសេសគឺវិស័យអប់រំដែលមានភាពកាន់តែមានភាពល្អប្រសើរឡើង ដែលនេះជាកម្លាំងចិត្តសម្រាប់យើងខ្ញុំជានិស្សិតក្នុងការបន្តស្មារតីសិក្សារៀនសូត្រ និងពង្រឹងសមត្ថភាពដើម្បីជាកម្លាំងចលកររបស់សង្គមជាតិ។

ជាពិសេសយើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះសាស្ត្រាចារ្យ **ឃឹម គីរី** ដែលបានជួយណែនាំយើងខ្ញុំទាំងពីរក្នុងការសិក្សាស្រាវជ្រាវ និងចងក្រងស្នាដៃនេះឡើង។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់ សូមគោរពជូនពរចំពោះលោកឪពុក អ្នកម្តាយដែលជាអ្នកមានគុណូបការៈរបស់យើងខ្ញុំ សាកលវិទ្យាធិការ គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ សូមទទួលនូវការដឹងគុណ និងការគោរពពីយើងខ្ញុំ។

# **អារម្ភកថា**

យើងខ្ញុំឈ្មោះ **អេង សុជាត្តា** និង **លី លីលីន** ជានិស្សិតថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** ឆ្នាំទី៤ ជំនាន់ទី៩នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ហើយក្រោមការដឹកនាំរបស់សាស្ត្រាចារ្យ **ឃឹម គីរី** យើងខ្ញុំបានសម្រេចជ្រើសរើសយកប្រធានបទមួយស្តីពី "**ច្បាប់ និងគោលនយោបាយរបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ**" មករៀបចំជាសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែក **រដ្ឋបាលសាធារណៈ** នេះដោយមានគោលបំណងដើម្បីសិក្សា និងស្វែងយល់ពីកត្តាដែលនាំឲ្យមានការប្រែប្រួលអាកាសធាតុ ហើយវានឹងបង្កផលប៉ះពាល់យ៉ាងណាខ្លះដល់ការរស់លើភពផែនដី ដោយការយល់ឃើញថា សព្វថ្ងៃនេះបញ្ហាបម្រែបម្រួលអាកាសធាតុនេះពុំសូវមានប្រជាពលរដ្ឋណាចាប់អារម្មណ៍ និងយល់ដឹងថាការប្រែប្រួលអាកាសធាតុនេះកើតឡើងដោយសារសកម្មភាពប្រចាំថ្ងៃរបស់ខ្លួនឡើយ។

លើសពីនេះទៅទៀតដោយយល់ឃើញថា រាជរដ្ឋាភិបាលកំពុងតែយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាទាក់ទងនឹងបញ្ហាបម្រែបម្រួលអាកាសធាតុថ្នាក់ជាតិ ដូច្នេះទើបយើងខ្ញុំបានខិតខំធ្វើការសិក្សាស្រាវជ្រាវច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗ និងឯកសារពាក់ព័ន្ធមួយចំនួនទៀត ជាពិសេសគឺស្រាវជ្រាវតាមបណ្តាញសង្គម ឬវេបសាយ (Website) របស់ក្រសួងបរិស្ថាន និង នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពដើម្បីរៀបចំចងក្រងជាឯកសារសារណា សម្រាប់ការពារចំពោះមុខគណៈមេប្រយោគរបស់សាកលវិទ្យាល័យ និងជាពិសេសទុកជាឯកសារសម្រាប់ឲ្យនិស្សិតជំនាន់ក្រោយៗធ្វើជាឯកសារស្រាវជ្រាវ។

ក្នុងសារណានេះ យើងខ្ញុំបានលើកនូវចំណុចសំខាន់មួយចំនួនដូចជាមូលហេតុ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ បញ្ហាបម្រែបម្រួលអាកាសធាតុក្នុងឆាកអន្តរជាតិ បទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ រួមទាំងគោលនយោបាយរបស់រាជរដ្ឋាភិបាលចំពោះបញ្ហាបម្រែបម្រួលអាកាសធាតុនេះ។

ក្នុងនាមយើងខ្ញុំជាអនាគតមន្ត្រីរដ្ឋបាល ដែលគិតដល់ផលប្រយោជន៍របស់សាធារណជនទូទៅ ក៏បានគិតពីបញ្ហា និងផលប៉ះពាល់នានាដល់ប្រជាពលរដ្ឋ យើងខ្ញុំសង្ឃឹមថា សារណាមួយនេះ អាចជំនួយស្មារតីដល់សាធារណជនទាំងអស់។ ក្នុងពេលជាមួយគ្នានេះដែរ យើងខ្ញុំជឿជាក់ថាសារណានេះ ពិតជាមានកំហុសឆ្គង និងចំណុចខ្វះខាតមួយចំនួនជាក់ជាពុំខាន ដូចនេះយើងខ្ញុំរង់ចាំក្នុងការរិះគន់កែលម្អក្នុងន័យស្ថាបនាពីសំណាក់អ្នកសិក្សាទាំងឡាយដោយក្តីសោមនស្សរីករាយ។

# មាតិកា

ទំព័រ

សេចក្តីផ្តើម ........................................ ១

ជំពូកទី១ សញ្ញាណទូទៅនៃបម្រែបម្រួលអាកាសធាតុ

១.១ អ្វីទៅជាបម្រែបម្រួលអាកាសធាតុ ........................................ ៤

១.១.១ និយមន័យ ........................................ ៤

១.១.១.១ ធាតុអាកាស អាកាសធាតុ ........................................ ៤

១.១.១.២ បម្រែបម្រួលអាកាសធាតុ និងសារៈសំខាន់នៃការសិក្សាពីវា ........................................ ៥

១.២ មូលហេតុដែលនាំឲ្យមានបម្រែបម្រួលអាកាសធាតុ ........................................ ៦

១.២.១ សកម្មភាពដែលកើតពីធម្មជាតិ ........................................ ៦

១.២.១.១ បន្ទុះភ្នំភ្លើង ........................................ ៦

១.២.១.២ ចរន្តទឹកនៃមហាសមុទ្រ ........................................ ៧

១.២.១.៣ ការប្រែប្រួលនៃគន្លងគោចរបស់ផែនដី ........................................ ៧

១.២.១.៤ ការប្រែប្រួលនៃប្រព័ន្ធព្រះអាទិត្យ ........................................ ៨

១.២.២ សកម្មភាពរបស់មនុស្ស ........................................ ៩

១.២.២.១ ឥទ្ធិពលនៃឧស្ម័នផ្ទះកញ្ចក់ ........................................ ៩

១.២.២.២ ការប្រែប្រួលការប្រើប្រាស់ដី ........................................ ១០

១.២.២.៣ ការធ្វើកសិកម្ម ........................................ ១០

១.២.២.៤ ការបាត់បង់ព្រៃឈើ ........ ១១

១.៣ ផលប៉ះពាល់ដែលកើតពីបម្រែបម្រួលអាកាសធាតុ ........ ១១

១.៣.១ កំនើនសីតុណ្ហភាព ........ ១២

១.៣.២ ការកើតឡើងនូវបាតុភូតធម្មជាតិ ........ ១២

១.៣.៣ កំនើននីវ៉ូទឹកសមុទ្រ ........ ១៣

១.៣.៤ ផលប៉ះពាល់លើសុខភាពមនុស្ស ........ ១៤

១.៣.៥ ការជះឥទ្ធិពលលើប្រព័ន្ធអេកូឡូស៊ី និងវិស័យកសិកម្ម ........ ១៤

១.៤ សកម្មភាពជាអន្តរជាតិពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ........ ១៥

១.៤.១ កិច្ចប្រជុំក្នុងអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ........ ១៥

១.៤.១.១ សន្ធិសីទរបស់អង្គការសហប្រជាជាតិស្តីពីបរិស្ថានមនុស្សឆ្នាំ១៩៧២ (សន្ធិសីទទីក្រុងស្តុកខូម) ........ ១៦

១.៤.១.២ សន្ធិសីទរបស់អង្គការសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍឆ្នាំ១៩៩២ (សន្ធិសីទទីក្រុងរីអូ ឬ UNCED ឬ the Earth Summit) ........ ២១

១.៤.១.៣ កិច្ចប្រជុំកំពូលពិភពលោកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ២០០២ (WSSD ឬ the Johannesburg Summit) ........ ២៤

១.៤.២ កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ United Nations Environment Programme (UNEP) ........ ២៤

១.៤.៣ គោលដៅអភិវឌ្ឍសហសវត្សរ៍ និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ ........ ២៦

១.៤.៣.១ គោលដៅអភិវឌ្ឍសហសវត្សរ៍ ........ ២៦

១.៤.៣.២ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ........ ២៦

ជំពូកទី២ ក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិស្តីពីបញ្ហាបម្រែបម្រួលអាកាសធាតុ

២.១ បទដ្ឋានគតិយុត្តជាតិពាក់ព័ន្ធនឹងបញ្ហាបម្រែបម្រួលអាកាសធាតុ ........ ២៧

២.១.១ ច្បាប់ ........ ២៧

២.១.១.១ គោលបំណង ........ ២៨

២.១.២ លិខិតបទដ្ឋានក្រោមជាតិ ........ ៣០

២.១.២.១ គោលបំណង ........ ៣០

២.១.៣ ស្ថាប័នអនុវត្ត ........ ៣១

២.២ បទដ្ឋានគតិយុត្តអន្តរជាតិពាក់ព័ន្ធនឹងបញ្ហាបម្រែបម្រួលអាកាសធាតុ ........ ៣៣

២.២.១ អនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ ........ ៣៣

២.២.២ អនុសញ្ញាបាសែលស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូននិងការបោះចោលសំណល់គ្រោះថ្នាក់ឆ្លងដែន ........ ៣៤

២.២.៣ អនុសញ្ញាវីយែន ........ ៣៥

២.២.៤ ពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូសូន ........ ៣៥

២.២.៥ អនុសញ្ញាស្តីពីជីវៈចម្រុះ ........ ៣៦

២.២.៦ អនុសញ្ញាស្តុកខូម ........ ៣៧

២.២.៧ ពិធីសារទីក្រុងក្យូតូ ........ ៣៧

២.៣ ទំនាក់ទំនងរវាងបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិស្តីពីបញ្ហាប្រែប្រួលអាកាសធាតុ........................................................................................................................................................៣៨

២.៣.១ ទំនាក់ទំនង ........................................................................................................៣៨

២.៣.២ គុណសម្បត្តិនៃការចូលជាសមាជិក ..........................................................................៣៨

ជំពូកទី៣ គោលនយោបាយរបស់រដ្ឋាភិបាលចំពោះបញ្ហាប្រែប្រួលអាកាសធាតុ

៣.១ គោលនយោបាយរដ្ឋាភិបាល ........................................................................................ ៤០

៣.១.១ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៤-២០២៣...........៤១

៣.១.២ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង ..........................................................៤៣

៣.១.៣ ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០..................៤៤

៣.២ សកម្មភាពរបស់រដ្ឋាភិបាល និងកិច្ចសហប្រតិបត្តិការអន្តរជាតិ.............................. ៤៥

៣.២.១ សកម្មភាពចម្បងរបស់រដ្ឋាភិបាល ..........................................................................៤៥

៣.២.១.១ ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុឆ្នាំ២០១៦-២០១៨ .................... ៤៥

៣.២.១.២ សកម្មភាពដែលរដ្ឋាភិបាលបានធ្វើកន្លងមក.................................................... ៤៨

ក. ការបន្សុាំ ................................................................................................................. ៤៨

ខ. ការកាត់បន្ថយ ......................................................................................................... ៤៩

៣.២.២ កិច្ចសហប្រតិបត្តិការអន្តរជាតិ...............................................................................៥០

៣.២.២.១ សម្ព័ន្ធប្រែប្រួលអាកាសធាតុកម្ពុជា.................................................................. ៥០

៣.២.២.២ កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ( UNEP ) .....................................៥៣

៣.២.២.៣ មូលនិធិបរិស្ថានសាកល GEF ........................................................................ ៥៤

**សេចក្តីសន្និដ្ឋាន** ........................................................................................................................ **៥៥**

**អនុសាសន៍** ................................................................................................................................ **៥៧**

**គន្ថនិទ្ទេស**

**ឧបសម្ព័ន្ធ**

**ពាក្យបំព្រួញ និងអក្សរកាត់**

# សេចក្ដីផ្ដើម

ការអភិវឌ្ឍប្រទេសជាតិត្រូវពឹងផ្អែកលើវិស័យជាច្រើន ដែលក្នុងនោះរួមមានទាំងវិស័យអប់រំ ច្បាប់ សេដ្ឋកិច្ច វប្បធម៌ បច្ចេកវិទ្យា ពាណិជ្ជកម្ម ហេដ្ឋារចនាសម្ព័ន្ធ វិស័យសុខាភិបាលជាដើម។ ប្រទេសខ្លះមានសន្ទុស្សន៍នៃការរីកចម្រើនលឿនជាងប្រទេសផ្សេង ដែលបណ្ដាលឲ្យតម្រូវការរបស់ប្រទេសទាំងនោះក៏ផ្សេងៗគ្នាដែរ។ តម្រូវការទាំងនោះនាំឲ្យមានផលប៉ះពាល់ដល់វិស័យផ្សេងៗទៀតទោះជាតិចឬច្រើនក្ដី។ ការប៉ះពាល់ដែលសំខាន់មួយក្នុងចំណោមកត្តាដទៃទៀត គឺទៅលើបញ្ហាបរិស្ថានដែលការថែរក្សាបរិស្ថានត្រូវបានទទួលស្គាល់ថាជារឿងដែលត្រូវពិចារណាសម្រាប់ប្រទេសទាំងអស់ទោះជាប្រទេសអភិវឌ្ឍក្ដី ប្រទេសកំពុងអភិវឌ្ឍក្ដី។

ការគិតគូរទៅលើបញ្ហាបរិស្ថានជារឿងដែលមានលក្ខណៈស្មុគស្មាញ។ ជាក់ស្ដែងបញ្ហាបម្រែបម្រួលអាកាសធាតុដែលកើតមានតាំងពីយូរណាស់មកហើយ ជះឥទ្ធិពលដល់ការអភិវឌ្ឍប្រទេស សុមាលភាពមនុស្ស សត្វ ប្រព័ន្ធអេកូឡូស៊ី និងជាពិសេសគឺទៅលើជីវភាពរស់នៅរបស់មនុស្ស។ ក្រៅពីអ្នកបរិស្ថានវិទ្យា បញ្ហាបម្រែបម្រួលអាកាសធាតុមិនសូវត្រូវបានគេចាប់អារម្មណ៍ទេកាលពីមុន។ មុនពេលដែលមានបដិវត្តឧស្សាហកម្មនៅក្នុងសតវត្សរ៍ទី១៨ និង១៩ ការអភិវឌ្ឍប្រទេសគឺផ្ដោតលើការបង្កបង្កើនផលដំណាំដែលមិនសូវមានផលប៉ះពាល់ខ្លាំងនោះទេ។ បន្ទាប់ពីបដិវត្តឧស្សាហកម្មចាប់ផ្ដើម ឧបករណ៍ទំនើបៗបានបង្កើតឡើង តម្រូវការផ្សេងៗមានការកើនឡើង ហើយតម្រូវការចេះតែកើនឡើងស្របពេលដែលបច្ចេកវិទ្យារីកចម្រើន មនុស្សកើនឡើងដែលនាំឲ្យការទាញយកធនធានធម្មជាតិកាន់តែសកម្ម។ ព្រឹត្តិការណ៍សំខាន់មួយទៀតគឺក្រោយសង្គ្រាមលោកលើកទី២ ដែលប្រទេសជាច្រើនបានរងគ្រោះដោយសារសង្គ្រាម ហើយបរិស្ថានក៏ទទួលរងនូវផលប៉ះពាល់យ៉ាងខ្លាំងដែលបណ្ដាលមកពីការទម្លាក់គ្រាប់បែក ការផ្ទុះប្រេង សារធាតុគីមីដែលចេញពីអាវុធគីមីថ្មីៗជាដើម។ ឥទ្ធិពលរបស់វាបានធ្វើឲ្យប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី បំពុលបរិស្ថាន និងសម្លាប់ជីវិតមនុស្ស សត្វជាច្រើនលាននាក់។ ទោះជាយ៉ាងនេះក្ដី បន្ទាប់ពីមានការប៉ះពាល់ដល់សេដ្ឋកិច្ច ក្រោយសង្គ្រាមប្រទេសជាច្រើនបានចាប់ផ្ដើមពង្រឹងវិស័យសេដ្ឋកិច្ចរបស់ខ្លួនយ៉ាងខ្លាំងដោយភ្លេចគិតពីផលប៉ះពាល់ទៅលើបរិស្ថាន និងសុខមាលភាពប្រជាជន។ ជាក់ស្ដែងដូចករណីប្រទេសជប៉ុនដែលរងផលប៉ះពាល់បរិស្ថានដោយការអភិវឌ្ឍផ្នែកឧស្សាហកម្មរបស់ខ្លួនដើម្បីស្ដារសេដ្ឋកិច្ចជាតិក្រោយសង្គ្រាម ឬប្រទេសផ្សេងទៀតដែលធ្វើការកែប្រែដីដើម្បីធ្វើកសិកម្ម ពង្រីកវិស័យឧស្សាហកម្ម និងបច្ចេកវិទ្យារបស់ខ្លួន។ ដូចគ្នានឹងពេលមានបដិវត្តឧស្សាហកម្មដែរ ក្រោយសង្គ្រាមរយៈពេលប៉ុន្មានទសវត្សរ៍ កំណើនប្រជាជនមានច្រើន ដែលនាំឲ្យតម្រូវការមានការកើនឡើងជា

លំដាប់ ស្របពេលដែលវិទ្យាសាស្ត្រមានការវិវត្ត ធ្វើឲ្យផលប៉ះពាល់ដល់បរិយាកាសនិងបរិស្ថានកាន់តែច្រើនឡើងដែរ ដែលវាជាកត្តានាំឲ្យអាកាសធាតុមានការប្រែប្រួលកាន់តែឆាបរហ័ស។

ក្រោយពីមានបាតុភូតធម្មជាតិ និងជំងឺជាច្រើនកើតឡើង កិច្ចប្រជុំអន្តរជាតិជាច្រើនបានរៀបចំឡើង ដែលក្នុងកិច្ចប្រជុំនីមួយៗមានការចូលរួមពីតំណាងប្រទេសជាច្រើន ហើយបានដាក់នូវរបៀបវារៈពីបញ្ហាបរិស្ថាន ព្រមទាំងកាតព្វកិច្ចមួយចំនួនដែលស្នើឲ្យរដ្ឋជួយបំពេញ តាមរយៈកិច្ចព្រមព្រៀងដែលតាក់តែងអនុម័តឡើងសម្រាប់រដ្ឋទាំងនោះ។ តែទោះជាយ៉ាងនេះក្ដី រដ្ឋមួយចំនួនមិនទាន់ចូលជាសមាជិកកិច្ចព្រមព្រៀងនៅឡើយទេ ដោយគេយល់ថាពួកគេត្រូវបំពេញកាតព្វកិច្ចច្រើន ឬការអនុវត្តកាតព្វកិច្ចទាំងនោះនាំឲ្យរាំងស្ទះដល់ការអភិវឌ្ឍប្រទេសរបស់ខ្លួន។ ចំណែកឯប្រទេសកម្ពុជាបានក្លាយជាសមាជិករបស់កិច្ចព្រមព្រៀងអន្តរជាតិមួយចំនួនផងដែរ។ គួរបញ្ជាក់ថាប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍមួយក្នុងចំណោមប្រទេសជាច្រើនដែលទទួលរងនូវឥទ្ធិពលពីបញ្ហាបម្រែបម្រួលអាកាសធាតុ ទោះបីជាប្រទេសយើងមិនទាន់ក្លាយជាប្រទេសដែលចូលរួមចំណែកក្នុងការបង្កើតឲ្យមានផលប៉ះពាល់ខ្លាំងដល់អាកាសធាតុក៏ដោយ។

បញ្ហាបម្រែបម្រួលអាកាសធាតុ ត្រូវការកិច្ចសហប្រតិបត្តិការតាំងពីថ្នាក់ក្រោម រហូតដល់លើពោលគឺទាំងបុគ្គល និងអង្គភាព ស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាស្ថាប័នអន្តរជាតិផ្សេងទៀតជាច្រើន។ ការស្រាវជ្រាវពីបញ្ហាបម្រែបម្រួលអាកាសធាតុមានលក្ខណៈស្មុគស្មាញពិបាក និងទាក់ទងជាមួយបញ្ហាបច្ចេកទេសជាច្រើន តែការស្វែងរកដំណោះស្រាយ និងការលើកឡើងនូវដំណោះស្រាយទាំងនោះក្នុងការអនុវត្តគឺកាន់តែជាកត្តាដែលស្មុគស្មាញ និងត្រូវការរយៈពេលយូរ។ ដំណោះស្រាយមួយជាចម្បងក្នុងការដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុគឺការបង្កើតច្បាប់ និងគោលនយោបាយពាក់ព័ន្ធ ដែលច្បាប់និងគោលនយោបាយទាំងនោះជាមធ្យោបាយណែនាំប្រជាពលរដ្ឋ ស្ថាប័នជាតិ និងអង្គភាពពាក់ព័ន្ធឲ្យបានយល់និងចូលរួមដោះស្រាយ ព្រមទាំងទប់ស្កាត់បញ្ហាបម្រែបម្រួលអាកាសធាតុ។ អ្វីដែលគួរឲ្យកត់សម្គាល់គឺថាច្បាប់ និងគោលនយោបាយទាំងអស់នោះមិនត្រឹមតែបំពេញនូវកាតព្វកិច្ចផ្នែកបរិស្ថានប៉ុណ្ណោះទេ វាក៏ផ្ដោតទៅលើការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជីវភាពប្រជាពលរដ្ឋ ការកាត់បន្ថយភាពក្រីក្រ ការធានានូវការការពារសង្គម វប្បធម៌ និងធនធានធម្មជាតិផងដែរ។ ប្រសិនបើការអនុវត្តច្បាប់ និងគោលនយោបាយដែលពាក់ព័ន្ធនឹងបញ្ហាបម្រែបម្រួលអាកាសធាតុមានលក្ខណៈល្អប្រសើរ ប្រទេសកម្ពុជាយើងអាចនឹងការពារខ្លួនបានប្រសើរជាងមុនទប់ទល់នឹងបញ្ហាអាកាសធាតុ ហើយសេដ្ឋកិច្ចជាតិក៏មានការរីកចម្រើនផងដែរ។

បញ្ហាបម្រែបម្រួលអាកាសធាតុនេះគឺមិនមែនជារឿងដែលទើបតែកើតឡើងនោះទេ ប៉ុន្តែមានមនុស្សជាច្រើននៅមិនទាន់បានចាប់អារម្មណ៍ យល់ដឹង ឬធ្វើសកម្មភាពដើម្បីឆ្លើយតបទៅនឹងបញ្ហានេះនៅឡើយ។ ក្រៅពីចំណេះដឹងរបស់ប្រជាជន បញ្ហាដែលយើងជួបប្រទះគឺកង្វះការយកចិត្តទុកដាក់ពីអ្នកសិក្សា។ ការអនុវត្តច្បាប់ពាក់ព័ន្ធឲ្យមានប្រសិទ្ធិភាពគឺជាមធ្យោបាយដែលប្រទេសនីតិរដ្ឋអាចយកទៅប្រើប្រាស់បានក្នុងការដោះស្រាយបញ្ហា ក៏ប៉ុន្តែចំនួនអ្នកសិក្សាច្បាប់ដែលយល់ដឹងពីកម្រងបទដ្ឋានគតិយុត្តលើបញ្ហាបម្រែបម្រួលអាកាសធាតុមិនសូវមានច្រើននោះទេ។ ប្រធានបទនេះគឺលើកឡើងពីច្បាប់អន្តរជាតិ ច្បាប់ជាតិ លិខិតបទដ្ឋានគតិយុត្តផ្សេងៗ ជាពិសេសគឺគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ ការបន្ស៊ាំខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុ ក៏ដូចជាការកាត់បន្ថយការរួមចំណែកការនាំឲ្យមានបម្រែបម្រួលអាកាសធាតុផងដែរ។ ការចងក្រងស្នាដៃនេះឡើងគឺក្នុងបំណងធ្វើឲ្យអ្នកសិក្សាច្បាប់ដទៃទៀតយល់ពីបញ្ហាបរិស្ថាន ជាពិសេសគឺបញ្ហាបម្រែបម្រួលអាកាសធាតុ និងប្រព័ន្ធច្បាប់ និងគោលនយោបាយពាក់ព័ន្ធ ដើម្បីបន្តការអភិវឌ្ឍប្រទេសឲ្យបានរីកចម្រើន។ ក្នុងការស្រាវជ្រាវនេះគឺផ្តោតលើមូលហេតុ និងផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ និងថាតើមានសកម្មភាពអ្វីខ្លះដែលគេបានធ្វើកន្លងមកដើម្បីបរិស្ថាន? តើច្បាប់និងគោលនយោបាយបម្រើផលប្រយោជន៍បរិស្ថាន សង្គម និងសេដ្ឋកិច្ចដូចម្តេចដែរ? តើស្ថាប័នណាខ្លះដែលទទួលខុសត្រូវក្នុងការអនុវត្តច្បាប់ និងគោលនយោបាយទាំងនោះ? ហើយរដ្ឋាភិបាលមានគោលនយោបាយ និងចក្ខុវិស័យយ៉ាងណានៅពេលអនាគត? ដើម្បីឲ្យមានភាពងាយស្រួលក្នុងការយល់ដឹង និងពិចារណា សូមធ្វើការបែងចែកស្នាដៃនេះជាបីជំពូក ដែលខ្លឹមសារសំខាន់របស់ជំពូកនីមួយៗបែងចែកដូចតទៅ៖

- ជំពូកទី១ នឹងធ្វើការបកស្រាយពីសញ្ញាណជាទូទៅនៃបញ្ហាបម្រែបម្រួលអាកាសធាតុដោយភ្ជាប់ជាមួយនឹងសកម្មភាពជាអន្តរជាតិពាក់ព័ន្ធ
- ជំពូកទី២ នឹងធ្វើការពិពណ៌នាពីច្បាប់ជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនឹងបញ្ហាបម្រែបម្រួលអាកាសធាតុ និងទំនាក់ទំនងរបស់ច្បាប់ទាំងនោះ
- ជំពូកទី៣ នឹងលើកបង្ហាញពីគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាសកម្មភាពរបស់រាជរដ្ឋាភិបាលដែលបាននឹងកំពុងធ្វើដើម្បីឆ្លើយតបនឹងបញ្ហាបម្រែបម្រួលអាកាសធាតុ

# ជំពូកទី១

# សញ្ញាណទូទៅនៃបម្រែបម្រួលអាកាសធាតុ

# ជំពូកទី១ សញ្ញាណទូទៅនៃបម្រែបម្រួលអាកាសធាតុ

យើងតែងតែលឺគេនិយាយអំពីពាក្យថាអាកាសធាតុ ឬក៏ធាតុអាកាសជាប្រចាំ។ មានអ្នកខ្លះអាចនឹងគិតថាវាគ្រាន់តែការត្រឡប់លំដាប់ពាក្យតែប៉ុណ្ណោះ ហើយអ្នកខ្លះក៏បានគិតថាប្រើប្រាស់មួយណាក៏បាន តែការពិតពាក្យទាំងពីរនេះត្រូវបានប្រើប្រាស់ និងឲ្យនិយមន័យផ្សេងពីគ្នា។ តើអ្វីទៅជាអត្ថន័យរបស់ពាក្យថាអាកាសធាតុ ធាតុអាកាស និងបម្រែបម្រួលអាកាសធាតុ។ ទោះបីជាមានការភ័ន្តច្រឡំលើការប្រើប្រាស់ពាក្យក៏ដោយ យ៉ាងហោចណាស់អ្នកអាចនឹងធ្លាប់បាននិយាយបានលឺ ឬអានអត្ថបទដែលសរសេរពីការកើនឡើងកម្ដៅផែនដី ភ្លៀងធ្លាក់ សីតុណ្ហភាពប្រចាំថ្ងៃ ទឹកជំនន់ គ្រោះរាំងស្ងួតជាដើម។ តើបាតុភូតខាងលើនេះមានភាពពាក់ព័ន្ធអ្វីនឹងពាក្យថាធាតុអាកាស អាកាសធាតុ និងបម្រែបម្រួលអាកាសធាតុ។

## ១.១ អ្វីជាបម្រែបម្រួលអាកាសធាតុ

### ១.១.១ និយមន័យ

#### ១.១.១.១ ធាតុអាកាស អាកាសធាតុ

ធាតុអាកាសគឺសំដៅលើលក្ខណៈដែលបរិយាកាសប្រព្រឹត្តទៅ ជាពិសេសគឺឥទ្ធិពលរបស់បរិយាកាសទៅលើជីវិត និងសកម្មភាពរបស់មនុស្ស។[1] ធាតុអាកាសគឺជាលក្ខខណ្ឌនៃបរិយាកាសផែនដីនៅកន្លែងមួយ និងពេលវេលាជាក់លាក់។ ធាតុអាកាសត្រូវបានគេគិតក្នុងរយៈពេលខ្លី អាចជានាទីឬម៉ោង ថ្ងៃឬខែ ដែលមានកន្លែងភាគច្រើន ធាតុអាកាសបានផ្លាស់ប្ដូរយ៉ាងឆាប់រហ័សពីមួយនាទីទៅមួយនាទី ពីមួយម៉ោងទៅមួយម៉ោង ឬពីមួយរដូវទៅមួយរដូវ។[2] គេអាចនិយាយពីធាតុអាកាសពេលគេសំដៅលើលក្ខខណ្ឌនៃសីតុណ្ហភាព សំណើម ពន្លឺព្រះអាទិត្យ ពពក ខ្យល់ សម្ពាធបរិយាកាស។ ធាតុអាកាសអាចប្រែប្រួលយ៉ាងរហ័សនៅតំបន់មួយចំនួន។ ផ្ទុយទៅវិញអាកាសធាតុគឺសំដៅដល់កម្រិតមធ្យមរបស់ធាតុអាកាសក្នុងរយៈពេលកំណត់មួយ និងស្ថិតក្នុងលំហ។[3] ដើម្បីឲ្យងាយក្នុងការចំណាំពាក្យទាំងពីរនេះ គេអាចប្រៀបធៀបអាកាសធាតុទៅនឹងអ្វីដែលយើងរំពឹងទុកដូចជារដូវវស្សាពេលខាងមុខនឹងមានភ្លៀងធ្លាក់តិច ឬរដូវប្រាំងក្ដៅខ្លាំងជាដើម ចំណែកឯធាតុអាកាសគឺជាអ្វីដែលយើងនឹងទទួលបាន ឧទាហរណ៍ដូចជាភ្លៀងធ្លាក់នៅថ្ងៃដែលក្ដៅខ្លាំង។ ធាតុ

[1] www.nasa.gov/mission_pages/noaa-n/climate/climate_weather.html (ចូលទស្សនាថ្ងៃទី១៧មេសា ២០១៦)។

[2] ដូចខាងលើ។

[3] ដូចខាងលើ។

អាកាសរួមមានសមាសភាគជាច្រើនដែលបង្កើតវា ក្នុងនោះមានដូចជាពន្លឺព្រះអាទិត្យ ភ្លៀង ផ្គាំង ពពក ខ្យល់ ព្រិល ព្យុះ កម្ដៅ រលកកម្ដៅ។

អាកាសធាតុគឺសំដៅលើលក្ខណៈរបស់អាកាសធាតុដែលប្រព្រឹត្តទៅក្នុងរយៈពេលវែងនៅក្នុងតំបន់ជាក់លាក់មួយ។[4] អ្នកវិទ្យាសាស្ត្រខ្លះបានឲ្យនិយមន័យថាអាកាសធាតុគឺជាធាតុអាកាសគិតជាមធ្យមសម្រាប់តំបន់ណាមួយក្នុងពេលវេលាជាក់លាក់មួយ ដែលជាទូទៅត្រូវបានគិតក្នុងកំឡុងពេលចាប់ពី៣០ឆ្នាំឡើងទៅ។ វាជាទម្រង់ធាតុអាកាសមធ្យមសម្រាប់តំបន់ជាក់លាក់មួយ។ ពេលដែលគេនិយាយពីអាកាសធាតុ គេសំដៅទៅលើកម្រិតមធ្យមរបស់សីតុណ្ហភាព សំណើម ពន្លឺព្រះអាទិត្យ កម្លាំងខ្យល់ បាតុភូតផ្សេងៗដូចជាអ័ព្ទ សន្សើម ព្យុះ និងសមាសភាគផ្សេងៗទៀតរបស់ធាតុអាកាសដែលកើតឡើងក្នុងរយៈពេលវែងក្នុងតំបន់ជាក់លាក់មួយ។

### ១.១.១.២ បម្រែបម្រួលអាកាសធាតុ និងសារៈសំខាន់នៃការសិក្សាពីវា

យើងប្រហែលជាតែងតែលឺពីបម្រែបម្រួលអាកាសធាតុ ប៉ុន្តែតើអ្វីទៅជាបម្រែបម្រួលអាកាសធាតុ ហើយហេតុអ្វីបានជាយើងត្រូវសិក្សាពីវា។ បម្រែបម្រួលអាកាសធាតុត្រូវបានឲ្យនិយមន័យថាជាការផ្លាស់ប្ដូរធាតុអាកាសប្រចាំថ្ងៃគិតជាមធ្យមគិតក្នុងរយៈពេលវែង និងក្នុងតំបន់ជាក់លាក់មួយ។ បម្រែបម្រួលអាកាសធាតុកើតមានក្នុងរូបភាពជាការប្រែប្រួលរយៈពេលខ្លី និងការប្រែប្រួលរយៈពេលវែង។ រយៈពេលខ្លីនេះមិនសំដៅលើរយៈពេលមួយថ្ងៃ មួយខែទេ តែវាគឺគិតពីច្រើនឆ្នាំឡើងទៅ។ ការកើនកម្ដៅក្នុងរដូវប្រាំង ឬភ្លៀងធ្លាក់ខ្លាំងមុនរដូវវស្សា គឺជារូបភាពនៃបម្រែបម្រួលអាកាសធាតុដែលកើតឡើងក្នុងរយៈពេលវែង ដែលគេអាចសង្កេតឃើញឬកត់សម្គាល់បានក្នុងរយៈពេលយូរ ផ្ទុយទៅវិញបម្រែបម្រួលអាកាសធាតុក៏អាចកើតមានក្នុងរូបភាពជា បន្ទុះភ្នំភ្លើង ការប្រែប្រួលនៃប្រព័ន្ធព្រះអាទិត្យ ចលនា El Niño ចលនា La Niña ពោលគឺបាតុភូតដែលកើតក្នុងកំឡុងពេលមួយខ្លី។[5] ជាការចាំបាច់ណាស់ដែលយើងត្រូវយល់ដឹងពីបញ្ហាបម្រែបម្រួលអាកាសធាតុ ព្រោះមនុស្សគ្រប់គ្នាគឺសុទ្ធតែរងឥទ្ធិពលរបស់វាទោះជាតិចឬច្រើនក្ដី។ មានមនុស្សមួយចំនួនប្រហែលជាគិតថាបម្រែបម្រួលអាកាសធាតុមិនមែនជារឿងសំខាន់ដែល គួរយកមកសិក្សា និងស្វែងយល់ទេ ប៉ុន្តែគេកំពុងភ្លេចថាអាកាសធាតុ ធាតុអាកាសប្រែប្រួលយ៉ាងរហ័ស កម្ដៅផែនដីកាន់តែកើនឡើង ភ្លៀងធ្លាក់មិនទៀងទាត់ ឬទិន្នផលដំណាំធ្លាក់ចុះ។ ការសិក្សាពីបញ្ហាបម្រែបម្រួលអាកាសធាតុពិតជាមានសារៈសំខាន់ណាស់។ បាតុភូតធម្មជាតិមួយអាចនឹងបណ្ដាលឲ្យមានបញ្ហា

[4] ដូចខាងលើ។

[5] ដូចខាងលើ។

ជាច្រើនផ្សេងទៀតកើតឡើង ឧទាហរណ៍ដូចជាការកើនឡើងកម្តៅផែនដីដែលអាចជះឥទ្ធិពលដល់កំនើននីវ៉ូទឹកសមុទ្រ និងលក្ខខណ្ឌអាកាសធាតុផ្សេងទៀត។

## ១.២ មូលហេតុដែលនាំឲ្យមានបម្រែបម្រួលអាកាសធាតុ

មានមូលហេតុជាច្រើនដែលនាំឲ្យមានបម្រែបម្រួលអាកាសធាតុ។ មូលហេតុទាំងនោះរួមមាន៖ សកម្មភាពដែលកើតពីធម្មជាតិរួមមាន បាតុភូត El Niño បន្ទុះភ្នំភ្លើង រួមទាំងសកម្មភាពរបស់មនុស្សដូចជា ឥទ្ធិពលនៃឧស្ម័នផ្ទះកញ្ចក់ ការប្រែប្រួលការប្រើប្រាស់ដី ជាដើម។

### ១.២.១ សកម្មភាពដែលកើតពីធម្មជាតិ

ការប្រែប្រួលអាកាសធាតុដែលកើតឡើងដោយសារសកម្មភាពរបស់ធម្មជាតិ សំដៅដល់រាល់សកម្មភាពដែលកើតឡើងដោយឯកឯង គ្មានអ្នកណាអាចស្មានដឹងទេថាវានឹងកើតឡើងនៅពេលណា។[6] ក៏ប៉ុន្តែដោយសារបច្ចុប្បន្ននេះ បច្ចេកវិទ្យាជឿនលឿន អ្នកវិទ្យាសាស្ត្រអាចសិក្សា និងស្រាវជ្រាវដឹងពីបាតុភូតជាច្រើននៅជុំវិញផែនដី។

#### ១.២.១.១ បន្ទុះភ្នំភ្លើង

បន្ទុះភ្នំភ្លើងគឺជាបាតុភូតធម្មជាតិដែលបង្កឲ្យមានបម្រែបម្រួលអាកាសធាតុ។ នៅពេលភ្នំភ្លើងផ្ទុះ វាបានបញ្ចេញនូវបរិមាណដ៏ច្រើននៃ ឧស្ម័នស៊ុលផួរឌីអុកស៊ីត($SO_2$) អាស៊ីតក្លរីទ្រិច(HCL) ចំហាយទឹក ធូលីដី និងផេះទៅក្នុងបរិយាកាស។ ហើយបរិមាណដ៏ច្រើននៃឧស្ម័ននេះ បានជះឥទ្ធិពលដល់លក្ខខណ្ឌនៃអាកាសធាតុ ដោយធ្វើឲ្យបរិយាកាសផែនដីចុះត្រជាក់។ ដោយសារកំទេចល្អិតតូចៗដែលភាយឡើងនៅក្នុងមណ្ឌលអាកាសរចល់ (Troposphere) ប៉ះនឹងពពក បង្កជាភ្លៀងអាស៊ីត ដែលនាំឲ្យប៉ះពាល់ដល់ភាវរស់ទាំងឡាយយ៉ាងខ្លាំង។ ផ្ទុយទៅវិញ បើបន្ទុះនោះ ផ្ទុះខ្លាំងហួសពីមណ្ឌលអាកាសរចល់នោះ ដល់មណ្ឌលអាកាសស្ងប់ (Stratosphere) ធ្វើឲ្យឧស្ម័នស៊ុលផួរឌីអុកស៊ីតនោះ បំលែងទៅជាអាស៊ីតស៊ុលផួរិច ហើយវាស្រូបយកនូវកាំរស្មីព្រះអាទិត្យ ហើយជះកាំរស្មីព្រះអាទិត្យទៅក្នុងលំហាវិញ ដោយសារតែកំទេចល្អិតទាំងនោះកកនៅក្នុងបរិយាកាស ហើយធ្វើឲ្យកាំរស្មីព្រះអាទិត្យមិនអាចជ្រាប និងសាយភាយដល់ផ្ទៃផែនដីនោះទេ ដែលនាំឲ្យផែនដីមានបរិយាកាសត្រជាក់។

[6] www.climatechangechallenge.org (ចូលទស្សនាថ្ងៃទី១៧ មេសា ឆ្នាំ២០១៦)។

### ១.២.១.២ ចរន្តទឹកនៃមហាសមុទ្រ

មហាសមុទ្រគឺជាធាតុផ្សំមួយដ៏សំខាន់នៃប្រព័ន្ធអាកាសធាតុ។ នៅតំបន់អេក្វាទ័រ ទឹកនៅលើផ្ទៃសមុទ្រមានកម្តៅក្តៅប្រហែលជា២៤ ទៅ២៦អង្សារសែលស្យុស ដោយសារតែកម្តៅនៃព្រះអាទិត្យ តែសីតុណ្ហភាពនៅក្នុងជម្រៅទឹកសមុទ្របែរជាត្រជាក់ខ្លាំង ដែលបាតសមុទ្រអាចមានសីតុណ្ហភាពដល់ទៅសូន្យអង្សារឯណោះ។ រីឯទឹកនៅតំបន់ប៉ូលនៃទ្វីបអាកទិច គឺមានសីតុណ្ហភាពត្រជាក់ខ្លាំង។ ហើយចរន្តនៃទឹកមហាសមុទ្រកើតឡើងដោយសារ កម្លាំងខ្យល់នៃតំបន់អេក្វាទ័របានបក់ផាត់ទឹកលើផ្ទៃសមុទ្រទៅកាន់តំបន់ប៉ូលតាមផ្ទៃខាងលើ រីឯទឹកត្រជាក់នៃតំបន់ប៉ូលតាមរយៈបាត សមុទ្រ។ តែមូលហេតុនៃបម្រែបម្រួលអាកាសធាតុគឺដោយសារបាតុភូតធម្មជាតិម្យ៉ាងហៅថា ចលនា El Niño ដែលជាបាតុភូតនៃការវិលវល់ចុះឡើងនៃកម្តៅទឹកក្តៅ និងទឹកត្រជាក់ដែលកើតឡើងនៅតំបន់មហាសមុទ្រប៉ាស៊ីហ្វិក ដោយសារតែមានកម្លាំងខ្យល់ខ្លាំងជាងមុននៅតំបន់នោះ ហើយបង្កឲ្យចរន្តទឹកមហាសមុទ្រខុសពីធម្មតា។ ក្នុងករណីនេះនឹងអាចបង្កឲ្យទឹកនៃតំបន់ប៉ូលកាន់តែត្រជាក់ខ្លាំង រីឯទឹកនៃតំបន់អេក្វាទ័រកាន់តែក្តៅខ្លាំង ដែលវានឹងបង្កឲ្យមានផលប៉ះពាល់ជាច្រើន។ ម្យ៉ាងវិញទៀត មហាសមុទ្រដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់នូវកំហាប់នៃឧស្ម័នកាបូនិចក្នុងបរិយាកាស។ ដូចនេះការប្រែប្រួលនៃចរន្តទឹកនៃមហាសមុទ្របានជះឥទ្ធិពលដល់អាកាសធាតុតាមរយៈចលនានៃឧស្ម័នកាបូនិចដែលនៅក្នុង និងក្រៅបរិយាកាស។

### ១.២.១.៣ ការប្រែប្រួលនៃគន្លងគោចររបស់ផែនដី

ផែនដីបានបង្កើតនូវគន្លងពេញលេញមួយជុំវិញព្រះអាទិត្យស្មើនឹងរយៈពេលមួយឆ្នាំ រីឯព្រះច័ន្ទវិលជុំវិញផែនដី។ តាមការសិក្សាផែនដីវិទ្យា បានឲ្យដឹងថាគ្រប់អង្គក្នុងលំហតែងតែមាននិចលភាព[7] ដែលវាគឺជាទំនោរនៃវត្ថុមួយក្នុងការទប់ទល់នឹងការប្រែប្រួលចលនា ដូចនេះប្រសិនបើមានតែនិចលភាព នោះចលនានៃផែនដី និងព្រះច័ន្ទនឹងក្លាយជាចលនាត្រង់ស្មើ។ នៅក្នុងបាតុភូតនេះ ដោយសារតែផែនដី និងព្រះអាទិត្យមានកម្លាំងទំនាញរៀងៗខ្លួន ដែលនាំឲ្យអង្គទាំងបីនេះនៅតែរក្សានូវចលនារបស់ខ្លួនឲ្យស្ថិតគន្លងបានយ៉ាងល្អ។ ហើយក្នុងពេលដែលផែនដីវិលជុំវិញព្រះអាទិត្យ ផែនដីក៏បានវិលជុំវិញខ្លួនឯងផងដែរដោយក្នុងមួយជុំគឺស្មើនឹងមួយថ្ងៃ ហើយរវាងចលនាទាំងពីរនេះ ផែនដីបានទ្រេត ២៣.៥ ដឺក្រេ ។ ទោះជាយ៉ាងណា នៅក្នុងដំណើររបស់ផែនដីក៏មានការប្រែប្រួលខ្លះៗដែរ បើទោះជាទម្រេតរបស់ផែនដីមានការប្រែប្រួលតិចតួចក្តី តែកត្តាសំខាន់នៃ

[7] សៀវភៅពុម្ព ផែនដី និងបរិស្ថានវិទ្យា ថ្នាក់ទី១១, ច្បាប់និចលភាព (ច្បាប់ទី១ញូតុន), ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ការប្រែប្រួលអាកាសធាតុដែលនាំឲ្យមានភាពចម្លែកនៅក្នុងរដូវនីមួយៗ។ ក្នុងករណីដែលការទ្រេតនៃផែនដីខ្លាំង គឺបង្កឲ្យមានកម្តៅខ្លាំងនៅរដូវប្រាំង និងត្រជាក់ខ្លាំងនៅរដូវរងា។ ក្នុងករណីការទ្រេតតិចជាង ២៣.៥ដឺក្រេ គឺធ្វើឲ្យមិនសូវក្តៅខ្លាំងនៅរដូវប្រាំង និងមិនត្រជាក់ខ្លាំងនៅរដូវរងា។ នេះជាការប្រែប្រួលនៃអាកាសធាតុ ទោះជាការប្រែប្រួលនោះយឺត តែភាពចម្លែកនោះកើតឡើងច្រើនជាងមួយម៉ឺនឆ្នាំងណោះ។

### ១.២.១.៤ ការប្រែប្រួលនៃប្រព័ន្ធព្រះអាទិត្យ

ព្រះអាទិត្យគឺជាប្រភពថាមពលសម្រាប់ប្រព័ន្ធអាកាសធាតុរបស់ផែនដី។ ទោះបីជាថាមពលព្រះអាទិត្យកើតមានជាប្រចាំដែលអាចឲ្យយើងសង្កេតឃើញជារៀងរាល់ថ្ងៃ ការប្រែប្រួលតិចតួចក៏អាចធ្វើឲ្យមានការប្រែប្រួលអាកាសធាតុបានដែរ។ មានអ្នកវិទ្យាសាស្ត្រខ្លះបានផ្តល់ការសង្ស័យថាការកើនឡើងកម្តៅមួយផ្នែកដែលមាននៅក្នុងពាក់កណ្តាលសតវត្សទី២០ គឺដោយសារតែកំណើនថាមពលដែលបានមកពីថាមពលព្រះអាទិត្យ។[8] ដោយសារព្រះអាទិត្យជាប្រភពថាមពលចម្បងដែលចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងប្រព័ន្ធអាកាសធាតុ ដូច្នេះវាជាការសមហេតុផលដែលគេប៉ាន់ស្មានថាការប្រែប្រួលនៃប្រព័ន្ធព្រះអាទិត្យនឹងនាំអាកាសធាតុប្រែប្រួល។ អ្នកវិទ្យាសាស្ត្របានបង្ហាញថាការប្រែប្រួលនៃប្រព័ន្ធព្រះអាទិត្យបានរួមចំណែកក្នុងបម្រែបម្រួលអាកាសធាតុដែលកើតមានពីមុនមក។ ជាក់ស្តែងការធ្លាក់ចុះនៃសកម្មភាពរបស់ព្រះអាទិត្យបានបណ្តាលឲ្យមានសម័យទឹកកក (Little Ice Age) នៅចន្លោះឆ្នាំ១៦៥០ ដល់ឆ្នាំ១៨៥០។ ការកើនឡើងកម្តៅផែនដីដែលមានក្នុងពេលបច្ចុប្បន្ននេះគឺមិនអាចត្រូវបានបកស្រាយដោយបម្រែបម្រួលប្រព័ន្ធព្រះអាទិត្យទេ។ ប្រសិនបើការកើនឡើងនៃកម្តៅផែនដី បានបណ្តាលមកពីសកម្មភាពព្រះអាទិត្យ អ្នកវិទ្យាសាស្ត្រប្រហែលរំពឹងឃើញសីតុណ្ហភាពកក់ក្តៅជាងនេះនៅគ្រប់ស្រទាប់បរិយាកាស។ ប៉ុន្តែពួកគេបានសង្កេតឃើញមានតែសីតុណ្ហភាពត្រជាក់នៅបរិយាកាសខាងលើសីតុណ្ហភាពក្តៅល្មមនៅស្រទាប់ផ្ទៃក្រៅនិងខាងក្រោមរបស់បរិយាកាស។ នេះបណ្តាលមកពីឧស្ម័នផ្ទះកញ្ចក់ដែលចាប់យកកម្តៅនៅស្រទាប់បរិយាកាសខាងក្រោម។

[8] www.climate.nasa.gov/causes/ (ចូលទស្សនាថ្ងៃទី១៧ មេសា ឆ្នាំ២០១៦)។

## ១.២.២ សកម្មភាពរបស់មនុស្ស

### ១.២.២.១ ឥទ្ធិពលនៃឧស្ម័នផ្ទះកញ្ចក់

អ្នកវិទ្យាសាស្ត្រផ្នែកអាកាសធាតុភាគច្រើន បានជឿជាក់ថា ចំនុចដែលសំខាន់បំផុតនៃការឡើងកម្តៅផែនដីនាពេលបច្ចុប្បន្ននេះ គឺដោយសារសកម្មភាពមនុស្សដែលបានបង្កើននូវឥទ្ធិពលនៃឧស្ម័នផ្ទះកញ្ចក់។ ឧស្ម័នផ្ទះកញ្ចក់បានរួមចំនែកយ៉ាងខ្លាំងក្នុងការការពារជីវិតនៅលើផែនដី ដោយឧស្ម័នទាំងនោះ បានធ្វើការឃាត់ទុកនូវកម្តៅ និងពន្លឺព្រះអាទិត្យមួយផ្នែក ហើយបានធ្វើឲ្យកាំរស្មីព្រះអាទិត្យមួយចំនែកផ្លាតទៅលំហវិញ ដោយមានតែកាំរស្មីមួយភាគតូចប៉ុណ្ណោះបានបាចសាយមកលើផ្ទៃផែនដី។ ប៉ុន្តែការកើនឡើងនូវបរិមាណរបស់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាសបានបង្កឲ្យកម្តៅក្នុងបរិយាកាសកើនឡើងខ្លាំងតាមរយៈការចាប់យកកម្តៅពីព្រះអាទិត្យ។ ឧស្ម័នសំខាន់ៗទាំងនោះរួមមាន ចំហាយទឹក ($H_2O$) ឧស្ម័នកាបូនិច ($CO_2$) ឧស្ម័ននីត្រូអុកស៊ីត ($N_2O$) និងឧស្ម័នមេតាន ($CH_4$)។

ចំហាយទឹក គឺជាឧស្ម័នដែលមានច្រើនជាងគេក្នុងផលផ្ទះកញ្ចក់ ហើយវាបានដើរតួយ៉ាងសំខាន់ក្នុងការឆ្លើយតបនឹងអាកាសធាតុ។ ដោយសារចំហាយទឹកបានបង្កជាពពក និងភ្លៀង ដែលវាជាដំណើរនៃការឆ្លើយតបដ៏សំខាន់ចំពោះផលនៃឧស្ម័នផ្ទះកញ្ចក់។

រីឯឧស្ម័នកាបូនិចវិញ គឺជាឧស្ម័នដែលមានសមាសភាគតិចក្នុងបរិយាកាស ក៏ប៉ុន្តែវាជាធាតុដ៏សំខាន់បំផុត។ ឧស្ម័ននេះត្រូវបានបញ្ចេញតាមរយៈដំណើរប្រព្រឹត្តទៅនៃធម្មជាតិដូចជា ការដកដង្ហើម បន្ទុះភ្នំភ្លើង និងតាមរយៈសកម្មភាពមួយចំនួនរបស់មនុស្សដូចជា ការកាប់ព្រៃឈើ បម្រែបម្រួលនៃការប្រើប្រាស់ដីធ្លី ការដុតឥន្ធនៈហ្វូស៊ីល។ សកម្មភាពរបស់មនុស្សក៏បានបង្កើននូវកំហាប់នៃឧស្ម័នកាបូនិចក្នុងបរិយាកាសចំនួនមួយភាគបីច្រើនជាងមុន តាំងពីការចាប់ផ្តើមនៃបដិវត្តន៍ឧស្សាហកម្ម។ នេះជាកត្តាសំខាន់បំផុតក្នុងការបង្កឲ្យមានការផ្លាស់ប្តូរអាកាសធាតុក្នុងរយៈពេលយូរអង្វែង។

ចំពោះឧស្ម័នមេតាន គឺជាពពួកឧស្ម័នអ៊ីដ្រូកាបូនមួយ ដែលត្រូវបានផលិតដោយធនធានធម្មជាតិ និងសកម្មភាពរបស់មនុស្សរួមមាន ការបំបែកធាតុនៃកាកសំណល់នៅកន្លែងចាក់សម្រាម ការធ្វើកសិកម្មជាពិសេសគឺការដាំដុះដំណាំស្រូវ ការរំលាយអាហារឲ្យសត្វចិញ្ចឹម និងការប្រើប្រាស់ជីអាចម៍សត្វក្នុងកសិដ្ឋាន។ ឧស្ម័នមេតាន គឺជាឧស្ម័នផ្ទះកញ្ចក់ដែលមានភាពសកម្មជាងឧស្ម័នកាបូនិច តែវាមានតិចតួចបំផុតក្នុងបរិយាកាស។

ឧស្ម័ននីត្រូអុកស៊ីត គឺជាឧស្ម័នផ្ទះកញ្ចក់ដែលមានអានុភាព ត្រូវបានផលិតដោយ ការដុត ជីវសាស្ត្រចម្រុះ ការប្រើប្រាស់ដី ជាពិសេសគឺការប្រើប្រាស់ជីធម្មជាតិ ចំហេះនៃឥន្ធនៈផូស៊ីល ការផលិតអាស៊ីតនីទ្រិច។

### ១.២.២.២ ការប្រែប្រួលការប្រើប្រាស់ដី

ការប្រែប្រួលការប្រើប្រាស់ដី គឺជាប្រភេទមួយនៃសកម្មភាពរបស់មនុស្សដែលបង្កឲ្យអាកាសធាតុនៃផែនដីប្រែប្រួល។[9] និយមន័យនេះត្រូវបានកំនត់ដោយអង្គការឧតុនិយមពិភពលោក (World Meteorological Organization) ។ កាលពីសម័យបុរាណ មនុស្សបានរស់នៅក្នុងព្រៃ មានលក្ខណៈជាកុលសម្ព័ន្ធ ហើយក៏មិនទាន់មានការយល់ដឹងអំពីការប្រើប្រាស់ដី ទើបតម្រូវការប្រើប្រាស់ដី ពុំទាន់មានច្រើន។ ក្រោយមក មនុស្សមានការវិវត្ត ទាំងការយល់ដឹង ទាំងជីវភាពរស់នៅ ទាំងការទទួលបានសិទ្ធិក្នុងសហគមន៍ដែលពួកគេរស់នៅ ជាពិសេសគឺកម្មសិទ្ធិលើដីធ្លី ទើបធ្វើឲ្យមានការកើនឡើងនៃតម្រូវការនៃការប្រើប្រាស់ដី ហើយក៏បង្កឲ្យមានការប្រែប្រួលដល់ការប្រើប្រាស់ដី។ ដែលការប្រែប្រួលនេះសំដៅដល់សកម្មភាពនៃការកាប់ព្រៃឈើ ក្នុងករណីនេះនាំឲ្យមានការប្រែប្រួលនៃបរិមាណពន្លឺព្រះអាទិត្យដែលចាំងផ្លាតពីផ្ទៃផែនដីត្រលប់ទៅលំហវិញ។ ដោយទំហំនៃការប្រែប្រួលក្នុងករណីនេះ ត្រូវបានប៉ាន់ស្មានថានឹងជះឥទ្ធិពលដល់អាកាសធាតុពិភពលោកដល់ទៅមួយភាគប្រាំ ពាក់ព័ន្ធនឹងការប្រែប្រួលឧស្ម័ននៅក្នុងផលផ្ទះកញ្ចក់។ ក្នុងករណីគ្រាន់តែជាបរិមាណដ៏តូចនៃការកាប់ព្រៃឈើប៉ុណ្ណោះ វាពុំទាន់មានការប៉ះពាល់ដល់បរិស្ថាន ក៏ដូចជាអាកាសធាតុធ្ងន់ធ្ងរនោះទេ។ ជាក់ស្តែងប្រហែលជាពាក់កណ្តាលនៃការប្រែប្រួលការប្រើប្រាស់ដីនេះ ត្រូវបានប៉ាន់ស្មានថាបានកើតឡើងក្នុងសម័យឧស្សាហកម្ម ដោយសារតែតម្រូវការប្រើប្រាស់ដី កាន់តែរីកដុះដាល។ នៅពេលនោះចំនួនប្រជាជននៅលើពិភពលោកមានការកើនឡើងយ៉ាងខ្លាំង ដូចនេះមានតម្រូវការផ្លាស់ប្តូរទីតាំងដែលធ្លាប់តែជាព្រៃស្តុក ឲ្យទៅជាលំនៅដ្ឋាន កសិដ្ឋានចិញ្ចឹមសត្វខ្នាតធំៗ ចំការដំណាំកសិកម្មផ្សេងៗ វាលស្មៅ វាលរហោដ្ឋាន។

### ១.២.២.៣ ការធ្វើកសិកម្ម

ពិតប្រាកដណាស់ វិស័យកសិកម្មបានផ្តល់នូវអាហារដល់យើងបរិភោគរាល់ថ្ងៃ។ ជាពិសេសវិស័យកសិកម្មក៏បានជួយសម្រួលដល់ជីវភាពរបស់ប្រជាជនជាច្រើន និងជួយដល់សេដ្ឋកិច្ច

[9] https://www2.usgs.gov/faq/node/5601 (ចូលទស្សនាថ្ងៃទី២០ មេសា ឆ្នាំ២០១៦)។

របស់ប្រទេសនីមួយៗផងដែរ។ ក៏ប៉ុន្តែតើវាបានប៉ះពាល់ដល់ការឡើងកម្តៅផែនដីយ៉ាងណា។ ពាក់ព័ន្ធនឹងការបង្កនេះ មានមូលហេតុវិជ្ជមាន និងអវិជ្ជមានមួយចំនួនពាក់ព័ន្ធ។

ក្នុងនោះមូលហេតុដែលប៉ះពាល់ដោយវិជ្ជមាននោះគឺ ការបង្ខាំងឧស្ម័នកាបូនិចក្នុងដី។ ការបង្ខាំងកាបូនទុកក្នុងដីច្រើននឹងធ្វើឲ្យដីនោះអាចផ្ទុកជាតិទឹកបានច្រើន។

ចំនែកឯមូលហេតុអវិជ្ជមានដែលបង្កឲ្យមានការប្រែប្រួលអាកាសធាតុនោះគឺ ការឈានមកដល់នូវបរិមាណដ៏មហិមានៃឧស្ម័នកាបូនិច ក្នុងវិស័យកសិឧស្សាហកម្ម។ រាល់ផលិតកម្មទាំងអស់ក្នុងវិស័យនេះរួមមាន ការផលិត និងប្រើប្រាស់ជីសម្រាប់ដំណាំ ថ្នាំសម្លាប់សត្វល្អិត ប្រេងឥន្ទនៈ និងប្រេងសម្រាប់គ្រឿងចក្រដូចជាត្រាក់ទ័រ រថយន្តដឹកទំនិញ នាវា ការប្រើប្រាស់អគ្គីសនីដែលដើរដោយពន្លឺព្រះអាទិត្យ។ បើទោះជាផលិតកម្មទាំងអស់ នោះសុទ្ធតែមានប្រយោជន៍តែផលប៉ះពាល់ក៏មានដែរ។

#### ១.២.២.៤ ការបាត់បង់ព្រៃឈើ

មូលហេតុដ៏ធំបំផុតនៃការបាត់បង់ព្រៃឈើគឺ កាប់ព្រៃឈើដើម្បីយកដីទំនេរទៅប្រើប្រាស់ជាផលប្រយោជន៍ផ្សេងៗ ដែលវាមានលក្ខណៈស្រដៀងនឹងចំនុចនៃការប្រែប្រួលការប្រើប្រាស់ដី។ គេសង្កេតឃើញថានៅពេលខ្វះជម្រក ពួកគេកាប់ព្រៃឈើ ដើម្បីវាតទីយកដីសង់លំនៅឋានសម្រាប់រស់នៅ យកដីធ្វើកសិកម្ម ឬកសិដ្ឋាន។ កាន់តែមានកំនើននៃប្រជាជន កាន់តែត្រូវការលំនៅឋានដែលធ្វើឲ្យត្រូវកាប់ព្រៃទាំងនោះ។ ម្យ៉ាងវិញទៀតក្នុងតម្រូវការចាំបាច់ប្រចាំថ្ងៃ តាំងពីបុរាណកាលយើងឃើញថាការប្រើប្រាស់ឈើមានប្រសិទ្ធិភាពខ្លាំងណាស់ សូម្បីតែការចំអិនអាហារក៏ត្រូវការកាប់ឈើ ដើម្បីធ្វើជាអុស ការសង់ផ្ទះជាលក្ខណៈគ្រួសារតូចៗជាដើម តែវាគ្រាន់ជាលក្ខណៈតូចតាចប៉ុណ្ណោះ។ តែបច្ចុប្បន្ន មនុស្សបានប្រើប្រាស់ឈើ ដោយកែច្នៃឈើជាសម្ភារៈប្រើប្រាស់នានាដូចជាសង្ហារឹមតុបតែងគេហដ្ឋានដែលទាមទារប្រភេទឈើប្រណីត ដោយឡែកឈើប្រណីតគឺកម្រមានណាស់ ព្រោះវាត្រូវចំណាយពេលយូរក្នុងការលូតលាស់ទម្រាំតែធំ។ ដោយការបាត់បង់ព្រៃឈើបានធ្វើឲ្យផែនដីជួបទុក្ខលំបាកយ៉ាងច្រើនដោយបាត់បង់ប្រភពដែលស្រូបទាញយកបរិមាណកាបូនក្នុងបរិយាកាស។

## ១.៣ ផលប៉ះពាល់ដែលកើតពីបម្រែបម្រួលអាកាសធាតុ

ដោយសារមូលហេតុមួយចំនួនខាងលើ បានបំផ្លិចបំផ្លាញប្រព័ន្ធការពារដ៏មាំនៃផែនដីរួមមានឥទ្ធិពលនៃឧស្ម័នផ្ទះកញ្ចក់ ស្រទាប់អូសូន។ ដែលវាបានធ្វើឲ្យកម្តៅនៃថាមពលព្រះអាទិត្យ

ចាំងមកផ្ទៃផែនដីសឹងតែទាំងអស់ ហើយវាបានធ្វើឲ្យរាល់ជីវិតនៅលើផែនដី ត្រូវជួបនឹងបញ្ហាជាច្រើន ជាពិសេសគឺការប្រែប្រួលនៃអាកាសធាតុ។ ហើយបច្ចុប្បន្ននេះ វាកំពុងតែជាបញ្ហាក្តៅគគុកមួយ ដែលពិភពលោកកំពុងជជែកដល់។ ដោយសារតែវាបានបង្កនូវផលអាក្រក់យ៉ាងច្រើនដល់ពិភពលោក ដូចជាការកើនឡើងនៃសីតុណ្ហភាព ការកើតឡើងនៃគ្រោះថ្នាក់ដែលបង្កដោយបាតុភូតធម្មជាតិ ក៏ដូចជាគ្រោះធម្មជាតិនានា ការកើនឡើងនៃកម្ពស់នីវ៉ូទឹកសមុទ្រ ការប៉ះពាល់ដល់សុខភាពមនុស្ស ការជះឥទ្ធិពលលើប្រព័ន្ធអេកូឡូស៊ី និងវិស័យកសិកម្ម។

### ១.៣.១ កំនើនសីតុណ្ហភាព

ផលនៃឧស្ម័នផ្ទះកញ្ចក់ បានធ្វើឲ្យបរិយាកាសផែនដីកាន់តែក្តៅខ្លាំងដែលវាបានបង្កឲ្យសីតុណ្ហភាពជាមធ្យមបានកើនឡើងទូទាំងពិភពលោក តែមិនមែនមានន័យថាវាឡើងកម្តៅគ្រប់កន្លែងនោះទេ។ ជាពិសេសនៅក្នុងសីតុណ្ហភាពក្តៅ វាបានបង្កឲ្យមានរំហួត និងបង្កជាភ្លៀងក៏ប៉ុន្តែមិនមែនមានន័យថាគ្រប់ទីកន្លែងមានលក្ខខណ្ឌអាកាសធាតុដូចគ្នានោះទេព្រោះកន្លែងខ្លះសើមកន្លែងខ្លះស្ងួត។ តែនៅក្នុងទសវត្សចុងក្រោយនេះ សីតុណ្ហភាពបានកើនឡើងយ៉ាងគួរឲ្យកត់សម្គាល់។ បច្ចុប្បន្ននេះ អ្នកវិទ្យាសាស្រ្តអាចដឹងថាសីតុណ្ហភាពនឹងកើនឡើងប៉ុណ្ណា តែគេមិនច្បាស់ទេថា វានឹងបន្តការកើនឡើងដល់ពេលណា និងកើនឡើងលឿនប៉ុណ្ណានោះទេ។ នេះក៏ព្រោះតែទង្វើរបស់មនុស្សបានបន្ថែមនូវឧស្ម័នក្នុងផលផ្ទះកញ្ចក់ និងការប្រើប្រាស់នូវចំហេះឥន្ធនៈ និងធ្យូងថ្ម។ កំនើនសីតុណ្ហភាព មានន័យថា រលកកម្តៅតែងតែកើតឡើងញឹកញាប់ជាងមុន និងមានរយៈពេលយូរជាងមុន។ រលកកម្តៅនេះអាចធ្វើឲ្យមានគ្រោះថ្នាក់ និងបង្កនូវជំងឺជាច្រើនដូចជា ជំងឺដាច់សសៃឈាមខួរក្បាលជាដើម ដែលអាចបណ្តាលឲ្យបាត់បង់ជីវិត។ ដោយឡែកការកើនឡើងនៃសីតុណ្ហភាពក៏បានជះឥទ្ធិពលដល់មហាសមុទ្រ លក្ខខណ្ឌអាកាសធាតុ ព្រិលនិងទឹកកក រុក្ខជាតិ និងសត្វពាហនៈ។[10]

### ១.៣.២ ការកើតឡើងនូវបាតុភូតធម្មជាតិ

ការប្រែប្រួលអាកាសធាតុក្នុងរូបភាពដូចជា ការកើនឡើងនៃកម្តៅកាន់ក្តៅខ្លាំង ការចុះត្រជាក់ខ្លាំង ភាពមិនទៀងទាត់នៃរបបទឹកភ្លៀង។ តាមរយៈនេះបានបង្កនូវគ្រោះធម្មជាតិមួយចំនួនដូចជា គ្រោះរាំងស្ងួត ព្យុះភ្លៀង ព្យុះព្រិល ទឹកជំនន់ ខ្យល់កន្រ្តាក់ រញ្ជួយដី រញ្ជួយដីក្រោមបាត

---

[10] https://www3.epa.gov/climatechange/kids/impacts/signs/temperature.html (ចូលទស្សនាថ្ងៃទី២១ មេសា ឆ្នាំ ២០១៦)។

សមុទ្រ រលកសមុទ្រ។ ដោយសារសីតុណ្ហភាពឡើងក្តៅ នាំឲ្យប្រភពទឹកសំខាន់ៗដូចជា ទន្លេ បឹង ស្ទឹង ព្រែក ត្រពាំងរីងស្ងួត ប្រជាពលរដ្ឋខ្វះទឹកប្រើប្រាស់ រុក្ខជាតិក៏មិនអាចរីកលូតលាស់បាន ផល ដំណាំក៏ខូចខាត។ ចំនែកឯការធ្លាក់ភ្លៀងមិនទៀងទាត់ គឺបង្កឲ្យរដូវវស្សាបែរជាគ្មានទឹកប្រើប្រាស់ ហើយបែរជាមានភ្លៀងធ្លាក់ខ្លាំងនៅចុងរដូវវស្សា ដែលបង្កនូវទឹកជំនន់ ដែលនាំឲ្យប្រជាពលរដ្ឋ ដែលរស់នៅក្បែរប្រភពទឹក លិចផ្ទះសម្បែង ស្រែចំការ ដំណាំខូចខ្ទេច។ មិនតែប៉ុណ្ណោះ នៅ ពេលដែលគ្មានព្រៃឈើ ក៏បង្កឲ្យមានព្យុះ ឬខ្យល់កន្ត្រាក់ដែលនាំឲ្យបក់រលំផ្ទះសម្បែងរបស់ប្រជា ពលរដ្ឋជាច្រើន និងអាចបណ្តាលឲ្យបាត់បង់ជីវិតទៀតផង។ សូម្បីតែករណីគ្រោះរញ្ជួយដី ក៏បង្កឲ្យ រលំផ្ទះអគារផ្សេងៗ បាក់សង្កត់មនុស្សស្លាប់ជាច្រើន។ មួយវិញទៀតរញ្ជួយដីក្រោមបាតសមុទ្របាន បង្កជារលកសមុទ្រធំៗកំពស់ច្រើនម៉ែត្រដែលបានសម្លាប់មនុស្ស សត្វ រុក្ខជាតិគ្រប់ប្រភេទទៀត ផង។

### ១.៣.៣ កំនើននីវ៉ូទឹកសមុទ្រ

ជាធម្មតានៅពេលទឹកឡើងកម្តៅធ្វើឲ្យវារីកមាឌ បើទោះជាតំនក់ទឹកនីមួយៗរីកក្នុងទំហំតូច ក្តីតែនៅពេលប្រមូលផ្តុំការរីកមាឌនៃម៉ូលេគុលទឹកនៅក្នុងមហាសមុទ្រ វាបានបង្កឲ្យមានការកើន ឡើងនៃកម្ពស់នីវ៉ូទឹកសមុទ្រ។[11] ដូចនេះ ប្រសិនបើមនុស្សនៅតែបន្តសកម្មភាពបន្ថែមឧស្ម័នផ្ទះ កញ្ចក់ទៅក្នុងបរិយាកាស កម្តៅក្នុងបរិយាកាសកាន់តែកើនឡើង ដុំទឹកកកនៅតំបន់អាកទិចកាន់តែ រលាយ កម្ពស់នីវ៉ូទឹកសមុទ្រនឹងកើនឡើងជាលំដាប់។ ការកើនឡើងនៃកម្ពស់នីវ៉ូទឹកសមុទ្របាន គំរាមកំហែងដល់ប្រជាពលរដ្ឋដែលរស់នៅក្បែរមាត់សមុទ្រ រីឯតំបន់ទំនាបនឹងជួបប្រទះនូវទឹក ជំនន់យ៉ាងញឹកញាប់ ហើយតំបន់ដែលទាបខ្លាំងនឹងលិចបាត់ក្នុងទឹក។ ចំពោះតំបន់ឆ្នេរសមុទ្រ បម្រែបម្រួលអាកាសធាតុក្នុងពិភពលោក បានគម្រាមកំហែងដល់ជីវិត និងសំណង់អគារនៅតំបន់ នោះ។ មានប្រជាជនជាច្រើននៅជុំវិញពិភពលោក រស់នៅក្នុងតំបន់ទំនាបឆ្នេរ ក៏ដូចជាតំបន់ដីកោះ នឹងទទួលរងនូវគ្រោះទឹកជំនន់ដោយសារកម្ពស់នីវ៉ូទឹកសមុទ្រកើនឡើង។ កម្តៅទឹកមហាសមុទ្រក៏ បានបង្កើតជាព្យុះនៅតំបន់សមុទ្រដូចគ្នា។[12]

[11] ដូចខាងលើ។

[12] ដូចខាងលើ។

### ១.៣.៤ ផលប៉ះពាល់លើសុខភាពមនុស្ស

ដោយសារតែការកើនឡើននៃសីតុណ្ហភាព និងការកើតឡើងនៃគ្រោះធម្មជាតិនានា បានបង្កឲ្យមានជំងឺផ្សេងៗ និងប៉ះពាល់យ៉ាងខ្លាំងដល់ទារក កុមារ មនុស្សចាស់ជរា ប្រជាជនក្រីក្រ ជាពិសេសគឺអ្នកដែលមានជំងឺស្រាប់ ប្រជាជនដែលរស់នៅតំបន់ឆ្នេរ និងជនបទដាច់ស្រយាល។ ចំពោះផលប៉ះពាល់នៃរលកកម្តៅដែលបណ្តាលឲ្យសីតុណ្ហភាពក្តៅគឺ ធ្វើឲ្យបង្កជំងឺដាច់សសៃឈាមខួរក្បាលជាដើម។

ចំនែកឯឧស្ម័នពុលក្នុងបរិយាកាស និងស្រទាប់អូសូនបានបង្កឲ្យប៉ះពាល់ដល់ផ្លូវដង្ហើមដូចជា ជំងឺហឺត ជំងឺផ្សេងៗដែលពាក់ព័ន្ធនឹងសួត។ ជាក់ស្តែងយើងឃើញថា ស្រទាប់អូសូនជាស្រទាប់នៅក្នុងបរិយាកាសដែលបានជួយការពារជីវិតនៅលើភពផែនដីពីកាំរស្មីអ៊ុលត្រាររបស់ព្រះអាទិត្យ ដែលនោះគឺជាស្រទាប់អូសូនល្អដែលស្ថិតក្នុងមណ្ឌលអាកាសស្ងប់(Stratosphere)។ ក៏ប៉ុន្តែស្រទាប់អូសូនអាក្រក់ត្រូវបានគេរកឃើញនៅក្នុងបរិយាកាសជាប់នឹងផ្ទៃផែនដី ដែលស្រទាប់នេះបានផ្សំឡើងពីផ្សេងអ័ព្ទដែលជាធាតុដ៏សំខាន់ និងឧស្ម័នពុលដែលបង្កក្នុងបរិយាកាស។ ការប្រែប្រួលអាកាសធាតុដោយសារតែការកើនឡើងនៃស្រទាប់អូសូនអាក្រក់ក្នុងបរិយាកាស បានធ្វើឲ្យមនុស្សពិបាកដកដង្ហើម។ ម៉្យាងវិញទៀត ការផ្លាស់ប្តូរអាកាសធាតុអាចបង្កឲ្យរីករាលដាលជំងឺឆ្លងមួយចំនួន។ ជាពិសេសនៅរដូវរងារអាចអនុញ្ញាតឲ្យសត្វមូស និងចៃរស់នៅបានយូរ និងបង្កកូនបង្កថៅបន្ថែម ដោយសារពួកវាធន់នឹងអាកាសធាតុត្រជាក់ ដែលបង្កឲ្យសុខភាពមនុស្សប្រថុយនឹងគ្រោះថ្នាក់។ ការព្រួយបារម្ភមួយទៀតគឺ ជំងឺគ្រុនចាញ់ ដែលអាចបណ្តាលឲ្យបាត់បង់ជីវិតមនុស្ស។

### ១.៣.៥ ការជះឥទ្ធិពលលើប្រព័ន្ធអេកូឡូស៊ី និងវិស័យកសិកម្ម

ព្រៃឈើមានលក្ខណៈជាប្រព័ន្ធអេកូឡូស៊ី ដែលមានឥទ្ធិពលលើគ្រប់ពូជអំបូរទាំងអស់លើភពផែនដី។ ប្រសិនបើត្រូវបានគេបំបែកប្រព័ន្ធនេះ វានឹងត្រូវបំផ្លាញខ្ទេចខ្ទីគ្រប់ទីកន្លែងទាំងអស់មិនថាក្នុងតំបន់ណាមួយទេ គឺវានឹងត្រូវបំផ្លាញជុំវិញពិភពលោក។

ការប្រែប្រួលអាកាសធាតុបានបង្កផលវិបាកដល់វិស័យកសិកម្មយ៉ាងធ្ងន់ធ្ងរ តាមរយៈសកម្មភាពរបស់ធម្មជាតិខ្លួនឯង និងសកម្មភាពរបស់មនុស្ស។ សម្រាប់ការបាត់បង់ព្រៃឈើ ចម្រោះដីជាកត្តាចម្បង ដោយសារតែរឹសរបស់ដើមឈើបានចាក់គ្រឹះទៅក្នុងដី។ ប្រសិនបើគ្មានដើមឈើទេ ដីងាយនឹងបន្សាត់ចេញពីទីតាំងរបស់វាតាមរយៈទឹកភ្លៀង។ ជាពិសេសនៅតាមមាត់អូរ ព្រែក ស្ទឹង ឬទន្លេ ប្រសិនបើមិនមានដើមឈើនៅតាមមាត់ច្រាំងទេនោះ នឹងនាំឲ្យមានបញ្ហាបាក់ដីជាដើម។

ម្យ៉ាងវិញទៀត បញ្ហាអាកាសធាតុបានបង្កផលប៉ះពាល់ដល់ការធ្វើកសិកម្មរបស់ប្រជាពលរដ្ឋ ក៏ដូចជាផលដំណាំរបស់ពួកគេ។ ចំពោះការធ្វើកសិកម្មក្នុងប្រទេសកម្ពុជាវិញ ភាគច្រើនគឺធ្វើតាមលក្ខណៈធុនតូច មានលក្ខណៈគ្រួសារ ដូចនេះការធ្វើស្រែចំការក៏អាស្រ័យនឹងទឹកភ្លៀង។ បែបនេះប្រសិនបើអាកាសធាតុប្រែប្រួល របបទឹកភ្លៀងប្រែប្រួល នោះការធ្វើកសិកម្មក៏ប្រែប្រួល ទិន្នផលនៃដំណាំក៏ប្រែប្រួល។ ដោយសារតែដំណាំទាំងនោះត្រូវការនូវសីតុណ្ហភាពសមរម្យ និងទឹកគ្រប់គ្រាន់ ដូចជារុក្ខជាតិខ្លះរស់បានក្នុងតំបន់ត្រជាក់ខ្លាំង រុក្ខជាតិខ្លះទៀតមិនអាចទ្រាំនឹងអាកាសធាតុត្រជាក់ខ្លាំងនោះទេ។ ដូចនេះ ប្រសិនបើគ្រួសារណាដែលមានជីវភាពពឹងផ្អែកទាំងស្រុងលើការធ្វើកសិកម្ម ជីវិតរបស់ពួកគេក៏ពឹងផ្អែកលើអាកាសធាតុដូចគ្នា។

## ១.៤ សកម្មភាពជាអន្តរជាតិពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ

### ១.៤.១ កិច្ចប្រជុំក្នុងអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)

ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៦០មក ការការពារបរិស្ថានបានក្លាយជាក្តីកង្វល់របស់ពិភពលោកដែលពេលនោះគេឃើញមានច្បាប់ និងគោលនយោបាយជាច្រើនកើតមានឡើងជាបន្តបន្ទាប់។ ស្របពេលនោះ រដ្ឋាភិបាលប្រទេសស៊ុយអែតបានស្នើសុំទៅអង្គការសហប្រជាជាតិឲ្យរៀបចំសន្និសីទជាអន្តរជាតិឡើង គឺសន្និសីទស្តីពីបរិស្ថានមនុស្ស (UN Conference on Human Environment)។[13] ពេលនោះមហាសន្និបាតអង្គការសហប្រជាជាតិបានចេញនូវសំណើ និងរៀបចំនូវសន្និសីទនេះឡើងនៅឆ្នាំ១៩៧២។[14]

ម្ភៃឆ្នាំក្រោយមក អង្គការសហប្រជាជាតិបានសម្រេចចិត្តរៀបចំសន្និសីទអន្តរជាតិលើកទី២ ស្តីពីបរិស្ថាន និងការអភិវឌ្ឍ(UN Conference on Environment and Development)។[15]សន្និសីទនេះបានប្រព្រឹត្តនៅទីក្រុងរីអូ ប្រទេសប្រេស៊ីលនៅឆ្នាំ១៩៩២។ សន្និសីទថ្មីមួយទៀតត្រូវបានបង្កើតឡើងនៅឯទីក្រុងចូហានីសប៊ើហ្គ ប្រទេសអាហ្វ្រិកខាងត្បូង នៅឆ្នាំ២០០២ គឺ១០ឆ្នាំក្រោយពីសន្និសីទលើកទី២។ វាជាកិច្ចប្រជុំពិភពលោកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព(World Summit on Sustainable Development)។[16]

---

[13] UNGA Res 2398 [XXIII] ថ្ងៃទី៣ ធ្នូ ១៩៦៨ ក្នុងកិច្ចប្រជុំ GAOR លើកទី២៣។

[14] ដូចខាងលើ។

[15] UNGA Res 44/228 ថ្ងៃទី២២ ធ្នូ ១៩៨៩ ក្នុងកិច្ចប្រជុំGAOR លើកទី៤៤។

[16] UNGA Res 55/199 [2000] ថ្ងៃទី២ កុម្ភៈ ២០០១។

### **១.៤.១.១ សន្និសីទរបស់អង្គការសហប្រជាជាតិស្តីពីបរិស្ថានមនុស្សឆ្នាំ១៩៧២ (សន្និសីទទីក្រុងស្តុកខូម)**

សន្និសីទរបស់អង្គការសហប្រជាជាតិស្តីពីបរិស្ថានមនុស្សដែលបានប្រព្រឹត្តធ្វើឡើងពីថ្ងៃទី៥ រហូតដល់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៧២ នៅទីក្រុងស្តុកខូម ប្រទេសស៊ុយអែត ដោយបានពិចារណាសម្រេចទៅលើភាពចាំបាច់នៃទស្សនៈវិស័យរួម និងគោលការណ៍រួមដើម្បីជម្រុញ និងណែនាំមនុស្សជាតិពីការអភិរក្ស និងការរីកចម្រើននៃបរិស្ថានមនុស្ស។[17] ក្នុងសន្និសីទនេះគេបានលើកឡើងនូវចំណុចសំខាន់ៗមួយចំនួនដូចជា[18]៖

- មនុស្សជាសភាវៈ និងជាអ្នកបំផ្លាញបរិស្ថានដែលទ្រទ្រង់រូបរាងកាយរបស់គេ ហើយតែងផ្តល់ឲ្យគេនូវឱកាសសម្រាប់ការបង្កើតចំណេះដឹង សីលធម៌ ការលូតលាស់ផ្នែកសង្គម និងស្មារតី។ នៅក្នុងបដិវត្តដ៏ស្មុគស្មាញ និងយូរអង្វែងរបស់មនុស្សជាតិ ជ័យជំនះគឺមាននៅពេលដែលមនុស្សទទួលបានអំណាចដើម្បីផ្លាស់ប្តូរបរិស្ថានរបស់គេតាមមធ្យោបាយអស្ចារ្យជាច្រើនរាប់មិនអស់ ដែលអាចធ្វើបានតាមផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមគឺមានសារៈសំខាន់ណាស់សម្រាប់ការរស់នៅរបស់គេនិងការទទួលបានសិទ្ធិជាមូលដ្ឋានរបស់គេ ជាពិសេសសិទ្ធិរស់រាន។
- ការការពារ និងការធ្វើឲ្យរីកចម្រើននូវបរិស្ថានមនុស្សគឺជាបញ្ហាចម្បងដែលជះឥទ្ធិពលដល់ការរស់នៅរបស់មនុស្ស ព្រមទាំងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងពិភពលោក។ វាជាបំណងរបស់មនុស្សលើពិភពលោក និងជាកាតព្វកិច្ចរបស់រដ្ឋាភិបាលទាំងអស់។
- មនុស្សតែងតែសរុបពីបទពិសោធន៍ដែលគេមាន ធ្វើការស្រាវជ្រាវ បង្កើតថ្មី ផលិត និងធ្វើអ្វីដែលមានភាពរីកចម្រើន។ ប្រសិនបើប្រើប្រាស់ប្រកបដោយភាពវៃឆ្លាត សមត្ថភាពរបស់មនុស្សក្នុងការកែប្រែមជ្ឈដ្ឋានជុំវិញ អាចនាំមកឲ្យមនុស្សនូវផលប្រយោជន៍ជាច្រើនពាក់ព័ន្ធនឹងការអភិវឌ្ឍ និងកាលានុវត្តភាពដើម្បីពង្រឹងគុណភាពនៃជីវិត។

ផ្ទុយទៅវិញបើមនុស្សប្រើប្រាស់ភាពវៃឆ្លាតរបស់គេក្នុងផ្លូវមិនល្អ សមត្ថភាពនេះនឹងនាំមកនូវផលអវិជ្ជមានដល់មនុស្ស និងបរិស្ថានមនុស្ស។ យើងបានឃើញនូវភស្តុតាងជាច្រើនដែលបង្ហាញពីផលអាក្រក់ដែលមនុស្សបង្កឡើងចំពោះតំបន់ជាច្រើនលើផែនដី ក្នុងនោះមានដូចជាការបំពុលទឹក ខ្យល់ ដី និងភាវៈមានជីវិត ការរំខានយ៉ាងខ្លាំងដល់លំនឹងអេកូឡូស៊ី ការបំផ្លាញនិងបន្ថយ

[17] http://www.unep.org/documents.multilingual/default.asp?documentid=97&articleid=1503 (ចូលទស្សនាថ្ងៃទី២១ មេសា ២០១៦)។

[18] ដូចខាងលើ។

នូវបរិមាណធនធានដែលមិនអាចជំនួសបានដូចជារ៉ែ ឧស្ម័នធម្មជាតិ រួមទាំងការចុះខ្សោយឬការបំផ្លាញដល់សុខភាពរាងកាយ បញ្ញា និងសង្គមរបស់មនុស្សជាពិសេសការរស់នៅនិងសង្គមការងារ។

- នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ បញ្ហាបរិស្ថានភាគច្រើនគឺបណ្តាលមកពីការអភិវឌ្ឍមិនគ្រប់គ្រាន់។ មានមនុស្សរាប់លាននាក់កំពុងរស់នៅក្នុងភាពក្រីក្រ ខ្វះខាតអ្វីដែលជាតម្រូវការចាំបាច់ដើម្បីរស់ ខ្វះខាតម្ហូបអាហារ សម្លៀកបំពាក់ ទីជម្រក ការអប់រំ សុខភាព និងអនាម័យ។ ដូច្នេះបណ្តាប្រទេសកំពុងអភិវឌ្ឍត្រូវតែខិតខំអភិវឌ្ឍប្រទេសរបស់ខ្លួន ដោយស្របពេលជាមួយគ្នាផ្តោតទៅលើកម្មវត្ថុជាអាទិភាព និងតម្រូវការចាំបាច់ដើម្បីការពារ និងធ្វើឲ្យបរិស្ថានប្រសើរឡើង។ ក្នុងគោលបំណងដូចគ្នាដែរ បណ្តាប្រទេសដែលមានឧស្សាហកម្មរីកចម្រើនគួរតែបង្កើនកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយគម្លាតជាមួយប្រទេសកំពុងអភិវឌ្ឍ។ ក្នុងបណ្តាប្រទេសអភិវឌ្ឍ បញ្ហាបរិស្ថានភាគច្រើនគឺពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យឧស្សាហកម្ម និងបច្ចេកវិទ្យា។
- កំណើនប្រជាជន គឺជាបញ្ហាប្រឈមសម្រាប់ការការពារបរិស្ថាន។ គោលនយោបាយ និងនីតិវិធីសមស្របត្រូវតែបង្កើតឡើងតាមភាពចាំបាច់ដើម្បីដោះស្រាយបញ្ហានេះ។ មនុស្សគឺជាអ្នកដែលអាចជំរុញឲ្យមានដំណើរការសង្គម បង្កើតធនធានសង្គម អភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ហើយតាមរយៈការខិតខំរបស់គេ គេក៏អាចកែប្រែបរិស្ថានមនុស្សបានដែរ។ ស្របគ្នាជាមួយដំណើរការសង្គម និងភាពរីកចម្រើននៃផលិតផល វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សមត្ថភាពរបស់មនុស្សក្នុងការធ្វើឲ្យបរិស្ថានរីកចម្រើនគឺកាន់តែមានភាពល្អប្រសើរឡើង។
- នេះជាដំណាក់កាលមួយដែលមនុស្សត្រូវតែកែប្រែសកម្មភាពរបស់ខ្លួន ដោយគិតដល់សារៈសំខាន់របស់បរិស្ថាន។ បើយើងមិនខ្វាយខ្វល់ ឬមិនធ្វើសកម្មភាពទេ បរិស្ថាននៅលើភពផែនដីដែលយើងរស់នៅនឹងពឹងផ្អែក អាចនឹងត្រូវបំផ្លាញ។ ប៉ុន្តែប្រសិនបើយើងធ្វើសកម្មភាពប្រកបដោយគតិបណ្ឌិត យើងអាចទទួលបាននូវជីវិតដ៏ល្អប្រសើរក្នុងបរិស្ថានដែលមានតម្រូវការនិងក្តីសង្ឃឹមរបស់មនុស្ស។ មានការយល់ឃើញជាច្រើនពីការធ្វើឲ្យប្រសើរឡើងនូវគុណភាពបរិស្ថាន និងការបង្កើតនូវជីវិតដ៏ល្អប្រសើរ។ អ្វីដែលយើងត្រូវការគឺការធ្វើសកម្មភាពដោយយកចិត្តទុកដាក់អត់ធ្មត់និងមានរបៀបរៀបរយ។ ដើម្បីទទួលបានសេរីភាពនៅក្នុងធម្មជាតិ មនុស្សត្រូវប្រើចំណេះដឹងរបស់ខ្លួនបង្កើតឲ្យមានបរិស្ថានដ៏ល្អប្រសើរមួយ។ ការការពារ និងធ្វើឲ្យរីកចម្រើននូវបរិស្ថានមនុស្សសម្រាប់ពេលបច្ចុប្បន្ន និងអនាគត គឺជាគោលបំណងដ៏សំខាន់បំផុតសម្រាប់មនុស្សដែលត្រូវធ្វើ ហើយក៏ជាគោលបំណងសំខាន់សម្រាប់សុខសន្តិភាព និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាសកល។

- ដើម្បីសម្រេចឲ្យបាននូវគោលបំណងនេះ វាទាមទារឲ្យមានការទទួលស្គាល់ការទទួលខុសត្រូវពីប្រជាជន និងសហគមន៍ និងសហគ្រាស ស្ថាប័នគ្រប់ជាន់ថ្នាក់។ គ្រប់រូបវន្តបុគ្គល នីតិបុគ្គលត្រូវតែកែប្រែបរិស្ថានរបស់គេសម្រាប់ជំនាន់ក្រោយ។ រាជរដ្ឋាភិបាលត្រូវទទួលបន្ទុកលើគោលនយោបាយ និងសកម្មភាពបរិស្ថានក្នុងទឹកដីរបស់គេ។ ព្រមគ្នានោះដែរកិច្ចសហប្រតិបត្តិការជាអន្តរជាតិក៏ជាកត្តាសំខាន់ក្នុងការបង្កើនធនធានជួញជំរុញបណ្តាប្រទេសកំពុងអភិវឌ្ឍឲ្យមានលទ្ធភាពក្នុងការទទួលខុសត្រូវ។ ការកើនឡើងនូវបញ្ហាបរិស្ថាន ទាំងក្នុងតំបន់ ឬជាសកល នាំឲ្យគេត្រូវការជាចាំបាច់នូវការបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការអនុវត្តសកម្មភាពពីអង្គការអន្តរជាតិក្នុងគោលបំណងរួម។

សន្និសីទនេះបានកោះហៅរដ្ឋាភិបាល និងប្រជាជនទាំងអស់ឲ្យខិតខំប្រឹងប្រែងការពារ និងធ្វើឲ្យបរិស្ថានមនុស្សមានភាពល្អប្រសើរឡើងសម្រាប់ជាប្រយោជន៍ដល់មនុស្សនិងប្រទេសទាំងអស់។ សន្និសីទនេះបានលើកឡើងនូវគោលការណ៍មួយចំនួនក្នុងសេចក្តីប្រកាសដើម្បីផ្តល់ជាអនុសាសន៍ដល់រដ្ឋាភិបាលក្នុងការរៀបចំគោលនយោបាយរបស់ខ្លួន ហើយក៏ជាការណែនាំដល់មនុស្សពីការអភិរក្ស និងការធ្វើឲ្យប្រសើរឡើងនូវបរិស្ថានមនុស្សផងដែរ។ គោលការណ៍ទាំងនេះមានចំនួន ២៦ដែលមានសេចក្តីដូចខាងក្រោម៖

- **គោលការណ៍ទី១**ក្នុងសេចក្តីប្រកាសនេះគឺបានចែងពីទំនាក់ទំនងរវាងសិទ្ធិមនុស្ស និងបរិស្ថាន។ ក្នុងនោះដែរគេក៏បានបង្ហាញពីបញ្ហាសិទ្ធិមនុស្សជាអន្តរជាតិដូចជាការរើសអើងពូជសាសន៍ ការដាក់អាណានិគម ជាដើម។ គោលការណ៍នេះក៏បានលើកឡើងពីការធានាពីសេរីភាព សមភាព និងកម្រិតជីវភាពរស់នៅដែលការប្រើប្រាស់សិទ្ធិទាំងនេះត្រូវពឹងផ្អែកលើលក្ខខណ្ឌបរិស្ថាន ដោយមានន័យថាពេលដែលបរិស្ថានត្រូវបានបំផ្លាញ សិទ្ធិមនុស្សក៏នឹងមានផលប៉ះពាល់ដែរ។[19]
- **គោលការណ៍ទី២ដល់ទី៧**នៃសេចក្តីប្រកាសនេះបានចែងពីមូលដ្ឋានសម្រាប់ការការពារបរិស្ថាន និងផលប៉ះពាល់ដល់បរិស្ថាន។ គោលការណ៍ទាំងនេះបានចែងថាធនធានធម្មជាតិរបស់ពិភពលោក គឺមិនត្រឹមតែមានប្រេង រ៉ែប៉ុណ្ណោះទេ ប៉ុន្តែមានខ្យល់ ទឹក ផែនដី រុក្ខជាតិ និងសត្វ ព្រមទាំងប្រព័ន្ធអេកូឡូស៊ីផងដែរ។ ធនធានធម្មជាតិទាំងនេះគួរតែត្រូវបានការពារដើម្បីជាប្រយោជន៍សម្រាប់ពេលបច្ចុប្បន្ន និងជំនាន់ក្រោយ។[20] ធនធានកើតឡើងវិញត្រូវតែធានាឲ្យបាននូវសមត្ថភាពរបស់វាក្នុងការកើតឡើងវិញ ចំនែកឯធនធានដែលមិនអាចកើតឡើងវិញគួរតែត្រូវបានប្រើប្រាស់ឲ្យ

[19] មហាសន្និបាតអង្គការសហប្រជាជាតិ, *សន្និសីទអង្គការសហប្រជាជាតិស្តីពីបរិស្ថានមនុស្ស*, ថ្ងៃទី១៥ ធ្នូ១៩៧២, A/RES/2994, គោលការណ៍ទី១ នៃសេចក្តីប្រកាសទីក្រុងស្តុកខូម, http://www.refworld.org/docid/3b00f1c840.html។
[20] ដូចខាងលើ, គោលការណ៍ទី២ នៃសេចក្តីប្រកាសទីក្រុងស្តុកខូម។

បានត្រឹមត្រូវ។[21] សេចក្តីប្រកាសនេះក៏ផ្តោតទៅលើសារៈសំខាន់នៃការគ្រប់គ្រងធនធាន និងការការពារសត្វព្រៃ និងជម្រកសត្វ។[22] គោលការណ៍នេះបានស្នើឲ្យមានការបញ្ឈប់ការបង្កើតកាកសំណល់ពុល ឬសំណល់ណាដែលបរិស្ថានមិនអាចទទួលយកបាន និងការការពារសមុទ្រពីការបំពុល ។[23] គោលការណ៍ទី៧នៃសេចក្តីប្រកាសនេះ គឺជាគោលការណ៍ដែលចែងពីកាតព្វកិច្ចរបស់រដ្ឋដែលត្រូវចាត់វិធានការសមស្របនានាដើម្បីការពារសមុទ្រពីការបំពុល។

- **គោលការណ៍ទី៨ដល់ទី២០** នៃសេចក្តីប្រកាសនេះបានចែងពីមធ្យោបាយនានាដើម្បីការពារបរិស្ថាន និងទំនាក់ទំនងរវាងបរិស្ថាននិងសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម។ គេបានចែងថាការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមមានសារៈសំខាន់ណាស់ដើម្បីធានាបរិស្ថានរស់នៅ និង ការងាររបស់មនុស្ស ព្រមទាំងបង្កើតលក្ខខណ្ឌចាំបាច់សម្រាប់ការបង្កើនគុណភាពនៃជីវិត។[24]គោលការណ៍ទី៩បានបញ្ជាក់ពីមធ្យោបាយជួយដល់ប្រទេសក្រីក្រ ពោលគឺការផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស។ គោលនយោបាយបរិស្ថានជាតិគួរតែជួយជម្រុញដំណើរការរបស់ប្រទេសក្រីក្រ ហើយពួកគេគួរតែទទួលបានជំនួយបន្ថែមពីអន្តរជាតិ។[25] គោលការណ៍ទី១០ដល់ទី១២ ផ្តោតទៅលើផលវិបាកនៃសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិទៅលើការការពារបរិស្ថាន។[26] គោលការណ៍ទី១៣ដល់ទី១៥ផ្តោតសំខាន់ទៅលើសារៈសំខាន់នៃសមាហរណកម្ម ការសម្របសម្រួល និងគម្រោងអភិវឌ្ឍដែលមានហេតុផលសមស្រប។[27] គោលការណ៍ទី១៦ បានចែងពីបញ្ហាអត្រានុកូលសាស្ត្រ ដែលអាចអនុវត្តបាននៅពេលដែលរដ្ឋាភិបាលគិតថាជាការចាំបាច់នៅពេលដែលមានកំណើនប្រជាជនច្រើន ឬនៅពេលដែលកំណើនប្រជាជនច្រើននាំឲ្យប៉ះពាល់ដល់បរិស្ថាននៃបរិស្ថានមនុស្សនិងរារាំងដល់ការអភិវឌ្ឍ។[28] ចំណែកឯគោលការណ៍ទី១៨ដល់ទី២០ លើកឡើងពីលិខិតូបករណ៍ផ្សេងៗស្តីពីគោលនយោបាយបរិស្ថាន ជម្រើសផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការផ្លាស់ប្តូរព័ត៌មាន ការបង្រៀននិងព័ត៌មានពីបញ្ហាបរិស្ថាន។
- **គោលការណ៍ទី២១ ដល់ទី២៦** គឺស្តីពីការអភិវឌ្ឍច្បាប់អន្តរជាតិ។ គោលការណ៍ទី២១ ត្រូវបានគេទទួលស្គាល់ថាជាវិធាននៃច្បាប់ទំនៀមទម្លាប់បរិស្ថានអន្តរជាតិ ដែលវាក៏ស្របតាមធម្មនុញ្ញ

[21] ដូចខាងលើ, គោលការណ៍ទី៣ ដល់ទី៥ នៃសេចក្តីប្រកាសទីក្រុងស្តុកខូម។
[22] ដូចខាងលើ, គោលការណ៍ទី៤ នៃសេចក្តីប្រកាសទីក្រុងស្តុកខូម។
[23] ដូចខាងលើ, គោលការណ៍ទី៦ នៃសេចក្តីប្រកាសទីក្រុងស្តុកខូម។
[24] ដូចខាងលើ, គោលការណ៍ទី៨ នៃសេចក្តីប្រកាសទីក្រុងស្តុកខូម។
[25] ដូចខាងលើ, គោលការណ៍ទី៩ នៃសេចក្តីប្រកាសទីក្រុងស្តុកខូម។
[26] ដូចខាងលើ, គោលការណ៍ទី១០ ដល់ទី១២ នៃសេចក្តីប្រកាសទីក្រុងស្តុកខូម។
[27] ដូចខាងលើ, គោលការណ៍ទី១៣ ដល់ទី១៥ នៃសេចក្តីប្រកាសទីក្រុងស្តុកខូម។
[28] ដូចខាងលើ, គោលការណ៍ទី១៦ នៃសេចក្តីប្រកាសទីក្រុងស្តុកខូម។

របស់អង្គការសហប្រជាជាតិ និងគោលការណ៍នៃនីតិអន្តរជាតិស្តីពីបូរណភាពដែនដីពោលគឺសិទ្ធិក្នុងការទាញយកធនធានដែលខ្លួនមានស្របតាមគោលនយោបាយបរិស្ថានរបស់ខ្លួន និងទទួលខុសត្រូវថាសកម្មភាពដែលធ្វើឡើងក្នុងដែនដីអធិបតេយ្យរបស់ខ្លួនគឺមិនប៉ះពាល់ដល់បរិស្ថានរបស់រដ្ឋផ្សេង ឬតំបន់ដែលមិនស្ថិតក្នុងអធិបតេយ្យភាពរបស់ខ្លួន។ សេចក្តីប្រកាសនេះក៏បានបន្ថែមថារដ្ឋគួរតែសហការណ៍ដើម្បីអភិវឌ្ឍច្បាប់អន្តរជាតិពាក់ព័ន្ធនឹងការទទួលខុសត្រូវ និងសំណងព្យសនកម្មចំពោះជនរងគ្រោះដោយសារការបំពុល និងផលប៉ះពាល់បរិស្ថានផ្សេងៗដែលកើតឡើងនៅក្រៅទឹកដីរបស់គេ។[29] រដ្ឋត្រូវថែងពីលក្ខណៈវិនិច្ឆ័យ និងវិធាននានាពីបញ្ហាបរិស្ថានតាមប្រទេសរៀងៗខ្លួន។[30] ហើយរដ្ឋត្រូវសហការដើម្បីការពារ និងធ្វើឲ្យបរិស្ថានមានភាពប្រសើរឡើង និងធានាថាអង្គការអន្តរជាតិដើរតើក្នុងការសម្របសម្រួល ប្រកបដោយប្រសិទ្ធិភាពនិងសកម្មនៅក្នុងបញ្ហានេះ។[31] ចំណែកគោលការណ៍ចុងក្រោយគឺជាការហាមឃាត់អាវុធនុយក្លេអ៊ែ និងមធ្យោបាយនានាដែលនាំឲ្យមានការបំផ្លាញទ្រង់ទ្រាយធំ។[32]

សេចក្តីប្រកាសស្តុកខូមមិនត្រូវបានអនុម័តឲ្យទៅជាសន្ធិសញ្ញាទេ ហើយវាក៏គ្មានចំណងគតិយុត្តដែរ តែទោះជាយ៉ាងណាវាក៏មានសារៈសំខាន់ផ្នែកច្បាប់ផងដែរ។[33] សន្និសីទនេះធ្វើឲ្យមាននូវសកម្មភាពអន្តរជាតិជាច្រើនដើម្បីការពារបរិស្ថាន ដែលនាំឲ្យប្រធានបទស្តីពីបរិស្ថានកើតមានក្នុងរបៀបវារៈអន្តរជាតិជាលើកដំបូង។ ការសម្រេចចិត្តបង្កើតសន្និសីទនេះឡើងជាការសម្រេចចិត្តមួយដែលធ្វើឲ្យអង្គការអន្តររដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល រួមទាំងរដ្ឋាភិបាលផងចាប់ផ្តើមធ្វើសកម្មភាពដើម្បីបរិស្ថាន។[34]

---

29 ដូចខាងលើ, គោលការណ៍ទី២២ នៃសេចក្តីប្រកាសទីក្រុងស្តុកខូម។

30 ដូចខាងលើ, គោលការណ៍ទី២៣ នៃសេចក្តីប្រកាសទីក្រុងស្តុកខូម។

31 ដូចខាងលើ, គោលការណ៍ទី២៤ និងទី២៥ នៃសេចក្តីប្រកាសទីក្រុងស្តុកខូម។

32 ដូចខាងលើ, គោលការណ៍ទី២៦ នៃសេចក្តីប្រកាសទីក្រុងស្តុកខូម។

33 Max Planck. "Stockholm Declaration (1972) and Rio Declaration (1992)" [សេចក្តីប្រកាសទីក្រុងស្តុកខូម (១៩៧២) និងសេចក្តីប្រកាសទីក្រុងរីអ៊ូ (១៩៩២)]. *Oxford Public International Law* (កក្កដា ២០០៨) , http://opil.ouplaw.com, (ចូលទស្សនាថ្ងៃទី២៣ មេសា ២០១៦)។ [តទៅនេះហៅថា Max Planck. សេចក្តីប្រកាសទីក្រុងស្តុកខូម (១៩៧២) និងសេចក្តីប្រកាសទីក្រុងរីអ៊ូ (១៩៩២)]។

34 ដូចខាងលើ។

### ១.៤.១.២ សន្និសីទរបស់អង្គការសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍឆ្នាំ១៩៩២ (**សន្និសីទទីក្រុងរីអូ ឬ** UNCED **ឬ** the Earth Summit)

សន្និសីទទីក្រុងរីអូស្តីពីបរិស្ថាន និងការអភិវឌ្ឍបានធ្វើឡើងចាប់ពីថ្ងៃទី៣ដល់ថ្ងៃទី១៤មិថុនា ឆ្នាំ១៩៩២ ដោយមានការចូលរួមពីតំណាងប្រទេស១៧៨។ អង្គការសហប្រជាជាតិបានទទួលស្គាល់នូវបញ្ហាបរិស្ថានធំៗចំនួន៩ ដែលរួមមាន៖ ការការពារបរិយាកាស ការការពារទឹក ការការពារបរិស្ថានសមុទ្រ ធនធានលើដី ជីវសាស្ត្រចម្រុះ ការគ្រប់គ្រងជីវបច្ចេកទេសនិងកាកសំណល់ ការធ្វើឲ្យប្រសើរឡើងនូវបរិស្ថានរស់នៅ និងការងារ ការការពារសុខមាលភាពមនុស្ស និងការបង្កើនគុណភាពជីវិត។[35]

សេចក្តីប្រកាសទីក្រុងរីអូស្តីពីបរិស្ថាន និងការអភិវឌ្ឍ ដែលរួមមាន ២៧ គោលការណ៍មានលក្ខណៈជាការរួមបញ្ចូល និងជាការសម្របសម្រួលដោយសារតែប្រទេសទាំងអស់ដែលចូលរួមមានគោលបំណង និងចំណុចអាទិភាពផ្សេងៗគ្នា។[36] លទ្ធផលនៃសន្និសីទនេះគឺតំណាងការព្រមព្រៀងរវាងចំណុចអាទិភាព និងផលប្រយោជន៍របស់បណ្តាកំពុងអភិវឌ្ឍ និងបណ្តាប្រទេសអភិវឌ្ឍ។ ដោយសារតែចំនួនប្រទេសចូលរួម សន្និសីទត្រូវបានគេចាត់ទុកជា តំណាងការព្រមព្រៀងគ្នាទៅលើបញ្ហាបរិស្ថាន និងការអភិវឌ្ឍ។ លទ្ធផលដែលបានលើកឡើងនេះគឺជាឯកសារពីគោលការណ៍មួយចំនួនឆ្លើយតបទៅនឹងសេចក្តីថ្លែងលើវិធានដែលបានចែងពីបញ្ហាបរិស្ថានរួមរបស់ប្រទេសនានា និងគោលការណ៍ផ្សេងទៀតដែលបានចែងពីគោលការណ៍ច្បាប់ថ្មីៗពាក់ព័ន្ធនឹងបរិស្ថាន និងការអភិវឌ្ឍ។ គោលការណ៍សំខាន់បំផុតរបស់សេចក្តីប្រកាសទីក្រុងរីអូ គឺការអភិវឌ្ឍប្រកបដោយចីរភាព ដូចមានចែងក្នុងរបាយការណ៍ប្រាដលេនដ៍ (Brundtland Report)។ ការអភិវឌ្ឍប្រកបដោយចីរភាពត្រូវបានឲ្យនិយមន័យថាជាការអភិវឌ្ឍដែលបំពេញតម្រូវការក្នុងពេលបច្ចុប្បន្នដោយមិនប៉ះពាល់ដល់សមត្ថភាពរបស់ជំនាន់ក្រោយក្នុងការបំពេញតម្រូវការរបស់គេ។[37] វាមានគោលគំនិតសំខាន់ៗ២យ៉ាងគឺ៖

- គោលគំនិតពីតម្រូវការ៖ ផ្តោតទៅលើតម្រូវការសំខាន់របស់ប្រទេសក្រីក្រដែលតម្រូវការជាអាទិភាពរបស់គេគួរតែត្រូវបានផ្តល់ឲ្យ។

[35] មហាសន្និបាតអង្គការសហប្រជាជាតិ, *សន្និសីទអង្គការសហប្រជាជាតិស្តីពីបរិស្ថាននិងការអភិវឌ្ឍ*, ថ្ងៃទី១៤ មិថុនា ១៩៩២, A/CONF. 151/26, Vol. I, សេចក្តីប្រកាសទីក្រុងរីអូ។[តទៅនេះហៅថា *សេចក្តីប្រកាសទីក្រុងរីអូ*]

[36] Max Planck. សេចក្តីប្រកាសទីក្រុងស្តុកខូម (១៩៧២) និងសេចក្តីប្រកាសទីក្រុងរីអូ (១៩៩២), កថាខណ្ឌទី៣៣។

[37] គណៈកម្មាការពិភពលោកស្តីពីបរិស្ថាន និងការអភិវឌ្ឍ, *Our Common Future ["The Brundtland Report"] [អនាគតរួមយើងទាំងអស់គ្នា, របាយការណ៍ប្រាដលេនដ៍]*, ១៩៨៧, ៤៣–៤៦, ៣៦៤–៦៦។

- គោលគំនិតស្តីពីដែនកំណត់នៃការអនុវត្តបច្ចេកវិទ្យារបស់រដ្ឋ និងអង្គការសង្គមពាក់ព័ន្ធនឹងលទ្ធភាពរបស់បរិស្ថានក្នុងការបំពេញសេចក្តីត្រូវការនាពេលបច្ចុប្បន្ននឹងអនាគត។

ការផ្តោតសំខាន់ថ្មីគឺមាននៅក្នុងគោលការណ៍ទី២នៃសេចក្តីប្រកាសទីក្រុងរីអូ ដែលជាការលើកឡើងពីគោលការណ៍ទី២១នៃសេចក្តីប្រកាសទីក្រុងស្តុកខូមដែលចែងពីតុល្យភាពរវាងអធិបតេយ្យភាពទឹកដីនឹងករណីយកិច្ចរបស់រដ្ឋក្នុងការការពារផលប៉ះពាល់បរិស្ថានរវាងប្រទេសនឹងប្រទេស។ ប៉ុន្តែគោលការណ៍នេះបន្ថែមពាក្យអភិវឌ្ឍដោយលើកឡើងថារដ្ឋមានសិទ្ធិក្នុងការទាញយកធនធានរបស់គេស្របតាមគោលនយោបាយអភិវឌ្ឍ និងបរិស្ថាន។ គោលការណ៍ទី៣ ផ្តោតទៅលើសិទ្ធិក្នុងការអភិវឌ្ឍ ហើយគោលការណ៍ទី៤ បញ្ជាក់ពីការការពារបរិស្ថានដែលត្រូវគេចាត់ទុកជាផ្នែកសំខាន់នៃដំណើរការអភិវឌ្ឍដែលមិនអាចបោះបង់បានដើម្បីធានាឲ្យមាននូវការអភិវឌ្ឍប្រកបដោយចីរភាព។ នៅក្នុងគោលការណ៍ទី៧ នៃសេចក្តីប្រកាស គេលើកឡើងពីការទទួលខុសត្រូវរួម តែខុសៗគ្នា។ ការទទួលខុសត្រូវខុសគ្នានេះសំដៅលើកត្តា២យ៉ាងគឺ ការទទួលខុសត្រូវលើការបង្កើតឲ្យមានបញ្ហាបរិស្ថាន និងសមត្ថភាពរបស់រដ្ឋក្នុងការលើកឡើង ឬដោះស្រាយនូវបញ្ហា។ គោលការណ៍ទី៨ បន្ថែមថារដ្ឋគួរតែកាត់បន្ថយនិងលុបបំបាត់ការផលិត និងការប្រើប្រាស់ផលិតផលដែលមិនមានលក្ខណៈស្ថិតស្ថេរ ព្រមគ្នាដែរវាក៏បានលើកឡើងពីការលើកកម្ពស់គោលនយោបាយអត្រានុកូលសាស្ត្រ។ ទោះជាវាមិនបានបញ្ជាក់យ៉ាងច្បាស់ ប៉ុន្តែផ្នែកដំបូងនៃគោលការណ៍នេះ គឺសំដៅលើប្រទេសអភិវឌ្ឍ ហើយផ្នែកខាងក្រោយសំដៅលើប្រទេសកំពុងអភិវឌ្ឍ។

សេចក្តីប្រកាសទីក្រុងរីអូនេះចែងថា "មនុស្សគឺស្ថិតនៅចំណុចសំខាន់នៃការអភិវឌ្ឍប្រកបដោយចីរភាព។ មនុស្សមានសិទ្ធិទទួលបានជីវិតដែលមានជាសុខភាព និងមានលទ្ធផលល្អប្រសើរនៅក្នុងភាពសុខដុមជាមួយធម្មជាតិ។"[38] គោលការណ៍នេះ បង្វែរសកម្មភាពពីការការពារបរិស្ថាន មកជាការការពារបរិស្ថាននៅក្នុងបរិបទនៃការអភិវឌ្ឍសេដ្ឋកិច្ចដោយភ្ជាប់មកជាមួយការគិតគូរលើសមភាពនៃតម្រូវការបច្ចុប្បន្ន និងអនាគត។[39] គោលការណ៍ទី១០ គឺស្តីពីកាតព្វកិច្ចរបស់រដ្ឋក្នុងការផ្តល់នូវព័ត៌មានជាសាធារណៈ ការចូលរួម និងការទទួលបានយុត្តិធម៌។[40] គោលការណ៍ទី១១ បានចែងផ្តោតលើសារៈសំខាន់នៃការអនុម័តច្បាប់នានាស្តីពីបញ្ហាបរិស្ថានប្រកបដោយប្រសិទ្ធិភាព។[41] គោលការណ៍ទី១៣ បានស្នើឲ្យមានការអភិវឌ្ឍនូវវិធាននៃការទទួលខុសត្រូវ។[42] គោល

[38] *សេចក្តីប្រកាសទីក្រុងរីអូ*, គោលការណ៍ទី១ នៃសេចក្តីប្រកាសទីក្រុងរីអូ។
[39] ដូចខាងលើ, គោលការណ៍ទី៣, ៥, ៧, ១១ នៃសេចក្តីប្រកាសទីក្រុងរីអូ។
[40] ដូចខាងលើ, គោលការណ៍ទី១០ នៃសេចក្តីប្រកាសទីក្រុងរីអូ។
[41] ដូចខាងលើ, គោលការណ៍ទី១១ នៃសេចក្តីប្រកាសទីក្រុងរីអូ។
[42] ដូចខាងលើ, គោលការណ៍ទី១៣ នៃសេចក្តីប្រកាសទីក្រុងរីអូ។

ការណ៍ទី១៥ ជាទម្រង់គោលការណ៍ថ្មីៗដែលរួមមានគោលការណ៍ជូនដំណឹងជាមុន។[43] គោលការណ៍ទី១៦ គឺស្តីពីគោលការណ៍អ្នកបំពុលជាអ្នកបង់ (the 'polluter pays' principle) ដែលគោលការណ៍នេះទាមទារឲ្យមានការគិតគូរលើការខាតបង់បរិស្ថាន។[44] គោលការណ៍ទី១៧ បានចែងពីលក្ខខណ្ឌទូទៅនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។[45] គោលការណ៍ទី១៨ និង១៩ បានចែងពីកាតព្វកិច្ចក្នុងការជូនដំណឹងដល់បណ្តារដ្ឋផ្សេងៗពីស្ថានភាពចាំបាច់ និងគម្រោងដែលអាចប៉ះពាល់ដល់បរិស្ថាន។[46] គោលការណ៍មួយចំនួន ជាពិសេសគោលការណ៍ទី១៧ នៃសេចក្តីប្រកាសទីក្រុងរីអូស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបានទទួលស្គាល់ចាប់តាំងពីសន្និសីទនេះមក។ គោលការណ៍ផ្សេងទៀតមានលក្ខណៈជាការណែនាំទៅលើគោលនយោបាយ។ ឧទាហរណ៍ដូចមាននៅក្នុងគោលការណ៍ទី៣ដែលសំដៅកាត់បន្ថយភាពក្រីក្រ ឬគោលការណ៍ទី៦ ចែងពីភាពចាំបាច់សម្រាប់តម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍ។ គោលការណ៍ទី៩ ស្តីពីការពង្រឹងការកសាងសមត្ថភាពរបស់ជនជាតិភាគតិច ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពដោយបង្កើនការយល់ដឹងពីវិទ្យាសាស្ត្រ។ គោលការណ៍ទី១២ បានផ្សព្វផ្សាយពីប្រព័ន្ធសេដ្ឋកិច្ចបើក និងគាំទ្រ ហើយនិងការព្រមព្រៀងជាអន្តរជាតិ ការថ្កោលទោសនីតិវិធីធ្វើពាណិជ្ជកម្មដែលមានការរើសអើងរើសអើងឬការរឹតបន្តឹងលើពាណិជ្ជកម្មអន្តរជាតិ ព្រមទាំងសកម្មភាពជាឯកតោភាគីផងដែរ។ គោលការណ៍ទី១៤ រារាំងមិនឲ្យមានការផ្លាស់ប្តូរទីតាំងទៅរដ្ឋផ្សេងនូវសកម្មភាព និងសារធាតុដែលបង្កឲ្យមានការបំផ្លាញបរិស្ថានធ្ងន់ធ្ងរឬជះឥទ្ធិពលដល់សុខភាពមនុស្ស។ គោលការណ៍ទី២០ដល់ទី២២ ផ្តោតទៅលើសារៈសំខាន់នៃការចូលរួមរបស់ស្ត្រី យុវជន និងជនជាតិដើមភាគតិចក្នុងការការពារបរិស្ថាន។

ដូចគ្នានឹងសេចក្តីប្រកាសទីក្រុងស្តុកខូមដែរ សេចក្តីប្រកាសទីក្រុងរីអូ គ្មានចំណងគតិយុត្តិទេ។ សេចក្តីប្រកាសទីក្រុងរីអូនេះជាការលើកឡើងម្តងទៀតពីសេចក្តីប្រកាសទីក្រុងស្តុកខូម ដោយបញ្ចូលគោលការណ៍ច្បាប់បន្ថែមដែលគោលការណ៍ទាំងនោះមានក្នុងរយៈពេល២០ឆ្នាំនោះ។ ក្នុងកម្រិតអន្តរជាតិ សេចក្តីប្រកាសនេះគឺមានឥទ្ធិពលគួរឲ្យកត់សម្គាល់។ ជាលទ្ធផលនៃសន្និសីទនេះ រាល់សន្ធិសញ្ញាអន្តរជាតិដែលទាក់ទងនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ គេតែងតែបញ្ចូលការការពារបរិស្ថានជាគោលបំណងមួយរបស់រដ្ឋជាភាគី។[47] ក្រៅពីសេចក្តីប្រកាសទីក្រុងរីអូ សន្និសីទ

[43] ដូចខាងលើ, គោលការណ៍ទី១៥ នៃសេចក្តីប្រកាសទីក្រុងរីអូ។
[44] ដូចខាងលើ, គោលការណ៍ទី១៦ នៃសេចក្តីប្រកាសទីក្រុងរីអូ។
[45] ដូចខាងលើ, គោលការណ៍ទី១៧ នៃសេចក្តីប្រកាសទីក្រុងរីអូ។
[46] ដូចខាងលើ, គោលការណ៍ទី១៨ និង១៩ នៃសេចក្តីប្រកាសទីក្រុងរីអូ។
[47] Max Planck. សេចក្តីប្រកាសទីក្រុងស្តុកខូម (១៩៧២) និងសេចក្តីប្រកាសទីក្រុងរីអូ (១៩៩២), កថាខណ្ឌទី៥។

នេះនាំឲ្យមានកិច្ចព្រមព្រៀងទៀតដែលមានអានុភាពផ្លូវច្បាប់គឺ អនុសញ្ញាស្តីពីជីវៈចម្រុះ និង ក្របខ័ណ្ឌសន្ធិសញ្ញាស្តីពីបម្រែបម្រួលអាកាសធាតុ។

**១.៤.១.៣ កិច្ចប្រជុំកំពូលពិភពលោកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ ២០០២** ( WSSD **ឬ** the Johannesburg Summit )

កិច្ចប្រជុំស្តីពីការអភិវឌ្ឍប្រកបដោយចីរភាពត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី២៦ ខែសីហាដល់ ថ្ងៃទី៤ ខែកញ្ញាឆ្នាំ២០០២ ក្នុងទីក្រុងចូហានីសបឺហ្គ ប្រទេសអាហ្វ្រិកខាងត្បូង។ ក្នុងកិច្ចប្រជុំនេះ ការអភិវឌ្ឍប្រកបដោយចីរភាពត្រូវបានលើកឡើងម្តងទៀតជាប្រធានបទសំខាន់សម្រាប់របៀបវារៈ ប្រជុំ។ នៅក្នុងកិច្ចប្រជុំនេះ រដ្ឋទាំងឡាយបានធ្វើការតាំងចិត្តដោយធានាថា ធនធានជីវៈចម្រុះដែល យើងមាននឹងត្រូវបានប្រើប្រាស់ដើម្បីផ្លាស់ប្តូរ និងដើម្បីសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍ ប្រកបដោយចីរភាព។ ដោយទទួលស្គាល់ពីសារៈសំខាន់នៃការកសាងសាមគ្គីភាពរបស់មនុស្ស រដ្ឋ ទាំងឡាយនឹងជម្រុញឲ្យមានការពិភាក្សា និងការសហប្រតិបត្តិការរវាងប្រជាជាតិទូទាំងពិភពលោក ដោយគ្មានការរើសអើង។ រដ្ឋទាំងនោះបានឯកភាពលើកិច្ចប្រជុំនេះដែលផ្តោតទៅលើសេចក្តីថ្លៃថ្នូរ របស់មនុស្សដែលមិនអាចកាត់ផ្តាច់បាន និងការបង្កើនលទ្ធភាពរបស់មនុស្សក្នុងការទទួលបានទឹក ស្អាត អនាម័យ ទីជម្រក ថាមពល ការថែទាំសុខភាព សន្តិសុខ និងការការពារជីវៈចម្រុះ។ រដ្ឋផ្សេងៗ ក៏ប្តេជ្ញាធ្វើការជាមួយគ្នាដើម្បីជួយឲ្យគេទទួលបានហិរញ្ញវត្ថុ ផលប្រយោជន៍ពីការបើកទីផ្សារ ធានា ការកសាងសមត្ថភាព ការប្រើប្រាស់បច្ចេកវិទ្យាទំនើបដើម្បីនាំមកនូវការអភិវឌ្ឍ និងធានាឲ្យមាន ការផ្លាស់ប្តូរបច្ចេកវិទ្យា ការអភិវឌ្ឍធនធានមនុស្ស ការអប់រំ និងការបណ្តុះបណ្តាលដើម្បីលុបបំបាត់ ភាពក្រីក្រ។[48] កិច្ចប្រជុំកំពូលនេះក៏បានទទួលស្គាល់ពីសារៈសំខាន់របស់ជនជាតិដើមភាគតិចក្នុង ការអភិវឌ្ឍប្រកបដោយចីរភាពផងដែរ។[49]

**១.៤.២ កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ** United Nations Environment Programme ( UNEP )

កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិគឺជាអ្នកមានសមត្ថកិច្ចផ្នែកបរិស្ថាននាំមុខគេក្នុង អន្តរជាតិដែលទទួលបន្ទុករៀបចំរបៀបវារៈបរិស្ថានអន្តរជាតិ ផ្សព្វផ្សាយការអនុវត្តជាបន្តបន្ទាប់ស្តីពី

[48] *កិច្ចប្រជុំកំពូលពិភពលោកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព,* ថ្ងៃទី៤ កញ្ញា ២០០២, សេចក្តីប្រកាសទីក្រុងចូហានីស បឺហ្គ។

[49] ដូចខាងលើ។

ការវាស់វែងបរិស្ថាននៃការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ និងដើរតួជាសមត្ថកិច្ចគាំទ្របរិស្ថានពិភពលោក។[50]

កម្មវិធីនេះធ្វើសកម្មភាពដូចជា៖

- វាយតម្លៃទៅលើលក្ខខណ្ឌ និងនិន្នាការបរិស្ថានជាតិ តំបន់ និងពិភពលោក
- បង្កើតលិខិតូបករណ៍ជាតិ និងអន្តរជាតិស្តីពីបញ្ហាបរិស្ថាន
- ពង្រឹងសមត្ថភាពស្ថាប័នដើម្បីការគ្រប់គ្រងបរិស្ថានប្រកបដោយភាពត្រឹមត្រូវ

កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិនេះមានបេសកកម្មចម្បងក្នុងការផ្តល់ភាពជាអ្នកដឹកនាំនិងលើកទឹកចិត្តឲ្យមានដៃគូសហប្រតិបត្តិការក្នុងការយកចិត្តទុកដាក់លើបរិស្ថាន ដោយការជម្រុញ ការផ្តល់ព័ត៌មាន និងអនុញ្ញាតឲ្យរដ្ឋ និងប្រជាជនអាចបង្កើនគុណភាពជីវិតរបស់ពួកគេដោយមិនប៉ះពាល់ដល់ជំនាន់ក្រោយ។

កម្មវិធីនេះបានបង្កើតនូវអនុកម្មវិធីបម្រែបម្រួលអាកាសធាតុដែល គោលដៅចម្បងរបស់កម្មវិធីនេះមានដូចជា៖

- ការសម្របខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុ (Adapting)៖ កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិជួយប្រទេសទាំងឡាយកាត់បន្ថយការរងឥទ្ធិពល និងការប្រើប្រាស់សេវាប្រព័ន្ធអេកូឡូស៊ីដើម្បីកសាងរនាំងធម្មជាតិទប់ទល់នឹងឥទ្ធិពលនៃបម្រែបម្រួលអាកាសធាតុ។
- ការបញ្ជ្រាបបម្រែបម្រួលអាកាសធាតុ (Mitigating)៖ ការជួយជ្រោមជ្រែងប្រទេសទាំងឡាយក្នុងការបង្កើតគោលនយោបាយរឹងមាំ បច្ចេកវិទ្យា និងជម្រើសនៃការវិនិយោគ ដែលនាំឲ្យមានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។
- ការកាត់បន្ថយការបំភាយកាបូនពីការកាប់បំផ្លាញព្រៃឈើ (Reducing Emissions from Deforestation and Forest Degradation, REDD+)៖ កម្មវិធីនេះធ្វើការជាដៃគូសហប្រតិបត្តិការជាមួយកម្មវិធីអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ និងអង្គការស្បៀងអាហារ និងកសិកម្មក្នុងការគាំទ្រប្រទេសកំពុងអភិវឌ្ឍឲ្យកាត់បន្ថយការបញ្ចេញកាបូនពីការកាប់បំផ្លាញព្រៃឈើ តាមរយៈការគាំទ្រការអភិវឌ្ឍយុទ្ធសាស្ត្រកាត់បន្ថយការបំភាយកាបូបពីការកាប់បំផ្លាញព្រៃឈើ (REDD+)ជាដើម។
- បង្កើនចំណេះដឹង និងទំនាក់ទំនង៖ កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិធ្វើការដើម្បីបង្កើនចំណេះដឹងទាក់ទងនឹងបញ្ហាវិទ្យាសាស្ត្រនៃបម្រែបម្រួលអាកាសធាតុ និងលើកកម្ពស់ការយល់ដឹងពីឥទ្ធិពលនៃបម្រែបម្រួលអាកាសធាតុដល់អ្នកដែលធ្វើការសម្រេចចិត្ត និងអ្នកដទៃទៀត។[51]

[50] http://www.unep.org/About/ (ចូលទស្សនាថ្ងៃទី៥ ឧសភា ២០១៦)។

### ១.៤.៣ គោលដៅអភិវឌ្ឍសហសវត្សរ៍ និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ

#### ១.៤.៣.១ គោលដៅអភិវឌ្ឍសហសវត្សរ៍

ក្នុងឆ្នាំ២០០០ ប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលរបស់ប្រទេសជាច្រើនបានប្រជុំគ្នានៅទីស្នាក់ការរបស់អង្គការសហប្រជាជាតិក្នុងទីក្រុងញូយ៉ក។ គេបានបង្កើតគោលដៅអភិវឌ្ឍសហសវត្សរ៍ ដែលមានចំណុចជាច្រើននៅក្នុងនោះរួមមានទាំងការការពារបរិស្ថាន។ គេបានសម្រេចថារដ្ឋទាំងឡាយត្រូវខិតខំប្រឹងប្រែងដើម្បីជួយមនុស្សជាតិទូទៅពីការគម្រាមគំហែងនានាបង្កដោយសកម្មភាពមនុស្ស ហើយដែលវាជះឥទ្ធិពលដល់បរិមាណធនធានដែលពួកគេត្រូវការ។[52] រដ្ឋក៏បានគាំទ្រដល់គោលការណ៍នៃការអភិវឌ្ឍប្រកបដោយចីរភាពផងដែរ។[53] គេបានតាំងចិត្តថានឹងបង្កើតឲ្យមាននូវក្រមសីលធម៌ពីការអភិរក្សក្នុងគ្រប់សកម្មភាពបរិស្ថានទាំងអស់។ ការបង្កើតគោលដៅនេះឡើងបានជម្រុញឲ្យរដ្ឋខិតខំ និងធ្វើសកម្មភាពដើម្បីបរិស្ថានជាបន្តបន្ទាប់។

#### ១.៤.៣.២ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព

ចាប់ពីថ្ងៃទី២៥ ដល់ទី២៧ ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល និងអ្នកតំណាងជាន់ខ្ពស់មកពីប្រទេសផ្សេងៗ បានជួបប្រជុំគ្នានៅទីក្រុងញូយ៉កដែលជាទីស្នាក់ការរបស់អង្គការសហប្រជាជាតិ។ កិច្ចប្រជុំនេះបានសម្រេចបង្កើតគោលដៅអភិវឌ្ឍប្រកបដោយចីរភាពដែលនឹងត្រូវសម្រេចឲ្យបានក្នុងឆ្នាំ២០៣០។ ការអភិវឌ្ឍប្រកបដោយចីរភាពនេះត្រូវសម្រេចឲ្យបានក្នុងទិសដៅ៣សំខាន់ៗគឺ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ដែលធ្វើឡើងក្នុងលក្ខខណ្ឌតុល្យភាព និងរួមគ្នា។ ក្នុងគោលដៅទាំងនោះ មានគោលដៅមួយចំនួនបានលើកឡើងពីបញ្ហាពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ដូចជាគោលការណ៍ទី១៣ ស្តីពីការអនុវត្តសកម្មភាពភាពបន្ទាន់ដើម្បីទប់ស្កាត់នឹងបម្រែបម្រួលអាកាសធាតុ គោលការណ៍ទី១៥ ស្តីពីការការពារ ការស្តារ និងការលើលកម្ពស់ការប្រើប្រាស់ប្រកបដោយចីរភាពនៃប្រព័ន្ធអេកូឡូស៊ីនៅលើដី ការគ្រប់គ្រងព្រៃឈើឲ្យស្ថិតស្ថេរ ការទប់ទល់នឹងការកើតឡើងនៃវាលខ្សាច់ថ្មី និងបញ្ឈប់ និងកែប្រែការបំផ្លាញដី និងការបាត់បង់ជីវៈចម្រុះជាដើម។

---

[51] UNEP, *Climate Change Factsheet* (កក្កដា ២០១០), http://www.unep.org/climatechange/Introduction.aspx (ចូលទស្សនាថ្ងៃទី ៥ ឧសភា ២០១៦)។

[52] មហាសន្និបាតអង្គការសហប្រជាជាតិ, A/RES/55/2, កិច្ចប្រជុំលើកទី៥៥, សេចក្តីប្រកាសសហវត្សរបស់អង្គការសហប្រជាជាតិ។

[53] ដូចខាងលើ។

# ជំពូកទី២

# ក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិស្តីពី បញ្ហាបម្រែបម្រួលអាកាសធាតុ

# ជំពូកទី២ ក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិស្តីពីបញ្ហាបម្រែបម្រួលអាកាសធាតុ

ប្រទេសកម្ពុជាបានបង្កើតនូវកម្រងច្បាប់ជាច្រើនពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន ដែលក្នុងនោះរួមមានបញ្ហាបម្រែបម្រួលអាកាសធាតុ។ ការបង្កើតច្បាប់ទាំងនោះ គឺជាការឆ្លើយតបមួយទៅនឹងស្ថានភាពបរិស្ថានពិភពលោក និងស្របទៅតាមបរិបទគតិយុត្តអន្តរជាតិផងដែរ។

## ២.១ បទដ្ឋានគតិយុត្តជាតិពាក់ព័ន្ធនឹងបញ្ហាបម្រែបម្រួលអាកាសធាតុ

ដោយសារតែបញ្ហាបម្រែបម្រួលអាកាសធាតុ គឺជាបញ្ហាដ៏ក្តៅគគុកនាទសវត្សចុងក្រោយនេះ ហេតុនេះហើយរាជរដ្ឋាភិបាលកម្ពុជា ក៏ពុំបាននៅស្ងៀមដែរ។ តាមរយៈការបង្កើតឲ្យមានយន្តការនានា ក៏ដូចជាផែនការសកម្មភាព ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមឆ្នាំនីមួយៗ។ មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលក៏បានរៀបចំជាច្បាប់ ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីធានាដល់ការគ្រប់គ្រងធនធានធម្មជាតិ ជីវចម្រុះ ការគ្រប់គ្រងបឹងទន្លេសាប បរិស្ថានតំបន់ឆ្នេរសមុទ្រកម្ពុជា គុណភាពបរិស្ថាន សុខភាពមនុស្ស ការគ្រប់គ្រងកាកសំណល់សំរាម ប្រភពនៃសម្លេង។

### ២.១.១ ច្បាប់

ខាងក្រោមនេះ ជាបទបញ្ញត្តិដែលទាក់ទងនឹងវិស័យបរិស្ថាន ដែលពាក់ព័ន្ធនឹងបញ្ហាបម្រែបម្រួលអាកាសធាតុដូចមានចែងក្នុងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ២០១៦-២០១៨ របស់រាជរដ្ឋាភិបាលៈ

- ព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣
- ព្រះរាជក្រឹត្យស្តីពីការបង្កើតនិងគ្រប់គ្រងបបនីយជីវមណ្ឌលបឹងទន្លេសាប ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១
- ព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ ឆ្នាំ២០០៥
- ច្បាប់ស្តីពី ការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤
- ច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៤
- ច្បាប់ស្តីពី កិច្ចការពារបេតិកភណ្ឌវប្បធម៌ ឆ្នាំ១៩៩៦
- ច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦
- ច្បាប់ស្តីពី ការគ្រប់គ្រងឱសថ ឆ្នាំ១៩៩៦

- ច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា ឆ្នាំ២០០០
- ច្បាប់ស្តីពី អគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០០
- ច្បាប់ភូមិបាល (ឆ្នាំ១៩៩២ និងឆ្នាំ២០០១)
- ច្បាប់ស្តីពី ការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ឆ្នាំ២០០១
- ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១
- ច្បាប់ស្តីពី ជលផល ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០២
- ច្បាប់ស្តីពី ព្រៃឈើ ឆ្នាំ២០០២
- ច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ សិប្បកម្ម ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦
- ច្បាប់ស្តីពី ការគ្រប់គ្រងធនធានទឹកនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- ច្បាប់ស្តីពីសម្បទាន ខែមេសា ឆ្នាំ២០០៨
- ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពី ទេសចរណ៍ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩
- ច្បាប់ស្តីពី តំបន់ការពារធម្មជាតិ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨
- ច្បាប់ស្តីពីជីវសុវត្ថិភាព ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨។[54]

### ២.១.១.១ គោលបំណង

រាល់បទបញ្ញត្តិដែលបានរៀបចំឡើង សុទ្ធតែមានគោលដៅច្បាស់លាស់។ ដូចគ្នានេះដែរ រាល់បទបញ្ញត្តិខាងលើនេះ មានគោលបំណងច្បាស់លាស់ និងដូចៗគ្នាមានដូចតទៅៈ

- ការបង្កើតជាតំបន់ការពារធម្មជាតិ ដោយមានចែកជាតំបន់ឧទ្យានធម្មជាតិ ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ដែលទទួលរងនូវការប្រើប្រាស់ច្រើនយ៉ាង ហើយក៏មានកំនត់ថាប្រភេទតំបន់នោះ មានទីតាំងស្ថិតនៅឯណា មានទំហំប៉ុន្មានហិកតា
- ការពារ លើកកំពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋដោយធ្វើការទប់ស្កាត់ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុល
- វាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ធានាឲ្យមានការអភិរក្ស ការអភិវឌ្ឍ ការគ្រប់គ្រងនិងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តភាពនិងភាពស្ថិតស្ថេរនូវធនធានធម្មជាតិ

[54] *ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ២០១៦-២០១៨ របស់រាជរដ្ឋាភិបាល*, (រាជធានីភ្នំពេញៈ ក្រសួងបរិស្ថាន, ២០១៦), ៦២។

- លើកទឹកចិត្ត និងផ្តល់លទ្ធភាពឲ្យមានសាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បង្ក្រាបអំពើទាំងឡាយដែលបង្កផលប៉ះពាល់ដល់បរិស្ថាន
- ជំរុញឲ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព និងដើម្បីសម្រេចបាននូវការងារអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ដើម្បីគ្រប់គ្រង និងរក្សាការពារគុណភាពនៃបរិមាណធនធានទឹកក្នុងព្រះរាជាណាចក្រកម្ពុជា
- ការពារ និងលើកកម្ពស់ដល់កត្តាទាំងឡាយណាដែលនាំឲ្យមានការប្រែប្រួលអាកាសធាតុ
- រក្សាការបំភាយកាបូន ឲ្យនៅកម្រិតទាបឆ្ពោះទៅកាន់ការកសាងសង្គមដែលបញ្ចេញកាបូនតិច
- ដើម្បីបញ្ជ្រាប បន្ស៊ី បន្សាំ និងធ្វើឲ្យមានសុខដុមនីយកម្មរវាងគោលការណ៍អភិវឌ្ឍន៍បៃតង
- កាត់បន្ថយការកើនឡើងនៃឧស្ម័នផលផ្ទះកញ្ចក់បន្សុាំនឹងការប្រែប្រួលអាកាសធាតុ ដែលនាំឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវិតលើផែនដី
- ធានានូវការគ្រប់គ្រងព្រៃឈើទាំងអស់ មិនថាកើតដោយធម្មជាតិ ឬដោយដាំក្តីប្រកបដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គមសេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវចម្រុះ និងមរតកវប្បធម៌
- តាមរយៈការរក្សាការពារព្រៃឈើ គឺដើម្បីរក្សានូវតុល្យភាពនៃរបបអាកាសធាតុ
- ទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានទៅលើការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ដែលបណ្តាលមកពីការផលិត ការដឹកជញ្ជូន ការអភិវឌ្ឍ ការលើកដាក់ ការផ្ទេរ ការប្រើប្រាស់ ការស្តុកទុក និងការបញ្ចេញសារពាង្គកាយកែច្នៃរស់ ដែលបង្កើតឡើងដោយជីវបច្ចេកវិទ្យាទំនើប
- ធានាប្រសិទ្ធភាពនៃការអភិរក្ស និងការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តភាពព្រមទាំងយកចិត្តទុកដាក់ចំពោះហានិភ័យដល់សុខភាពមនុស្ស
- ធ្វើឲ្យមានតម្លាភាពក្នុងនីតិវិធីពិនិត្យ និងក្នុងការធ្វើសេចក្តីសម្រេចចំពោះសារពាង្គកាយរស់ និងសកម្មភាពទាំងឡាយ ដែលទាក់ទងនឹងផលិតផលកែច្នៃ
- លើកកម្ពស់ការយល់ដឹងអំពីជីវបច្ចេកវិទ្យាទំនើប សំដៅទប់ស្កាត់ហានិភ័យពីការប្រើប្រាស់ និងការបញ្ចេញនូវផលិតផលសាច់កែច្នៃរស់ទៅក្នុងបរិស្ថាន និងសុខភាពមនុស្ស
- គ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ការប្រើប្រាស់អណ្តូងរ៉ែ ព្រមទាំងរាល់សកម្មភាពទាំងឡាយដែលទាក់ទងនឹងប្រតិបត្តិការធនធានរ៉ែនៅព្រះរាជាណាចក្រកម្ពុជា

- គោលបំណងរួមគឺ រួមចំនែកក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់បរិស្ថាន។

### ២.១.២ លិខិតបទដ្ឋានក្រោមជាតិ

ក្រសួងបរិស្ថានក៏មានភារកិច្ចអនុវត្តនូវលិខិតបទដ្ឋានក្រោមច្បាប់ជាច្រើនដូចជា៖

- អនុក្រឹត្យលេខ២៧ អនក្រ បក ស្តីពីការត្រួតពិនិត្យការបំណុលទឹក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩
- អនុក្រឹត្យលេខ៣៦ អនក្រ បក ស្តីពីការគ្រប់គ្រងសំណល់រឹង ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៩
- អនុក្រឹត្យលេខ៤២ អនក្រ បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងសម្លេង ទឹក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០
- អនុក្រឹត្យលេខ៤៧ អនក្រ បក ស្តីការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូហ្សូន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៩៩
- អនុក្រឹត្យខេខ៧២ អនក្រ បក ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩
- ប្រកាសស្តីពីការប្រមូល និងដឹកជញ្ជូនសំណល់រឹងឧស្សាហាកម្មក្នុងរាជធានីភ្នំពេញ
- ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង នៅខេត្ត ក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា
- សេចក្តីណែនាំស្តីពីការគ្រប់គ្រងសំណល់រឹងតាមបណ្តារោងចក្រ សហគ្រាស និងក្រុមហ៊ុន
- សេចក្តីជូនដំណឹងស្តីពីការបញ្ឈប់ការលក់ ឬផ្តល់ និងការដុតសំណល់រឹងឧស្សាហាកម្ម។[55]

#### ២.១.២.១ គោលបំណង

លិខិតបទដ្ឋានគតិយុត្តទាំងអស់នេះ ក៏មានគោលបំណងច្បាស់លាស់ដូចជា៖

- មានការកំណត់ពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ
- មានការកំណត់ប្រភេទ និងទំហំគម្រោង សកម្មភាពដែលស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន ទាំងសាធារណៈ ដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

[55] *ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ២០១៦-២០១៨ របស់រាជរដ្ឋាភិបាល*, (រាជធានីភ្នំពេញ៖ ក្រសួងបរិស្ថាន, ២០១៦), ៦៣។

- បំផុសឲ្យមានការចូលរួមពីសាធារណៈជនក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិ យោបល់ មកធ្វើការពិចារណា ក្នុងកិច្ចដំណើរការអនុម័តគម្រោង
- មានវិសាលភាពអនុវត្ត និងចាត់វិធានការណ៍ចំពោះរាល់ប្រភពបំពុលចល័ត និងអចល័ត ទាំងឡាយដែលបង្កឲ្យមានការបំពុលខ្យល់ និងការរំខានដោយសំលេងនៅក្នុងបរិយាកាស
- មានការកំណត់ពីការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និង ប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និង ការអភិរក្សជីវៈចម្រុះ
- ហាមឃាត់រាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញ ចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់ និងបង្កឲ្យប៉ះពាល់ដល់បរិស្ថានយ៉ាងធ្ងន់ធ្ងរ
- បញ្ជៀសនូវរាល់សំណល់ ឬឧស្ម័នដែលបង្កឡើងដោយវិស័យឧស្សាហកម្ម ដែលនាំឲ្យមាន គ្រោះភ័យដល់បរិស្ថាន ក៏ដូចជាអាកាសធាតុ
- ទប់ស្កាត់នូវរាល់សកម្មភាពដែលបានបង្កឲ្យមានការបំផ្លិចបំផ្លាញស្រទាប់អូសូនក្នុង បរិយាកាស
- បញ្ឈប់នូវរាល់សកម្មភាព ដែលបានបង្កឲ្យមានការប្រែប្រួលអាកាសធាតុ

### ២.១.៣ ស្ថាប័នអនុវត្ត

ចំពោះបទបញ្ញត្តិខាងលើនេះ មានក្រសួងស្ថាប័នជាច្រើនមានភារកិច្ចអនុវត្តដូចជា៖

- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងរ៉ែ និងថាមពល
- អាជ្ញាធររាជធានី ខេត្ត
- ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- នាយកដ្ឋានប្រែប្រួលអាកាសធាតុ
- គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
- ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង

ស្ថាប័នខាងលើនេះ ជាស្ថាប័នតំណាងរាជរដ្ឋាភិបាលក្នុងការអនុវត្តនូវរាល់បទដ្ឋានគតិយុត្ត នានា និងវិធានការណ៍នានាក្នុងការធានានូវការការពារផលប៉ះពាល់ពាក់ព័ន្ធនឹងការប្រែប្រួល អាកាសធាតុ។ ក្នុងនោះអាជ្ញាធររាជធានី ខេត្ត សំដៅដល់រដ្ឋបាលសាលារាជធានី ខេត្ត រួមទាំងមន្ទីរ ពាក់ព័ន្ធនានា។

រីឯក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ បង្កើតឡើងដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយ ចីរភាព សំដៅធានាបាននូវតុល្យភាពរវាង សេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយ ក.ជ.អ.ច. មានគណៈកម្មាធិការប្រតិបត្តិមួយដែលមានរដ្ឋមន្ត្រីក្រសួង បរិស្ថានជាប្រធាន និងមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់ដំណើរការងារប្រចាំថ្ងៃ ហើយមានទីស្នាក់ការនៅក្រសួងបរិស្ថាន។

មួយវិញទៀតគឺនាយកដ្ឋានប្រែប្រួលអាកាសធាតុ ដែលដំបូងឡើយគ្រាន់តែជាការិយាល័យ ប្រែប្រួលអាកាសធាតុត្រូវបានបង្កើតឡើងក្នុងខែមិថុនា ឆ្នាំ២០០៣ ហើយបន្ទាប់មកបានតំលើងជា នាយកដ្ឋានប្រែប្រួលអាកាសធាតុក្នុងខែតុលា ឆ្នាំ២០០៩។ ដែលនាពេលនោះ នាយកដ្ឋាននេះគឺជា សេនាធិការរបស់អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ដែលមាន បេសកកម្មរួមចំនែកដល់ការអភិវឌ្ឍដោយចីរភាព ក្រោមលក្ខខណ្ឌប្រែប្រួលអាកាសធាតុ និងស្រប តាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ នាឆ្នាំ២០១៥ ក្រុមប្រឹក្សាជាតិអភិវឌ្ឍដោយ ចីរភាពត្រូវបានបង្កើតឡើង ហើយមានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពជា សេនាធិការ ហើយនាយកដ្ឋានប្រែប្រួលអាកាសធាតុ ក៏បានផ្លាស់ប្តូរជានាយកដ្ឋានចំណុះឲ្យ អគ្គលេខាធិការដ្ឋាននេះ។[56]

ហើយក៏មានអង្គភាពមួយទៀតដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុគឺ គណៈកម្មាធិការ ជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (គ.ជ.គ.ប.អ.) ដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៦ ដោយអនុក្រឹត្យលេខ ៣៥ អនក្រ.បក។ ដែលមានទិសដៅរួមមួយគាំទ្រដល់រាជរដ្ឋាភិបាលក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងប្រទេស រួមចំនែកការពារបរិស្ថាន និង ធនធានធម្មជាតិ ដើម្បីឲ្យបានដឹងមុន និងទប់ស្កាត់ការប្រែប្រួលអាកាសធាតុបណ្តាលមកពីមនុស្ស ដែលអាចបង្កឥទ្ធិពលអវិជ្ជមានចំពោះសុខុមាលភាពនៃមនុស្សជាតិ។

[56] ដូចខាងលើ, ៧។

ហើយក៏មានអង្គភាពមួយផ្សេងទៀត នោះគឺក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង (ក.ជ.អ.ប) ដែលត្រូវបានបើកសម្ពោធជាផ្លូវការនៅទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៣ ហើយមានគោលបំណងធំមួយ គឺការអភិវឌ្ឍបៃតងលើគ្រប់វិស័យ។[57]

## ២.២ បទដ្ឋានគតិយុត្តអន្តរជាតិពាក់ព័ន្ធនឹងបញ្ហាបម្រែបម្រួលអាកាសធាតុ

### ២.២.១ អនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ

នៅក្នុងសន្និសីទពិភពលោកលើកទី២ស្តីពីអាកាសធាតុ ដែលបានធ្វើឡើងក្នុងទីក្រុងហ្សឺណែវឆ្នាំ១៩៩០ ខុសគ្នាពីសន្និសីទពិភពលោកលើកទី១ស្តីពីអាកាសធាតុដែលធ្វើឡើងក្នុងឆ្នាំ១៩៧៩ ដែលសន្និសីទលើកទី២នេះ មានការចូលរួមពីរដ្ឋមន្ត្រីជាច្រើនរួមទាំងអ្នកវិទ្យាសាស្ត្រផងដែរ។ នៅខែធ្នូ ឆ្នាំ១៩៩០ មហាសន្និបាតអង្គការសហប្រជាជាតិ ស្របតាមសេចក្តីសម្រេចលេខ ៥៥/២១២ បានបង្កើតឲ្យមាននូវគណៈកម្មាធិការចរចារជាលក្ខណៈអន្តររដ្ឋាភិបាលសម្រាប់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីបញ្ហាបម្រែបម្រួលអាកាសធាតុ Intergovernmental Negotiating Committee for a Framework Convention on Climate Change (INC) ដែលជាដំណើរការចរចារអន្តររដ្ឋាភិបាលក្រោមការគាំទ្ររបស់មហាសន្និបាត។ គណៈកម្មាធិការនេះ បានជួបប្រជុំគ្នាចំនួន៥ដង ក្នុងរវាងឆ្នាំ១៩៩១ និងឆ្នាំ១៩៩២ ហើយបានបញ្ចប់ខ្លឹមសាររបស់អនុសញ្ញានេះក្នុងរយៈពេល ១៥ខែ ហើយបានអនុម័តអនុសញ្ញានេះនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៩២ ហើយចាប់ផ្តើមដាក់ចេញនៅខែមិថុនានៅទីក្រុងរីអូ ក្នុងកិច្ចប្រជុំកំពូលស្តីពីបរិស្ថាន និងការអភិវឌ្ឍ ដែលក្នុងពេលនោះមានប្រទេសចំនួន១៥៨រដ្ឋបានចុះហត្ថលេខា។ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៩៤ សន្និសញ្ញានេះបានចូលជាធរមាន។

គោលបំណងសំខាន់របស់អនុសញ្ញានេះ ក៏ដូចជាលិខិតូបករណ៍ពាក់ព័ន្ធផ្សេងទៀតដែរ ដែលភាគីនៃសន្និសីទអាចនឹងអនុម័តស្របតាមបទបញ្ញត្តិនៃអនុសញ្ញានេះ គឺដើម្បីធានាឲ្យមានលំនឹងនៃបណ្តុំឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាស ស្ថិតក្នុងកម្រិតមួយដែលអាចការពារការជ្រៀតជ្រែកនៃ សារធាតុគ្រោះថ្នាក់ក្នុងប្រព័ន្ធបរិយាកាស ។[58] បរិមាណនៃឧស្ម័នផ្ទះកញ្ចក់ដែលបានកម្រិតនេះគួរតែត្រូវសម្រេចឲ្យបានក្នុងរយៈពេលកំណត់មួយសមស្រប ដើម្បីអនុញ្ញាតឲ្យ

---

[57] http://www.cen.com.kh/home ; http://www.cen.com.kh/local/01942623#sthash.xLSF5J1a.dpuf, (ចូលទស្សនាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦)។

[58] អង្គការសហប្រជាជាតិ, FCCC/INFORMAL/84 GE.05-62220 (E) 200705, *United Nations Convention on Climate Change* [អនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីបម្រែបម្រួលអាកាសធាតុ], ១៩៩២, មាត្រា២។

ប្រព័ន្ធអេកូឡូស៊ីអាចសម្របខ្លួននឹងបម្រែបម្រួលអាកាសធាតុ និងដើម្បីធានាថាផលិតផលអាហារមិនត្រូវបានគម្រាមគំហែង និងដែលអនុញ្ញាតឲ្យការអភិវឌ្ឍសេដ្ឋកិច្ចប្រព្រឹត្តទៅបានក្នុងលក្ខណៈស្ថិតស្ថេរ។

ប្រទេសកម្ពុជាយើងបានចូលជាសមាជិកសន្ធិសញ្ញានេះផងដែរគឺតាំងពីឆ្នាំ១៩៩៥។

### ២.២.២ អនុសញ្ញាបាសែលស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូននិងការបោះចោលសំណល់គ្រោះថ្នាក់ឆ្លងដែន

នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ ការរឹតបន្តឹងបទបញ្ញត្តិដែលពាក់ព័ន្ធនឹងបរិស្ថាននៅក្នុងប្រទេសឧស្សាហនីយកម្មដែលនាំឲ្យមានការកើនឡើងយ៉ាងគំហុកនូវការចាក់សម្រាមកខ្វក់ចោល។ ក្នុងការស្វែងរកមធ្យោបាយផ្សេងៗដែលមានតម្លៃថោកដើម្បីលុបបំបាត់កាកសំណល់ អ្នកដែលធ្វើការជួញដូរសារធាតុពុលបានចាប់ផ្តើមដឹកជញ្ជូនកាកសំណល់តាមកប៉ាល់ទៅកាន់ប្រទេសកំពុងអភិវឌ្ឍ និងទៅអឺរ៉ុបខាងកើត។ ពេលដែលសកម្មភាពនេះត្រូវបានលាតត្រដាង ប្រតិកម្មពីអន្តរជាតិនាំឲ្យមានការព្រាងអនុសញ្ញាទីក្រុងបាសែល។ នៅក្នុងពេលដំបូងៗ (១៩៨៩-១៩៩៩) អនុសញ្ញានេះជាគោលការណ៍យកចិត្តទុកដាក់ក្នុងការបង្កើតឡើងនូវក្របខ័ណ្ឌមួយសម្រាប់ត្រួតពិនិត្យការដឹកជញ្ជូនសម្រាមឆ្លងដែន ដែលនេះគឺការដឹកជញ្ជូនសម្រាមឆ្លងពីប្រទេសមួយទៅប្រទេសមួយទៀត។ វាក៏បានអភិវឌ្ឍលក្ខណៈវិនិច្ឆ័យសម្រាប់ការគ្រប់គ្រងបរិស្ថានដែលមានភាពរឹងមាំ ហើយប្រព័ន្ធត្រួតពិនិត្យក៏ត្រូវបានដាក់ឲ្យដំណើរការ។[59]

អនុសញ្ញាទីក្រុងបាសែល ស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូន និងការបោះចោលសំណល់គ្រោះថ្នាក់ឆ្លងដែនត្រូវបានអនុម័តនៅថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៨៩ដោយសន្និសីទនៃអ្នកតំណាងរដ្ឋក្នុងទីក្រុងបាសែល ប្រទេសស្វីស ដើម្បីឆ្លើយតបនឹងការទាមទាររបស់សាធារណជនបន្ទាប់ពីមានការរកឃើញ នៅក្នុងប្រទេសអាហ្វ្រិកនិងបណ្តាតំបន់ផ្សេងៗទៀតនៃប្រទេសកំពុងអភិវឌ្ឍនូវការចាក់ចោលសម្រាមគ្រោះថ្នាក់ដែលដឹកចេញពីប្រទេសក្រៅនៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០។[60]

គោលបំណងនៃអនុសញ្ញាបាសែល គឺដើម្បីការពារសុខភាពមនុស្ស និងបរិស្ថានទប់ទល់នឹងផលប៉ះពាល់នៃសំរាមគ្រោះថ្នាក់។ ទំហំនៃអនុសញ្ញានេះគ្របដណ្តប់លើប្រភេទកាកសំណល់

---

[59] http://www.archive.basel.int/convention/basics.html (ចូលទស្សនាថ្ងៃទី២៣ ឧសភា ២០១៦)។

[60] http://www.basel.int/TheConvention/Overview/tabid/1271/Default.aspx (ចូលទស្សនាថ្ងៃទី២៣ ឧសភា ២០១៦)។

ដែលជាកាកសំណល់គ្រោះថ្នាក់ដែលផ្អែកលើប្រភព និងសមាសធាតុ និងលក្ខណៈរបស់វា ព្រមទាំងប្រភេទសំរាមដទៃទៀតដូចជាសំណល់តាមផ្ទះ និងសំណល់ដែលសល់ពីការដុត។

សន្និសញ្ញានេះផ្តោតទៅលើការកាត់បន្ថយការបង្កើតសំរាមគ្រោះថ្នាក់ និងការលើកកម្ពស់ការគ្រប់គ្រងបរិស្ថានស្តីពីកាកសំណល់គ្រោះថ្នាក់ ការរឹតបន្តឹងការធ្វើចរាចរកាកសំណល់គ្រោះថ្នាក់ និងប្រព័ន្ធបទបញ្ញត្តិដែលត្រូវប្រើក្នុងករណីដែលការដឹកជញ្ជូនកាកសំណល់ឆ្លងដែនត្រូវបានអនុញ្ញាត។

ជារួមអនុសញ្ញាបាសែលនេះមានគោលបំណងសំដៅលើការដឹកជញ្ជូនសំណល់ឆ្លងដែនដែលជាប្រភេទសំណល់គ្រោះថ្នាក់។[61]

### **២.២.៣ អនុសញ្ញាវីយ៉ែន**

អនុសញ្ញាទីក្រុងវីយ៉ែនត្រូវបានបង្កើតឡើងនៅថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៨៥ ហើយបានចូលជាធរមាននៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៨៨។ នេះជាកិច្ចព្រមព្រៀងអន្តរជាតិលើកទី១ស្តីពីការបំផ្លាញស្រទាប់អូសូន។ ក្រោមអនុសញ្ញានេះ បណ្តារដ្ឋាភិបាលប្រទេសផ្សេងៗបានប្តេជ្ញាចិត្តក្នុងការការពារស្រទាប់អូសូន និងសហការគ្នាក្នុងការអភិវឌ្ឍការស្វែងយល់ជាលក្ខណៈវិទ្យាសាស្ត្របន្ថែមពីការវិវត្តនៃបរិយាកាស។ ប្រទេសហត្ថលេខីបានបង្ហាញការយល់ដឹងរបស់ខ្លួនពីផលប៉ះពាល់ដ៏មានឥទ្ធិពលដែលបណ្តាលមកពីការផ្លះផ្លាយស្រទាប់អូសូនមកលើសុខភាពមនុស្ស និងបរិស្ថាន ហើយប្តេជ្ញាចិត្តនឹងធ្វើសកម្មភាពដើម្បីការពារសុខមាលភាពមនុស្ស និងបរិស្ថានទប់ទល់នឹងការប្រែប្រួលផ្សេងៗដែលបណ្តាលមកពីសកម្មភាពរបស់មនុស្សហើយនាំឲ្យមានការផ្លះផ្លាយស្រទាប់អូសូន។[62]

អនុសញ្ញានេះ ត្រូវបានគេហៅវាថាជាអនុសញ្ញាក្របខ័ណ្ឌដោយសារវាដើរតួជាក្របខ័ណ្ឌមួយសំដៅការខិតខំប្រឹងប្រែងក្នុងការការពារស្រទាប់អូសូនទាំងមូល។ អនុសញ្ញានេះមានគោលបំណងឲ្យប្រទេសជាភាគីទាំងអស់លើកកម្ពស់កិច្ចសហប្រតិបត្តិការដោយធ្វើការតាមដានស្រាវជ្រាវ និងការផ្លាស់ប្តូរព័ត៌មានស្តីពីឥទ្ធិពលនៃសកម្មភាពរបស់មនុស្សលើស្រទាប់អូសូន និងដើម្បីអនុម័តច្បាប់ ឬនីតិវិធីរដ្ឋបាលផ្សេងៗទប់ស្កាត់សកម្មភាពរបស់មនុស្សដែលបណ្តាលឲ្យមាន

---

[61] កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ, *Basel Convention on the Control of Transboundary Movements of Hazardous Wastes and Their Disposal* [អនុសញ្ញាបាសែលស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូន និងការបោះចោលសំណល់គ្រោះថ្នាក់ឆ្លងដែន], ១៩៩២, មាត្រា១។

[62] http://adlib.everysite.co.uk/adlib/defra/content.aspx?id=000IL3890W.184SZI7H84U62Q (ចូលទស្សនាថ្ងៃទី២៩ ឧសភា ២០១៦)។

ការប្រែប្រួលដល់ស្រទាប់អូសូន។ អនុសញ្ញានេះមិនបានទាមទារ ឬដាក់កាតព្វកិច្ចឲ្យប្រទេសផ្សេងៗអនុវត្តសកម្មភាពចម្បងដើម្បីត្រួតពិនិត្យសារធាតុដែលនាំឲ្យមានការបំផ្លាញស្រទាប់អូសូននោះទេ តែបណ្ដាប្រទេសផ្សេងៗបានឯកភាពគ្នាបង្កើតឲ្យមានពិធីសារម៉ុងរ៉េអាល់ស្ដីពីសារធាតុបំផ្លាញស្រទាប់អូសូន ដែលស្ថិតក្រោមអនុសញ្ញាវីយ៉េនដើម្បីអនុវត្តឲ្យបាននូវការគ្រប់គ្រងសារធាតុទាំងអស់នោះ។[63]

### ២.២.៤ ពិធីសារម៉ុងរ៉េអាល់ស្ដីពីសារធាតុបំផ្លាញស្រទាប់អូសូន

ការស្រាវជ្រាវជាច្រើនបានបង្ហាញឲ្យឃើញថាការបំផ្លាញស្រទាប់អូសូនមិនត្រឹមតែនាំឲ្យមានការប៉ះពាល់ដល់សុខភាពមនុស្សប៉ុណ្ណោះទេ ប៉ុន្តែក៏ជះឥទ្ធិពលយ៉ាងខ្លាំងដល់ស្ថានប្រព័ន្ធធម្មជាតិ និងប្រព័ន្ធសង្គមផងដែរ និងជាពិសេសគឺការប្រែប្រួលទៅលើអាកាសធាតុនៅលើផែនដី។ ដើម្បីកាត់បន្ថយសារធាតុដែលបំផ្លាញស្រទាប់អូសូន និងអនុវត្តអនុសញ្ញាវីយ៉េនឲ្យមានប្រសិទ្ធិភាព ពិធីសារម៉ុងរ៉េអាល់ត្រូវបានអនុម័តឡើងនៅទីក្រុងម៉ុងរ៉េអាល់ ប្រទេសកាណាដា នាថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៨៧ ដោយមានការចូលរួមពីប្រទេសជាច្រើន។ ប្រទេសកម្ពុជាបានសម្រេចចូលជាសមាជិកនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០១។[64]

### ២.២.៥ អនុសញ្ញាស្ដីពីជីវៈចម្រុះ

អនុសញ្ញាស្ដីពីជីវៈចម្រុះត្រូវបានបង្កើតឡើង និងដាក់ឲ្យប្រទេសផ្សេងៗចុះហត្ថលេខានៅក្នុងសន្និសីទអន្តរជាតិស្ដីពីបរិស្ថាន និងការអភិវឌ្ឍ ហើយបានចូលជាធរមាននៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៣។ អនុសញ្ញានេះបង្កើតឡើងក្នុងគោលបំណងសំខាន់ៗដូចជា៖

- ផ្ដោតលើការអភិរក្សជីវៈចម្រុះ
- ការប្រើប្រាស់ប្រកបដោយចីរភាពនៃសមាសភាគនៃជីវៈចម្រុះ
- ការចែកចាយអត្ថប្រយោជន៍ដែលទទួលបានពីការប្រើប្រាស់ប្រភពថាមពល ប្រកបដោយភាពត្រឹមត្រូវនិងសមភាព។[65]

[63] http://ozone.unep.org/en/treaties-and-decisions/vienna-convention-protection-ozone-layer (ចូលទស្សនាថ្ងៃទី២៤ ឧសភា ២០១៦)។

[64] សេចក្ដីថ្លែងហេតុនៃសេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើពិធីសារម៉ុងរ៉េអាល់ស្ដីពីសារធាតុបំផ្លាញស្រទាប់អូសូន, រាជរដ្ឋាភិបាលកម្ពុជា លេខ ៦០ សជណ.កបច, ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០០៥។

[65] https://www.cbd.int/intro/default.shtml (ចូលទស្សនាថ្ងៃទី២៤ ឧសភា ២០១៦)។

ប្រទេសកម្ពុជាបានចូលជាសមាជិកនៃអនុសញ្ញានេះចាប់តាំងពីថ្ងៃទី ១០ ខែឧសភា ឆ្នាំ ១៩៩៥។[66]

### ២.២.៦ អនុសញ្ញាស្តុកខូម

អនុសញ្ញាទីក្រុងស្តុកខូម ស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ បានធ្វើឡើងនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ នៅក្នុងទីក្រុងស្តុកខូម ប្រទេសស៊ុយអែតហើយបានចូលជាធរមាននៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៤។ អនុសញ្ញានេះជាអនុសញ្ញាអន្តរជាតិមួយដែលការពារសុខភាពមនុស្ស និងបរិស្ថានពីសារធាតុគីមីដែលនៅសល់ក្នុងបរិស្ថានរយៈពេលយូរ ហើយបានចែកចាយទៅតាមទីតាំងភូមិសាស្ត្រផ្សេងៗគ្នា ដែលជ្រៀតចូលក្នុងជាលិការបស់មនុស្ស និងសត្វព្រៃ ហើយនាំឲ្យមានផលប៉ះពាល់ដល់សុខភាពមនុស្ស និងបរិស្ថាន។ ការបញ្ចេញសារធាតុបំពុលសរីរាង្គដែលមិនអាចបំបែកបាននេះអាចនាំមានគ្រោះថ្នាក់ដល់សុខភាពមនុស្សដូចជាការកើតមាននូវជំងឺមហារីក ផលប៉ះពាល់ដល់សសៃប្រសាទជាដើម។ ដោយសារសកម្មភាពរបស់រដ្ឋាភិបាលប្រទេសតែមួយមិនអាចការពារប្រជាជនរបស់គេ ព្រមទាំងបរិស្ថានពីសារធាតុទាំងនោះបាន ដូច្នេះដើម្បីឆ្លើយតបទៅនឹងបញ្ហាដ៏ធំនេះ អនុសញ្ញានេះបានកំណត់ឲ្យរដ្ឋជាភាគីអនុវត្តនីតិវិធីផ្សេងៗដើម្បីលុបបំបាត់ ឬកាត់បន្ថយការបញ្ចេញសារធាតុសរីរាង្គបំពុលទៅក្នុងបរិស្ថាន។[67] គោលបំណងសំខាន់របស់អនុសញ្ញានេះគឺដើម្បីការពារសុខមាលភាពរបស់មនុស្ស និងការពារបរិស្ថានពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុដែលមានក្នុងបរិស្ថាន។[68]

### ២.២.៧ ពិធីសារទីក្រុងក្យូតូ

ពិធីសារក្យូតូ គឺជាកិច្ចព្រមព្រៀងអន្តរជាតិមួយដែលភ្ជាប់ទៅនឹងអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីបម្រែបម្រួលអាកាសធាតុ។ វាជាកិច្ចព្រមព្រៀងមួយដែលបានកំណត់គោលដៅនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ដោយមានការទទួលស្គាល់ថាប្រទេសអភិវឌ្ឍជាប្រទេសដែលគួរតែទទួលខុសត្រូវចំពោះកម្រិតខ្ពស់នៃឧស្ម័នផ្ទះកញ្ចក់ក្នុងបរិយាកាសនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃសកម្មភាពឧស្សាហកម្មជាង១៥០ឆ្នាំ ពិធីសារនេះបានធ្វើការដាក់បន្ទុកយ៉ាងខ្លាំងដល់ប្រទេសអភិវឌ្ឍក្រោមគោលការណ៍នៃការទទួលខុសត្រូវរួមតែផ្សេងៗពីគ្នា។

---

66 https://www.cbd.int/information/parties.shtml#tab=0 (ចូលទស្សនាថ្ងៃទី២៥ ឧសភា ២០១៦)។

67 http://chm.pops.int/TheConvention/Overview/tabid/3351/ (ចូលទស្សនាថ្ងៃទី២៥ ឧសភា ២១៦)។

68 អង្គការសហប្រជាជាតិ, 2256 UNTS 119; 40 ILM 532, *Stockholm Convention on Persistent Organic Pollutants* [សន្ធិសញ្ញាទីក្រុងស្តុកខូមស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ], ២០០៤, មាត្រា១។

ពិធីសារនេះ ត្រូវបានអនុម័តឡើងនៅក្នុងទីក្រុងក្យូតូ ប្រទេសជប៉ុន កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៧ ហើយបានចូលជាធរមាននៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៥។ ពិធីសារនេះទាមទារឲ្យប្រទេសជាសមាជិកអនុវត្តឲ្យបាននូវការកាត់បន្ថយឧស្ម័នក្នុងកម្រិតដែលបានកំណត់ ដោយប្រើប្រាស់មធ្យោបាយវាស់ស្ទង់របស់ខ្លួន។ ប៉ុន្តែវាក៏បានអនុញ្ញាតឲ្យប្រទេសទាំងនោះអនុវត្តនូវមធ្យោបាយផ្សេងៗទៀតដូចជា ការជួញដូរការបញ្ចេញឧស្ម័នជាលក្ខណៈអន្តរជាតិ យន្តការអភិវឌ្ឍស្អាត និងការអនុវត្តរួមគ្នា។

ម្យ៉ាងទៀតពិធីសារនេះគឺជាជំហានយ៉ាងសំខាន់ក្នុងការសម្រេចឲ្យបាននូវសង្គមមួយដែលកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលវាជាកត្តាមួយនាំឲ្យមានស្ថេរភាពនៃកម្រិតការបញ្ចេញឧស្ម័នទៅក្នុងបរិយាកាស និងជាថ្នាលមួយជួយជម្រុញឲ្យមាននូវគ្រោងសម្រាប់កិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀតពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ។[69] ប្រទេសកម្ពុជាយើងបានសុំចូលជាសមាជិកនៅថ្ងៃទី២២ខែសីហា ឆ្នាំ២០០២ ហើយបានចូលជាធរមាននៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៥។

## ២.៣ ទំនាក់ទំនងរវាងបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិស្តីពីបញ្ហាបម្រែបម្រួលអាកាសធាតុ

### ២.៣.១ ទំនាក់ទំនង

ក្រសួងបរិស្ថានបានដើរតួជាស្ថាប័នបង្គោលរបស់កម្ពុជាសម្រាប់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងពិធីសារទីក្រុងក្យូតូ ដោយដើរតួចម្បងនៅក្នុងការរៀបចំ និងសម្របសម្រួលការឆ្លើយតបរបស់កម្ពុជាទៅនឹងការប្រែប្រួលអាកាសធាតុ។ វិស័យនានាដទៃទៀតដូចជាក្រសួងសំខាន់ៗបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការរៀបគោលនយោបាយ និងការអនុវតតគម្រោង កម្មវិធីនានាដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។

### ២.៣.២ គុណសម្បត្តិនៃការចូលជាសមាជិក

ការចូលជាសមាជិកនៃសន្ធិសញ្ញា អនុសញ្ញា និងលិខិតូបករណ៍អន្តរជាតិផ្សេងៗ ផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនចំពោះប្រទេសកម្ពុជា ទាំងផ្នែកបរិស្ថាន សេដ្ឋកិច្ច និងនយោបាយ។

- ផ្នែកបរិស្ថាន៖ ប្រទេសកម្ពុជាមានលទ្ធភាពក្នុងការស្វែងយល់បន្ថែមពីបញ្ហាបរិស្ថាន ដើម្បីធ្វើការការពារ ទប់ស្កាត់ កាត់បន្ថយឥទ្ធិពលនៃបញ្ហាពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ។ ម្យ៉ាង

[69] http://www.unfccc.int/kyoto_protocol/items/2830.php (ចូលទស្សនាថ្ងៃទី២៤ ឧសភា ២០១៦)។

ទៀតប្រទេសកម្ពុជាអាចយកខ្លឹមសារនៃច្បាប់ទាំងនោះមកចងក្រងក្នុងច្បាប់ជាតិ និងគោលនយោបាយសំដៅការថែរក្សាបរិស្ថាន និងធនធានធម្មជាតិ។ ក្រៅពីនេះប្រទេសកម្ពុជាមានឱកាសក្នុងការទទួលបានការគាំទ្រជំនួយបច្ចេកទេស ហិរញ្ញវត្ថុ សម្រាប់ការបណ្តុះបណ្តាលការផ្តល់បច្ចេកទេស និងការទទួលបានព័ត៌មាន ការអនុវត្តគម្រោង គោលនយោបាយជាដើម។

- ផ្នែកសេដ្ឋកិច្ច៖ ដោយសារប្រទេសយើងជាប្រទេសកំពុងអភិវឌ្ឍ ដូច្នេះកាតព្វកិច្ចរបស់កម្ពុជាមិនមានច្រើនដូចជាបណ្តាប្រទេសអភិវឌ្ឍនោះទេ។ ការចូលរួមជាសមាជិកក្នុងលិខិតូបករណ៍អន្តរជាតិ ជាឱកាសដែលប្រទេសកម្ពុជាអាចចូលរួមអនុវត្តគម្រោងផ្សេងៗ ដែលជាថវិកាពហុភាគីព្រមទាំងទទួលបាននូវជំនួយក្នុងការប្រតិបត្តិសកម្មភាពដែលជាកិច្ចការពារបរិស្ថាន។
- ផ្នែកនយោបាយ៖ កម្ពុជាអាចបង្ហាញឆន្ទៈរបស់ខ្លួនក្នុងការរួមចំណែកដោះស្រាយបញ្ហាបរិស្ថាននានាដោយសហការជាមួយនឹងសហគមន៍អន្តរជាតិ។ លើសពីនេះទៅទៀត ប្រទេសកម្ពុជាអាចទទួលបានកិត្យានុភាពលើឆាកអន្តរជាតិក្នុងនាមជាប្រទេសដែលចូលរួមការការពិភាក្សា ការដោះស្រាយនិងកាត់បន្ថយមូលហេតុដែលនាំឲ្យមានបញ្ហាបម្រែបម្រួលអាកាសធាតុ និងបញ្ហាបរិស្ថានជារួម។

សរុបមកការចូលជាសមាជិកនៃលិខិតូបករណ៍អន្តរជាតិ ជាឱកាសដ៏ល្អសម្រាប់កម្ពុជាក្នុងការអភិវឌ្ឍប្រទេសជាតិដោយគិតគូរពីបញ្ហាបរិស្ថានជាធំ។ ហើយទំនាក់ទំនងរវាងលិខិតូបករណ៍អន្តរជាតិទាំងនោះ អាចឲ្យយើងយកមកអនុវត្តនៅក្នុងប្រព័ន្ធច្បាប់ជាតិ ដើម្បីធ្វើយ៉ាងណាឲ្យការអនុវត្តកិច្ចការពារបរិស្ថាន ជាពិសេសទៅលើបញ្ហាបម្រែបម្រួលអាកាសធាតុមានលទ្ធផលល្អប្រសើរ។

# ជំពូកទី៣

# គោលនយោបាយរបស់រដ្ឋាភិបាល
# ចំពោះបញ្ហាប្រែប្រួលអាកាសធាតុ

# ជំពូកទី៣ គោលនយោបាយរបស់រដ្ឋាភិបាលចំពោះបញ្ហាបម្រែបម្រួលអាកាសធាតុ

រដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់បន្តការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព ដែលធានានូវគុណភាពជីវិត និងបង្កើនគុណភាពរស់នៅរបស់ប្រជាជន។ អាទិភាពចម្បងមួយរបស់ការអភិវឌ្ឍជាតិគឺការកាត់បន្ថយភាពក្រីក្រ។ ដោយប្រទេសកម្ពុជាជាប្រទេសមួយដែលទទួលរងឥទ្ធិពលពីបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រពិតជាមិនអាចកាត់ផ្តាច់ពីបញ្ហាបម្រែបម្រួលអាកាសធាតុបានទេ ដោយសារវាជួយរដ្ឋាភិបាលក្នុងការកាត់បន្ថយ អត្រារងគ្រោះដែលកើតពីអាកាសធាតុ។ បញ្ហាបម្រែបម្រួលអាកាសធាតុមានឥទ្ធិពលយ៉ាងខ្លាំងដល់មនុស្ស ជាពិសេសប្រជាជនរស់នៅតាមតំបន់ជនបទដែលពឹងផ្អែកលើធនធានធម្មជាតិ។

## ៣.១ គោលនយោបាយរដ្ឋាភិបាល

បន្ទាប់ពីបានផ្តល់សច្ចាប័នលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីបម្រែបម្រួលអាកាសធាតុ (UNFCCC) កម្ពុជាបានចូលរួមជាមួយសហគមន៍អន្តរជាតិក្នុងការលើកឡើងពីបញ្ហាបម្រែបម្រួលអាកាសធាតុ។ ប៉ុន្តែប្រទេសកម្ពុជាក៏នៅតែទទួលផលប៉ះពាល់ខ្លាំងពីឥទ្ធិពលនៃបម្រែបម្រួលអាកាសធាតុដូចជាទៅលើវិស័យកសិកម្ម ធនធានទឹក ព្រៃឈើ ជលផល វិស័យទេសចរណ៍ជាដើម។ រដ្ឋាភិបាលបានខិតខំបង្កើតនូវគោលនយោបាយ ផែនការ និងស្ថាប័នជាតិជាច្រើន ដើម្បីឆ្លើយតបនឹងបញ្ហាបម្រែបម្រួលអាកាសធាតុ ដូចមានចែងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៤-២០១៨។ ក្នុងនោះរដ្ឋាភិបាល បានទទួលស្គាល់ការគ្រប់គ្រងបរិស្ថាន និងការប្រែប្រួលអាកាសធាតុថាជាបញ្ហាប្រឈមដែលត្រូវដោះស្រាយ។

ក្នុងនីតិកាលទី៥នេះ ក្រសួងបរិស្ថាននឹងបន្តផ្តោតលើការគ្រប់គ្រងបរិស្ថាននៅកម្ពុជាតាមរយៈ៖

ទី១ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។

ទី២ ការខិតខំកាត់បន្ថយផលប៉ះពាល់ពការប្រែប្រួលអាកាសធាតុ តាមរយៈការព្រឹងសមត្ថភាពបន្សាំ និងភាពធនទៅនឹងការប្រែប្រួលអាកាសធាតុ ជាពិសេស ការអនុវត្ត *ផែនការយុទ្ធសាស្ត្របម្រែបម្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០១៤-២០២៣ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង* និង *ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០*។

ទី៣ ការបន្តពង្រឹងសមត្ថភាពបច្ចេកទេស និងស្ថាប័ន ដើម្បីជំរុញការបញ្ជ្រាបប្រធានបទស្តីពីការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ ច្បាប់ និងផែនការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ទី៤ ការបន្តដាក់ចេញនូវវិធានការនានា ដើម្បីគ្រប់គ្រងការបំពុលបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី។[70]

## ៣.១.១ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៤-២០២៣

ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៤-២០១៨ ដែលបានលើកយកការងារបរិស្ថានជាបញ្ហាស្នូលរបស់ប្រទេស ផែនការយុទ្ធសាស្ត្រស្តីពីបម្រែបម្រួលអាកាសធាតុឆ្នាំ២០១៤-២០២៣ ក៏បានចែងពីទស្សនៈវិស័យ បេសកកម្ម និងគោលដៅរបស់ខ្លួនក្នុងការឆ្លើយតបនឹងបញ្ហាបម្រែបម្រួលអាកាសធាតុផងដែរគឺផ្អែកសំខាន់លើការវិភាគលើសមត្ថភាពរបស់ស្ថាប័ន ការតាមដានឥទ្ធិពលបម្រែបម្រួលអាកាសធាតុ និងការប៉ាន់ប្រមាណពីការប្រែប្រួលអាកាសធាតុ។[71] ចក្ខុវិស័យចម្បងរបស់វាគឺការធ្វើឲ្យប្រទេសកម្ពុជាក្លាយជាប្រទេសដែលមានពណ៌បៃតង មានកាបូនតិច អាចទប់ទល់នឹងអាកាសធាតុបានប្រសើរ មានសមធម៌ ចីរភាព និងមានចំណេះដឹង។ ព្រមគ្នានេះដែរបេសកកម្មរបស់វាគឺការបង្កើតក្របខ័ណ្ឌជាតិដើម្បីឲ្យមានការចូលរួមពីសាធារណជន វិស័យឯកជន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍពាក់ព័ន្ធផ្សេងទៀតនៅក្នុងដំណើរការនៃការឆ្លើយតបទៅនឹងបម្រែបម្រួលអាកាសធាតុដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។

គោលដៅនៃផែនការយុទ្ធសាស្ត្រនេះ គឺផ្តោតសំខាន់លើបញ្ហាដូចជា៖

- កាត់បន្ថយភាពអត្រារងគ្រោះដែលកើតមានដោយបម្រែបម្រួលអាកាសធាតុលើមនុស្ស ជាពិសេសចំពោះប្រព័ន្ធដែលងាយរងគ្រោះ និងសំខាន់ (ធម្មជាតិ និងមនុស្ស)
- ឆ្ពោះទៅរកមាគ៌ាអភិវឌ្ឍបៃតងដោយលើកកម្ពស់ការអភិវឌ្ឍនិងបច្ចេកវិទ្យាដែលមានកាបូនតិច
- លើកកម្ពស់ស្មារតីយល់ដឹងរបស់ប្រជាជន និងការចូលរួមពាក់ព័ន្ធនឹងសកម្មភាពឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ។[72]

រដ្ឋាភិបាលបានដាក់ចេញនូវគោលបំណងយុទ្ធសាស្ត្រចំនួន៨ដើម្បីធ្វើឲ្យសម្រេចបាននូវគោលបំណងនិងទស្សនវិស័យខាងលើនេះដែលមានដូចជា៖

---

[70] *គោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ឆ្នាំ២០១៤-២០១៨ របស់រាជរដ្ឋាភិបាល*, ជំពូកទី៤ ទំព័រ២០៥។

[71] *ផែនការយុទ្ធសាស្ត្របម្រែបម្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០១៤-២០២៣*, គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ, ២០១៣។

[72] ដូចខាងលើ។

1. លើកកម្ពស់ការទប់ទល់នឹងអាកាសធាតុតាមរយៈសន្តិសុខស្បៀង ទឹក និងថាមពល។

2. កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តាមតំបន់ និងតាមយ៉េនឌ័រ និងគ្រោះថ្នាក់សុខភាព ព្រមទាំងកាត់បន្ថយឥទ្ធិពលនៃបម្រែបម្រួលអាកាសធាតុ។

3. ធានាលទ្ធភាពទប់ទល់អាកាសធាតុរបស់ប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ ប្រព័ន្ធអេកូឡូស៊ីតាមតំបន់ឆ្នេរ ខ្ពង់រាប) ជីវចម្រុះ តំបន់ការពារ និងតំបន់បេតិកភណ្ឌវប្បធម៌។

4. លើកកម្ពស់គម្រោង និងបច្ចេកវិទ្យាដែលមានកាបូនតិចដើម្បីគាំទ្រការអភិវឌ្ឍប្រកបដោយចីរភាព។

5. ពង្រឹងសមត្ថភាព ចំណេះដឹង និងស្មារតីយល់ដឹងដើម្បីឆ្លើយតបទៅនឹងបម្រែបម្រួលអាកាសធាតុ។

6. លើកកម្ពស់ការបន្សាំ និងវិធីសាស្ត្រនៃការចូលរួមនៅក្នុងការកាត់បន្ថយការបាត់បង់ និងការបំផ្លាញដោយបញ្ហាប្រែប្រួលអាកាសធាតុ។

7. ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌសហប្រតិបត្តិការសម្រាប់ការឆ្លើយតបចំពោះបម្រែបម្រួលអាកាសធាតុ។

8. ពង្រឹងកិច្ចសហប្រតិបត្តិការ និងការចូលរួមយ៉ាងសកម្មក្នុងដំណើរការបម្រែបម្រួលអាកាសធាតុក្នុងតំបន់ និងសកល។

ផែនការយុទ្ធសាស្ត្របម្រែបម្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣ បានចែងពីសកម្មភាពអនុវត្តជា៣ដំណាក់កាលគឺ

- ដំណាក់កាលដំបូង ២០១៣-២០១៤៖ ផ្តោតលើការរៀបចំស្ថាប័ន និងហិរញ្ញវត្ថុសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ និងសម្រាប់អភិវឌ្ឍក្របខ័ណ្ឌ និងសូចនាករនៃការត្រួតពិនិត្យនិងវាយតម្លៃថ្នាក់ជាតិ ការអភិវឌ្ឍផែនការសកម្មភាពស្តីពីបម្រែបម្រួលអាកាសធាតុនៅឆ្នាំ២០១៤-២០១៨។
- ដំណាក់កាលទី២ ឆ្នាំ២០១៣-២០១៤៖ បន្តគាំទ្រការអនុវត្តដំណាក់កាលទី១ ដោយគ្របដណ្តប់ទាំងសកម្មភាពផ្សេងៗទៀតដូចជា ការទទួលស្គាល់ទៅលើថវិកាសម្រាប់ការបន្សាំ និងថវិកាអាកាសធាតុបៃតង ការគ្រប់គ្រងចំណេះដឹង និងការស្រាវជ្រាវ ការអភិវឌ្ឍសមត្ថភាព បញ្ជ្រាបញ្ហាបម្រែបម្រួលអាកាសធាតុក្នុងវិស័យផ្សេងៗគ្នាគ្រប់កម្រិត ដំណើរការនៃប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ និងការគ្រប់គ្រងទិន្នន័យ ការចាប់ផ្តើមគម្រោងឬកម្មវិធីអាទិភាពមួយចំនួននៅក្នុងវិស័យសំខាន់ៗដែលបានចែងក្នុងផែនការសកម្មភាពស្តីពីបញ្ហាបម្រែបម្រួលអាកាសធាត។ គោលដៅ

អាទិភាពចម្បងគឺសំដៅលើសកម្មភាពក្នុងការបន្សាំ ដែលរាប់បញ្ចូលទាំងសកម្មភាពពាក់ព័ន្ធនឹងការបន្ថយកម្រិតឧស្ម័នផ្ទះកញ្ចក់។

- ដំណាក់កាលពីឆ្នាំ២០១៩ ដល់ ២០២៣៖ ផ្តោតលើការស្រាវជ្រាវ និងសិក្សា ដែលគោលបំណងសំខាន់របស់វាគឺបន្តបញ្ជ្រាបបញ្ហាបម្រែបម្រួលអាកាសធាតុទៅក្នុងកម្មវិធីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ផែនការយុទ្ធសាស្ត្របម្រែបម្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣ជាផែនការយុទ្ធសាស្ត្រមួយដែលឆ្លុះបញ្ចាំងពីកិច្ចខិតខំរបស់រដ្ឋាភិបាលក្នុងការគិតគូរលើបញ្ហាបម្រែបម្រួលអាកាសធាតុ។

### ៣.១.២ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង

គោលនយោបាយអភិវឌ្ឍបៃតងត្រូវបានបង្កើតឡើងដើម្បីធ្វើឲ្យមានតុល្យភាពរវាងការអភិវឌ្ឍសេដ្ឋកិច្ច និងបរិស្ថាន សង្គម ព្រមទាំងវប្បធម៌ ដើម្បីសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាព និងដើម្បីទាក់ទាញហិរញ្ញប្បទាន បច្ចេកវិទ្យាបៃតង និងវិនិយោគិនបរទេស។

ចក្ខុវិស័យនៃការបង្កើតគោលនយោបាយជាតិនេះគឺធ្វើឲ្យមានតុល្យភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចជាមួយនឹងបរិស្ថាន សង្គម វប្បធម៌ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាពតាម  រយៈការបញ្ជ្រាប ការបន្ស៊ី ការបន្សាំ និងធ្វើឲ្យមានសុខដុមនីយកម្មរវាងគោលការណ៍អភិវឌ្ឍបៃតង និងគោលនយោបាយជាតិ។ ស្របតាមចក្ខុវិស័យនៃគោលនយោបាយនេះ គោលបំណងរបស់វាគឺលើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាជនទាំងអស់ ប្រកបដោយសុខដុមនីយកម្មជាមួយនឹងសុវត្ថិភាពអេកូឡូស៊ី តាមរយៈការអភិវឌ្ឍបៃតងផ្អែកលើសេដ្ឋកិច្ចបៃតង សេដ្ឋកិច្ចខៀវ ការការពារបរិស្ថាន ប្រព័ន្ធសុវត្ថិភាពសង្គម និងការរក្សាអត្តសញ្ញាណវប្បធម៌ជាតិ។[73]

បន្ថែមពីលើនេះទៀត គោលនយោបាយនេះក៏បានចែងពីគោលដៅដែលត្រូវអនុវត្តដើម្បីសម្រេចឲ្យបាននូវចក្ខុវិស័យដែលបានរៀបចំឡើង។ គោលដៅទាំងនោះរួមមានដូចជា៖

- ធ្វើការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយតុល្យភាពជាមួយបរិស្ថាន សង្គម វប្បធម៌
- បង្កើតបរិយាកាសអំណោយផលសម្រាប់អភិវឌ្ឍបៃតងប្រកបដោយសមធម៌ តុល្យភាព ភាគរភាព និងគុណភាពក្នុងប្រព័ន្ធសេដ្ឋកិច្ច សង្គម និងអេកូឡូស៊ី ដែលរក្សាបាននូវតម្លៃវប្បធម៌ជាតិ

[73] គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រសួងបរិស្ថាន ១ មីនា ឆ្នាំ២០១៣ ទំព័រ ១១។

- ធ្វើការគ្រប់គ្រងឲ្យមានប្រសិទ្ធិភាពក្នុងការទទួលបានសិទ្ធិគ្រប់គ្រងធនធានទឹក និងអនាម័យ សិទ្ធិទទួលបានសន្តិសុខស្បៀងនិងសុវត្ថិភាពចំណីអាហារ សិទ្ធិទទួលបានការអភិវឌ្ឍ ការអភិរក្សព្រៃឈើ និងធនធានចម្រុះ និងការប្រើប្រាស់ដីប្រកបដោយនិរន្តរភាព សិទ្ធិទទួលបានថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល សិទ្ធិទទួលបានព័ត៌មាន ចំណេះដឹង និងបំណិន សិទ្ធិទទួលបានមធ្យោបាយបម្រើឲ្យជីវភាពសង្គមនិងបរិស្ថានកាន់តែល្អប្រសើរ និងសិទ្ធិទទួលបានហិរញ្ញវត្ថុក្នុងការបង្កើតអាជីវកម្មខ្នាតតូច មធ្យម និងការវិនិយោគ
- លើកកម្ពស់ការអប់រំនិងបណ្តុះបណ្តាលលើការងារអភិវឌ្ឍបៃតង
- ពង្រឹងការផ្លាស់ប្តូរព័ត៌មាន ចំណេះដឹង បទពិសោធល្អៗ បច្ចេកទេស បច្ចេកវិទ្យា និងការវិនិយោគទាក់ទាញការងារបៃតង
- ជំរុញកិច្ចសហប្រតិបត្តិការអភិវឌ្ឍបៃតងក្នុងក្របខ័ណ្ឌថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ តំបន់ព្រមទាំងពិភពលោក។

រដ្ឋាភិបាលក៏បានបង្កើតនូវយុទ្ធសាស្ត្រមួយចំនួនផងដែរ ដូចជាៈ

- កិច្ចសហប្រតិបត្តិការនិងសម្របសម្រួលអន្តរស្ថាប័នជាតិនិងអន្តរជាតិ
- ការសិក្សាស្រាវជ្រាវនិងវិភាគទិន្នន័យ
- សុខដុមនីយកម្មនៃការអភិវឌ្ឍបៃតងក្នុងសេដ្ឋកិច្ច សង្គម និងវប្បធម៌
- ការអភិវឌ្ឍធនធានមនុស្ស
- ការអភិវឌ្ឍបច្ចេកវិទ្យាបៃតងឲ្យមានប្រសិទ្ធិភាព

ស្របទៅតាមគោលនយោបាយ ចក្ខុវិស័យ និងយុទ្ធសាស្ត្រខាងលើ បានស្តែងឲ្យឃើញថារដ្ឋាភិបាលបានយកចិត្តទុកដាក់លើការអភិវឌ្ឍបៃតងយ៉ាងខ្លាំង ព្រមទាំងការធានាឲ្យមានតុល្យភាពរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌។

### ៣.១.៣ ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០

ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ២០១៣ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយរបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចជាតិឆ្ពោះទៅរកសេដ្ឋកិច្ចបៃតងដោយផ្តោតទៅលើការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពនៃធនធានធម្មជាតិ ស្ថេរភាពបរិស្ថាន មុខរបរបៃតង បច្ចេកវិទ្យាបៃតង និងកំណែទម្រង់ សេដ្ឋកិច្ច។ ចក្ខុវិស័យនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០នេះ គឺសង្កត់ធ្ងន់ទៅលើការអភិវឌ្ឍសេដ្ឋកិច្ចជាតិ

ប្រកបដោយចីរភាព ព្រមទាំងបរិស្ថាន សង្គម និងស្ថេរភាពនៃវប្បធម៌សម្រាប់ការកាត់បន្ថយភាពក្រីក្រ។[74]

ផែនការយុទ្ធសាស្ត្រនេះមានបេសកកម្មផ្សព្វផ្សាយ លើកកម្ពស់ បង្កើន និងធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃការអភិវឌ្ឍបៃតងតាមរយៈការបញ្ជ្រាបពីដំណើរការនិងការវិវត្តបៃតង។[75] បន្ថែមពីលើនេះផែនការយុទ្ធសាស្ត្រជាតិមានគោលដៅធ្វើឲ្យសម្រេចបាននូវការអភិវឌ្ឍបៃតងដើម្បីធានាដល់ស្ថេរភាពនយោបាយ និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចដើម្បីឲ្យប្រទេសកម្ពុជាក្លាយជាប្រទេសអភិវឌ្ឍ។[76]

គោលបំណងសំខាន់ៗនៃផែនការយុទ្ធសាស្ត្រនេះ គឺការលើកកម្ពស់សេដ្ឋកិច្ចជាតិ ស្ថេរភាពការអភិវឌ្ឍ ការកាត់បន្ថយ និងការការពារការបំពុលបរិស្ថាន ការលើកកម្ពស់សេវាសុខភាពសាធារណៈ គុណភាពអប់រំ ការគ្រប់គ្រងធនធានធម្មជាតិ និងការប្រើប្រាស់ដីប្រកបដោយចីរភាព និងការគ្រប់គ្រងធនធានទឹក  ដើម្បីធានាឲ្យបាននូវកំណើនថាមពលដែលមានប្រសិទ្ធិភាព ធានាសុវត្ថិភាពចំណីអាហារ និងលើកតម្កើងវប្បធម៌ជាតិ។

ក្រៅពីនេះគេក៏បានសិក្សាពីក្របខ័ណ្ឌយុទ្ធសាស្ត្រសំខាន់ៗស្របតាមចក្ខុវិស័យ គោលបំណងរបស់ផែនការយុទ្ធសាស្ត្រនេះផងដែរ ដែលក្នុងនោះគេពង្រឹងលើទិសដៅយុទ្ធសាស្ត្រដូចជា៖

- ការវិនិយោគបៃតង និងការបង្កើតការងារបៃតង
- ការគ្រប់គ្រងសេដ្ឋកិច្ចបៃតងឲ្យមានតុល្យភាពជាមួយបរិស្ថាន
- ការអភិវឌ្ឍនិងចីរភាពរបស់សេដ្ឋកិច្ចខៀវ
- បរិស្ថានបៃតង និងការគ្រប់គ្រងធនធានធម្មជាតិ
- ការអភិវឌ្ឍធនធានមនុស្ស និងការអប់រំបៃតង
- ការគ្រប់គ្រងបច្ចេកវិទ្យាបៃតងប្រកបដោយប្រសិទ្ធិភាព
- ការលើកកម្ពស់ប្រព័ន្ធសុវត្ថិភាពសង្គមបៃតង
- ការគាំទ្រ និងការពារបេតិកភណ្ឌវប្បធម៌បៃតង និងអត្តសញ្ញាណជាតិ
- អភិបាលកិច្ចល្អចំពោះការអភិវឌ្ឍបៃតង។

[74] *ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០,* ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងក្រសួងបរិស្ថាន ១ មីនា ឆ្នាំ២០១៣ ទំព័រ ២។

[75] ដូចខាងលើ។

[76] ដូចខាងលើ។

យុទ្ធសាស្ត្រទាំងនេះត្រូវបានគិតគូរយ៉ាងយកចិត្តទុកដាក់ ដើម្បីសម្រេចឲ្យបានលទ្ធផលមួយដែលបន្តការអភិវឌ្ឍសេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន។

## ៣.២ សកម្មភាពរបស់រដ្ឋាភិបាល និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

### ៣.២.១ សកម្មភាពចម្បងរបស់រដ្ឋាភិបាល

#### ៣.២.១.១ ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុឆ្នាំ២០១៦-២០១៨

បន្ថែមពីលើគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការផ្សេងៗ រដ្ឋាភិបាលកម្ពុជាបាននឹងកំពុងបន្តការអនុវត្តសកម្មភាពនានាជាច្រើនពាក់ព័ន្ធនឹងបញ្ហាបម្រែបម្រួលអាកាសធាតុ ដែលសកម្មភាពទាំងនោះបានស្តែងឲ្យឃើញពីការយកចិត្តទុកដាក់របស់រដ្ឋាភិបាលក្នុងការឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងដែលកំពុងតែកើតមាននៅលើពិភពលោក។ បន្ទាប់ពីបានចូលជាសមាជិកនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីបម្រែបម្រួលអាកាសធាតុ ប្រទេសកម្ពុជាបានធ្វើនូវរបាយការណ៍ពីរច្បាប់ទៅកាន់អនុសញ្ញាក្របខ័ណ្ឌនេះ ដែលរបាយការណ៍ទី១ បានធ្វើឡើងនៅខែសីហាឆ្នាំ២០០២ និងលើកទី២នៅខែវិច្ឆិកាឆ្នាំ២០១៥។[77] របាយការណ៍ទាំងពីរនេះរៀបរាប់ពីសកម្មភាពដែលកម្ពុជាបាននឹងកំពុងធ្វើដើម្បីទប់ទល់នឹងបម្រែបម្រួលអាកាសធាតុ ក៏ដូចជាការកាត់បន្ថយឥទ្ធិពលនៃឧស្ម័នផ្ទះកញ្ចក់ជាដើម។

ដូចមានចែងក្នុងផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ២០១៦-២០១៨ ដែលបានរៀបចំឡើងដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ស្របតាមគោលការណ៍ណែនាំពីទីស្តីការគណៈរដ្ឋមន្ត្រី និងពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ផែនការនេះជាផ្នែកមួយយ៉ាងសំខាន់ដែលរួមចំណែកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៤-២០២៣។[78] ផែនការសកម្មភាពនេះផ្តោតលើសកម្មភាពយុទ្ធសាស្ត្រមួយចំនួនពាក់ព័ន្ធនឹងការគាំពារបរិស្ថាន ការអភិរក្សនិងប្រើប្រាស់ដោយចីរភាពនៃធនធានធម្មជាតិ ការអភិវឌ្ឍបៃតង ការអប់រំនិងផ្សព្វផ្សាយបរិស្ថាន និងអភិបាលកិច្ចប្រែប្រួលអាកាសធាតុ។ ផែនការនេះត្រូវបានបង្កើតឡើងដោយមានការពិភាក្សាជាមួយនាយកដ្ឋានពាក់ព័ន្ធជាច្រើន ដែលមកពីក្រសួងផ្សេងៗ ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធនានា។

---

[77] Initial National Communication, August 2002; Second National Communication, November 2015.

[78] ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ២០១៦-២០១៨ ក្រសួងបរិស្ថាន អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ខែមករា ឆ្នាំ២០១៦។

ផលដែលគេអាចទទួលបានពីការអនុវត្តសម្មភាពនេះមានដូចជាៈ

- ការយល់ដឹងជាសាធារណៈ អំពីបញ្ហាបម្រែបម្រួលអាកាសធាតុ
- ការពង្រឹងសមត្ថភាពស្ថាប័ននិងការបញ្ជ្រាបបញ្ហានៃការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការនៅថ្នាក់ជាតិ និងក្រោមជាតិ
- ការពង្រឹងភាពធនរបស់សហគមន៍
- ការរួមចំណែកកាន់តែធំឡើងដល់ការប្រឹងប្រែងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាមួយការកើនឡើងនៃបរិមាណឥណទានកាបូនទទួលបានមកពីគម្រោងកាត់បន្ថយកាបូបនៅព្រះរាជាណាចក្រកម្ពុជា។

ដើម្បីសម្រេចឲ្យបាននូវលទ្ធផលរំពឹងទុកខាងលើ ផែនការសកម្មភាពនេះបានដាក់ចេញនូវវិធានការទាំង១៧ នៅក្នុងផែនការសកម្មភាពនេះដែលមានដូចជាៈ

១. មជ្ឈមណ្ឌលបច្ចេកវិទ្យាសម្រាប់សន្តិសុខស្បៀង ទឹក និងថាមពល
២. ការវិភាគភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ
៣. វិធានការបន្សាំសម្រាប់តំបន់ការពារធម្មជាតិ
៤. ប្រព័ន្ធគណនេយ្យមូលធនធម្មជាតិ
៥. ប្រព័ន្ធសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់
៦. ឥណទានកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់
៧. កម្មវិធីនិងផែនការអភិវឌ្ឍន៍ទីក្រុងដែលឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
៨. ប្រព័ន្ធគ្រប់គ្រងចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ
៩. មេរៀនអប់រំស្តីអំពីការប្រែប្រួលអាកាសធាតុ
១០. ការលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុជាសាធារណៈ
១១. ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការនៅថ្នាក់ក្រោមជាតិ
១២. ប្រព័ន្ធត្រួតពិនិត្យនិងតាមដានអំពីការប្រែប្រួលអាកាសធាតុ
១៣. ការអភិវឌ្ឍសមត្ថភាពសម្រាប់យន្តការសម្របសម្រួលការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ
១៤. ការផ្តល់ឥណទានឥតសំណងសម្រាប់អនុវត្តវិធានការឆ្លើយតបនឹងអាកាសធាតុ
១៥. ក្របខ័ណ្ឌច្បាប់ស្តីពីការប្រែប្រួលអាកាសធាតុ
១៦.ក្របខ័ណ្ឌជាតិស្តីពិហិរញ្ញវត្ថុកាបូន
១៧. ការធ្វើរបាយការណ៍ដាក់ជូនអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

សកម្មភាពដែលបានដាក់ចេញខាងលើនេះទាមទារឲ្យមានការសហប្រតិបត្តិការពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ដើម្បីធានាឲ្យបាននូវលទ្ធផលប្រកបដោយនិរន្តរភាព។ បន្ថែមពីលើនេះដើម្បីអនុវត្តសកម្មភាពទាំងនេះក៏ទាមទារឲ្យមាននូវការផ្តល់ជាមូលនិធិ និងធនធានផ្សេងៗទៀត រួមទាំងបច្ចេកទេស និងបច្ចេកវិទ្យាផងដែរ។[79]

### ៣.២.១.២ សកម្មភាពដែលរដ្ឋាភិបាលបានធ្វើកន្លងមក

**ក. ការបន្សាំ**

ដោយសារបញ្ហាបម្រែបម្រួលអាកាសធាតុប៉ះពាល់ដល់វិស័យជាច្រើនរបស់ជាតិ ដែលក្នុងនោះវិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ ព្រៃឈើ សុខភាពមនុស្ស តំបន់ដែលនៅជាប់ឆ្នេរជាវិស័យដែលរងឥទ្ធិពលខ្លាំងជាងគេ។[80]

- វិស័យកសិកម្មៈ ដោយសារកសិកម្មក្នុងប្រទេសកម្ពុជានៅពឹងផ្អែកច្រើនលើរបបទឹកភ្លៀង និងប្រភពទឹកពីបឹងទន្លេសាប និងទន្លេផ្សេងៗ ដូច្នេះវិស័យនេះគឺពឹងផ្អែកយ៉ាងសំខាន់លើអាកាសធាតុតំបន់ និងរបបខ្យល់។
- វិស័យហេដ្ឋារចនាសម្ព័ន្ធៈ ហេដ្ឋារចនាសម្ព័ន្ធអាចងាយរងគ្រោះដោយសារផលប៉ះពាល់នៃទឹកជំនន់ដែលបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ ដែលបង្កឲ្យមានការខូចខាតផ្លូវ ប្រព័ន្ធផ្លូវទឹក ស្ពានជាដើម។
- វិស័យព្រៃឈើៈ នៅឆ្នាំ២០៥០ ព្រៃឈើនៅតំបន់ទំនាបជាពិសេសនៅភាគឥសាន្ត និងនិរតីជាតំបន់ងាយនឹងរងគ្រោះ ហើយប្រែជាតំបន់ស្ងួតដោយកង្វះទឹក។[81]
- សុខភាពរបស់ប្រជាជនៈ បម្រែបម្រួលអាកាសធាតុអាចជះឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោល។ ឥទ្ធិពលផ្ទាល់គឺមានដូចជា ការស្លាប់ ការរងរបួស ភាពមិនប្រក្រតីផ្លូវអារម្មណ៍ និងការប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធសុខភាពសាធារណៈ។ ឯឥទ្ធិពលមិនផ្ទាល់វិញមានដូចជាជំងឺឆ្លងកង្វះអាហារូបត្ថម្ភ ភាពស្រេកឃ្លានដែលជាលទ្ធផលនៃការរាំងប្រព័ន្ធអេកូឡូស៊ី ។
- តំបន់ជាប់ឆ្នេរៈ ធនធាននៅតំបន់ឆ្នេរបានរងឥទ្ធិពលរួចមកហើយដែលមកពីការនេសាទហួសប្រមាណ ការបំផ្លាញធនធានព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ីនៅតំបន់កោកកាងដែលឆ្ពោះទៅរក

---

[79] ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ២០១៦-២០១៨ ក្រសួងបរិស្ថាន អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ខែមករា ឆ្នាំ២០១៦ ទំព័រ១២។

[80] ក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា, *Cambodia's Initial National Communication to the UNFCCC* [របាយការណ៍លើកទី១ របស់កម្ពុជាសម្រាប់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ], (សីហា ២០០២) ។

[81] ដូចខាងលើ។

ការវិនាស។ បម្រែបម្រួលអាកាសធាតុក៏បន្ថែមឥទ្ធិពលដល់កំនើននីវ៉ូទឹកសមុទ្រ ការជន់លិច និងការធ្លាក់ចុះនៃបរិមាណទឹកស្អាតដែលអាចបរិភោគបានផងដែរ។

កម្ពុជាបានជ្រើសរើសយកវិស័យអាទិភាពទាំងនេះក្នុងការធ្វើសកម្មភាពទាក់ទងទៅនឹងការបន្ស៊ាំខ្លួននឹងបម្រែបម្រួលអាកាសធាតុ ដែលដូចជា៖

- ការលើកកម្ពស់ និងបង្កើនសមត្ថភាពរបស់សហគមន៍ទប់ទល់នឹងបម្រែបម្រួលអាកាសធាតុតាមរយៈសកម្មភាពបន្ស៊ាំតាមសហគមន៍ ការស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ី
- ការអនុវត្តវិធីសាស្ត្រគ្រប់គ្រងនៅតាមតំបន់ការពារ
- ពង្រឹងប្រព័ន្ធប្រកាសសញ្ញានិងព័ត៌មាន
- អភិវឌ្ឍប្រព័ន្ធធារាសាស្ត្រសម្រាប់វិស័យកសិកម្ម និងការអភិវឌ្ឍទីក្រុង
រាជរដ្ឋាភិបាលកម្ពុជាបានឲ្យតម្លៃខ្ពស់ទៅលើការអភិវឌ្ឍបៃតង ដើម្បីធានាបាននូវតុល្យភាពរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌។ ការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង ដើម្បីកាត់បន្ថយភាពក្រីក្រ បង្កើនកំណើនសេដ្ឋកិច្ច កិច្ចការពារបរិស្ថាននិងគ្រប់គ្រងធនធានធម្មជាតិ ការរីកចម្រើនលូតលាស់និងសុវត្ថិភាពសង្គម និងរក្សាតម្លៃវប្បធម៌ជាតិ។

# សន្ទានុក្រម

**កសិកម្មបៃតង** សំដៅដល់ផលិតកម្មកសិកម្មដែលប្រើបច្ចេកទេសនិងបច្ចេកវិទ្យាដែលមិនបង្កការខូចខាតដល់បរិស្ថាន និងមិនប៉ះពាល់ដល់អាយុជីវិតមនុស្ស សត្វ ដោយប្រើតែសារធាតុសរីរាង្គ(គ្មានសារធាតុគីមី)ដូចជាជីសរីរាង្គ ពូជដំណាំសរីរាង្គ និងធនធានរូបសាស្ត្រសរីរាង្គ(ទឹក ដី ខ្យល់ ភូគព្ភសាស្ត្រ ធម្មជាតិ) សម្រាប់ផលិតកម្មកសិកម្មនិងការបង្កបង្កើនផល។ កសិកម្មបៃតងគឺជួយលើកកម្ពស់សេដ្ឋកិច្ចបៃតង កសិឧស្សាហកម្មបៃតងនិងទេសចរណ៍បៃតង (ទេសចរណ៍ធម្មជាតិឬអេកូទេសចរណ៍)។

**គមនាគមន៍បៃតង** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ទូរគមនាគមន៍ និងបណ្តាញថាមពលអគ្គិសនីដែលជួយលើកកម្ពស់ដល់បរិស្ថានបៃតង ដូចជាផ្លូវរថភ្លើង ផ្លូវរថយន្តក្រុងដឹកអ្នកដំណើរ ផ្លូវនាវាចរណ៍ បណ្តាញខ្សែកាបអុបទិក ប្រព័ន្ធផ្កាយរណប បណ្តាញខ្សែបញ្ជូនអគ្គិសនី។

**គោលការណ៍អភិវឌ្ឍន៍បៃតង** សំដៅដល់ការអភិវឌ្ឍដែលមានលក្ខណៈបៃតង ដើម្បីធានាដល់សិទ្ធិទទួលបានពីការអភិវឌ្ឍ រួមមាន ការងារបរិស្ថានបៃតងនិងធនធានធម្មជាតិ ការងារធនធានទឹកនិងអនាម័យការងារ សន្តិសុខស្បៀងនិងសុវត្ថិភាពចំណីអាហារ ការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព ការងារសេដ្ឋកិច្ចនិងវិនិយោគ ការងារគមនាគមន៍ ការងារឧស្សាហកម្មនិងថាមពល និងការងារទេសចរណ៍បៃតង។

**ថាមពលបៃតង** សំដៅដល់ប្រសិទ្ធភាពថាមពល ពិសេសការផលិត និងការប្រើប្រាស់ថាមពលកកើតឡើងវិញ ដូចជាថាមពលដើរដោយកម្លាំងខ្យល់ ពន្លឺព្រះអាទិត្យ កម្លាំងទឹករលក ជីវឧស្ម័ន ជីវម៉ាស់ ជីវឥន្ធនៈ និងវារីអគ្គិសនី។

**ទង់សញ្ញាបៃតង** សំដៅដល់ទង់បៃតងដែលផ្តល់ដោយក្រសួង ស្ថាប័នពាក់ពន្ធ ដើម្បីលើកទឹកចិត្តដល់សហគ្រាសវិនិយោគិន និងអ្នកប្រើប្រាស់ដោយបានការពារបរិស្ថាន សុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី និងធានាបានកំណើនសេដ្ឋកិច្ច ព្រមទាំងគុណភាពជីវិតជូនប្រជាជន។

**ទេសចរណ៍បៃតង** សំដៅដល់ការអភិវឌ្ឍទេសចរណ៍និងអ្នកទេសចរណ៍ដែលមិនបង្កការប៉ះពាល់ដល់និរន្តរភាពបរិស្ថានបៃតងនិងធនធានធម្មជាតិ ដោយរក្សាបាននូវសោភណភាព ទេសភាពធម្មជាតិបៃតង និងប្រព័ន្ធអេកូឡូស៊ី និងបានគិតគូរដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងរក្សាអត្តសញ្ញាណវប្បធម៌ដោយមានសុខដុមនីយកម្មរវាងការអភិវឌ្ឍ និងការអភិរក្ស ដើម្បីប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានធម្មជាតិដ៏កម្រ ដែលត្រូវបន្សល់ទុកជូនអ្នកជំនាន់ក្រោយនូវសម្បត្តិធម្មជាតិសម្រាប់អនាគតរបស់ខ្លួន។

**បច្ចេកវិទ្យាបៃតង** សំដៅដល់ប្រព័ន្ធបច្ចេកទេសនិងបច្ចេកវិទ្យាដែលមិនបង្កឲ្យមានការខូចខាតដល់បរិស្ថាន ដូចជា បច្ចេកវិទ្យាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ បច្ចេកវិទ្យាកាត់បន្ថយការសាយភាយសារធាតុបំពុលបរិស្ថាន បច្ចេកវិទ្យាសម្រាប់ប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព បច្ចេកវិទ្យាអភិវឌ្ឍន៍ស្អាត និងបច្ចេកវិទ្យាសម្រាប់ការកែច្នៃនិងការប្រើប្រាស់ឡើងវិញនូវធនធានដែលបានប្រើរួច។

**បរិស្ថានបៃតង** សំដៅដល់បរិស្ថានល្អស្អាតគ្មានជាតិពុលដែលកើតចេញពីការអភិវឌ្ឍស្អាត ការមិនបំពុលបរិស្ថានក្នុងការថែរក្សាគុណភាពទឹក គុណភាពដី និងគុណភាពខ្យល់ សុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី ការធានាបានជាអាទិ៍នូវសុវត្ថិភាពចំណីអាហារ ការគ្រប់គ្រងធនធាន ធម្មជាតិ ព្រៃឈើ ធនធានទឹក ប្រកបដោយនិរន្តរភាព ការប្រើប្រាស់ដីប្រកបដោយចីរភាព និងការលើកកម្ពស់សុខុមាលភាពសាធារណៈ ដែលជាកត្តាចម្បងក្នុងការលើកស្ទួយសេដ្ឋកិច្ចបៃតងឲ្យមានគុល្យភាពទៅនឹងចីរភាពបរិស្ថាន សង្គម និងវប្បធម៌។

**ផលិតកម្មនិងការប្រើប្រាស់ប្រកបដោយចីរភាព** សំដៅដល់ប្រសិទ្ធភាពប្រើប្រាស់ធនធានធម្មជាតិដើម្បីបំពេញសេចក្តីត្រូវការផលិតនិងប្រើប្រាស់ក្នុងសេដ្ឋកិច្ច សង្គម ដែលបន្តរក្សានិរន្តរភាពធនធានធម្មជាតិ រួមមានសុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី ការបញ្ចេញសំណល់តិច កាត់បន្ថយការបំពុល ការប្រើប្រាស់និងកែច្នៃឡើងវិញសម្រាប់តម្រូវការនាពេលបច្ចុប្បន្ននិងជំនាន់ក្រោយ។

**ពន្ធបៃតង** សំដៅដល់ពន្ធកាត់បន្ថយការបំពុលបរិស្ថាន ពន្ធបញ្ចេញសំណល់រឹងនិងរាវ ពន្ធប្រើប្រាស់ធនធានធម្មជាតិ ដែលកើតចេញពីសកម្មភាពអភិវឌ្ឍន៍ដែលបំពុលនិងបង្កគ្រោះថ្នាក់ដល់បរិស្ថាន រួមជាមួយការធ្វើអាជីវកម្មនិងការប្រើប្រាស់ធនធានធម្មជាតិ។ ការយកពន្ធបៃតងគឺដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពបរិស្ថាន។

**វិនិយោគបៃតង** សំដៅដល់គម្រោងឬសកម្មភាពវិនិយោគលើការអភិវឌ្ឍបៃតង ដោយផ្តោតលើបច្ចេកវិទ្យាបៃតង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បរិស្ថានបៃតងនិងធនធានធម្មជាតិ ធនធានទឹកនិងអនាម័យ សន្តិសុខស្បៀងនិងសុវត្ថិភាពចំណីអាហារ ការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព គមនាគមន៍ ឧស្សាហកម្មនិងថាមពល និងទេសចរណ៍បៃតង។

**សេដ្ឋកិច្ចខៀវ** សំដៅដល់សកម្មភាពសេដ្ឋកិច្ចដែលកើតចេញពីការអភិវឌ្ឍតំបន់សមុទ្រតាមគោលការណ៍អភិវឌ្ឍន៍បៃតង។

**សេដ្ឋកិច្ចបៃតង** សំដៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានធម្មជាតិចីរភាពបរិស្ថាន ការងារបៃតង បច្ចេកវិទ្យាបៃតង និងកំណែទម្រង់សេដ្ឋកិច្ច ដោយគិតគូរបន្ថែមលើការលើកទឹកចិត្តបៃតង ដូចជាពន្ធបៃតង ហិរញ្ញវត្ថុបៃតង ពិសេសឥណទានបៃតង និងមីក្រូហិរញ្ញវត្ថុបៃតងជាដើម។

**ហិរញ្ញវត្ថុបៃតង** សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដូចជា មូលប្បទានបត្រ ភាគហ៊ុន បណ្ណបំណុលជាតិ បណ្ណបំណុលក្រុមហ៊ុន បណ្ណរតនាគារ ទ្រព្យសកម្ម តម្លៃអចលនវត្ថុ ឥណទាន និងធានារ៉ាប់រង ព្រមទាំងទីផ្សារហិរញ្ញវត្ថុដែលលើកកម្ពស់ការទិញដូរផលិតផលបៃតង និងសេវាកម្មបៃតង លើកទឹកចិត្តដល់ការវិនិយោគលើវិស័យកសិកម្មបៃតង ឧស្សាហកម្មបៃតង ពាណិជ្ជកម្មបៃតង ហេដ្ឋារចនាសម្ព័ន្ធនិងការដឹកជញ្ជូនបៃតង ទេសចរណ៍បៃតង ថាមពលបៃតង សំណង់និងអគារបៃតង ទូរគមនាគមន៍បៃតង ការស្រាវជ្រាវនិងការអភិវឌ្ឍវិស័យបៃតង ជំនាញនិងបច្ចេកទេសបៃតង ស្ថាប័នបៃតង កន្លែងធ្វើការងារមានលក្ខណៈបៃតង ទីផ្សារបៃតង ការផ្សព្វផ្សាយផលិតផលបៃតង ការលក់ដូរផលិតផលនិងសេវាកម្មបៃតង ព្រមទាំងលទ្ធកម្មហិរញ្ញវត្ថុបៃតង។

**អភិវឌ្ឍន៍បៃតង** សំដៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពដែលមិនបង្កការខូចខាតដល់បរិស្ថាន ដោយផ្អែកលើការប្រើប្រាស់ធនធានធម្មជាតិតិចដែលទទួលបានទិន្នផលខ្ពស់ ប្រសិទ្ធភាពថាមពល ការបញ្ចេញសំណល់តិច ការអភិវឌ្ឍស្អាត ការថែរក្សាភាពបៃតងនិងបេតិកភណ្ឌធម្មជាតិ ព្រមទាំងការបង្កើនជីវភាពរស់នៅរបស់ប្រជាជន ដើម្បីសម្រេចបាននូវគុណភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចជាមួយនឹងនិរន្តរភាពបរិស្ថាន ដែលជាឧត្តមប្រយោជន៍ដល់សង្គមទាំងមូល។

**អភិវឌ្ឍន៍ប្រកបដោយចីរភាព** សំដៅដល់ការអភិវឌ្ឍដែលនាំមកនូវការរីកចម្រើនសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាពបរិស្ថាន ដោយផ្អែកលើគុណភាពនៃបង្គោលគ្រឹះ០៤ គឺ សេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌។

**ឧស្សាហកម្មបៃតង** សំដៅដល់ផលិតកម្មស្អាតដែលប្រើប្រាស់បច្ចេកវិទ្យាបៃតង ថាមពលប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងខ្សែចង្វាក់ផលិតកម្មនៃសហគ្រាសធុនតូច មធ្យម និងធំ ដើម្បីធានាដល់និរន្តរភាពធនធានធម្មជាតិដោយអនុវត្តគោលការណ៍ផលិតកម្មនិងការប្រើប្រាស់ប្រកបដោយចីរភាព។

# ឧបសម្ព័ន្ធ 1: បញ្ជីសកម្មភាពទាក់ទងនឹងការប្រែប្រួលសកម្មភាព

| យុទ្ធសាស្ត្រអាទិភាព និងចង្កោមសកម្មភាព | | អង្គភាពប្រតិបត្តិ | អង្គភាពសហការអនុវត្តន៍ | តម្រូវការវិនិយោគសរុប (១.000ដុល្លារ) | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
| | | | | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ |
| **យុទ្ធសាស្ត្រអាទិភាពទី១៖** កិច្ចគាំពារបរិស្ថាន | | | | | | | | | | | | | |
| ១.១ | ការគ្រប់គ្រងសំណល់រឹង-រាវ តាមរាជធានី ទីក្រុង និងទីប្រជុំជនតាមវិធានការចម្រុះ និងការគ្រប់គ្រងសំណល់សត្វ។ | ន/ដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន | | **១០** | | **១២៤០** | | **១៧៥** | | **១៦៥** | | **១១០** | |
| ១.១.១ | រៀបចំលិខិតបទដ្ឋានគតិយុត្តិ និងយុទ្ធសាស្ត្រថវិកាសម្រាប់ការគ្រប់គ្រងសំណល់ រឹង-រាវ តាមរាជធានីទីក្រុង និងទីប្រជុំជន។ | ន/ដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន | មន្ទីរបរិស្ថាន/អាជ្ញាធរដែនដី | ០ | | ១៣០ | | ៣០ | | ៣០ | | ៣០ | |
| ១.១.២ | រៀបចំ និងអនុវត្តផែនការសកម្មភាព៥ឆ្នាំ២០១៥-២០២០ សម្រាប់គម្រោងអាទិភាពស្តីពីការគ្រប់ គ្រងសំណល់ រឹង-រាវ តាមរាជធានី ទីក្រុង និងទីប្រជុំជនតាមវិធានការចម្រុះ និងការគ្រប់គ្រងសំណល់សត្វ។ | ន/ដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន | មន្ទីរបរិស្ថានខេត្ត | ០ | | ១០ | | ១០ | | | | | |
| ១.២ | បញ្ជូលបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ | ន/ដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | | **៥៤,៤** | | **៦៩,៦** | | **៧០,៦** | | **៩៩,៦** | | **៧១,៦** | |
| ១.២.១ | រៀបចំលិខិតបទដ្ឋានគតិយុត្តិស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ | ន/ដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | មន្ទីរបរិស្ថាន | ២០ | | ៣០ | | ២០ | | ២០ | | | |
| ១.២.២ | រៀបចំ និងអនុវត្តផែនការសកម្មភាព៥ឆ្នាំ២០១៥-២០២០ សម្រាប់គម្រោងអាទិភាពស្តីពី ការវាយ តម្លៃហេតុប៉ះពាល់បរិស្ថាន | ន/ដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន | មន្ទីរបរិស្ថាន និងស្ថាប័នពាក់ព័ន្ធ | ១៣ | | ១២ | | ១២ | | ១២ | | ១២ | |
| **យុទ្ធសាស្ត្រអាទិភាពទី២៖** ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍដោយចីរភាព | | | | | | | | | | | | | |
| ២.១ | បញ្ជូលការប្រែប្រួលអាកាសធាតុទៅក្នុងផែនការ គ្រប់គ្រងតំបន់ការពារធម្មជាតិ | អគ្គន/ដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | | **១០** | | **២.៤៦៥** | | **២.៤៦៤** | | **២.៤៦៦** | | **២.៤៥៤** | |
| ២.១.១ | រៀបចំ និងអនុវត្តផែនការសកម្មភាព៥ឆ្នាំ២០១៥-២០២០ សម្រាប់គម្រោងអាទិភាពស្តីពីការគ្រប់គ្រងតំបន់ការពារធម្ម | ន/ដ្ឋានអនុសញ្ញាអន្តរជាតិ និងជីវៈចម្រុះ | នាយកដ្ឋានផែនការនិងកិច្ចការច្បាប់ | ០ | | ១៥ | | ១៥ | | ១៥ | | ១៥ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ជាតិ | | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| ២.១.៣ | កំណត់ទីតាំងដែលមានសក្តានុពល និងតម្រូវការសម្រាប់បង្កើតបន្ថែមនូវតំបន់ការពារធម្មជាតិមានរូបភាពជា តំបន់ដីសើម និងជីវៈចម្រុះ ទប់ទល់និងបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ។ | នាយកដ្ឋានតំបន់ដីសើមនិងតំបន់ឆ្នេរ | ន/ដ្ឋានវាយតម្លៃធនធានធម្មជាតិ ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ០ | | ២០ | | ២០ | | ២០ | | ២០ | |
| ២.១.៣ | កំណត់ទីតាំងដែលមានសក្តានុពល និងតម្រូវការសម្រាប់បង្កើតបន្ថែមនូវតំបន់ការពារធម្មជាតិមានរូបភាពជាឧទ្យានទប់ទល់និងបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានឧទ្យានជាតិ | ន/ដ្ឋានវាយតម្លៃធនធានធម្មជាតិ ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ១០ | | ១១ | | ១០ | | ១២ | | ០ | |
| ២.១.៤ | រៀបចំផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិដោយបញ្ចូលសមត្ថភាពបន្សុំារបស់ប្រជាសហគមន៍ បណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានស្រាវជ្រាវ និងអភិសហគមន៍ តំបន់ការពារធម្មជាតិ | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ០ | | ២.៤១៩ | | ២.៤១៩ | | ២.៤១៩ | | ២.៤១៩ | |
| **២.២** | **អនុវត្តន៍វិធានការគ្រប់គ្រង និងការពារតំបន់ការពារធម្មជាតិបន្សុំាការប្រែប្រួលអាកាសធាតុ** | | | **០** | | **៦០** | | **៦០** | | **៦០** | | **៦០** | |
| ២.២.១ | កំណត់ប្រភេទជីវចម្រុះ ដែលងាយរងការប្រែប្រួល និងងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ និងជម្រើសជាអាទិភាពសម្រាប់ការគ្រប់គ្រងនាពេលអនាគត និងបន្ថែមក្នុងយុទ្ធសាស្ត្របន្សុំាដែលមានស្រាប់ | ន/ដ្ឋានអនុសញ្ញាអន្តរជាតិ និងជីវចម្រុះ | ន/ដ្ឋានចំណុះអគ្គន/ដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | ០ | | ១០ | | ១០ | | ១០ | | ១០ | |
| ២.២.២ | ធ្វើឱ្យប្រសើរឡើងនូវភាពបន្សុំារបស់សហគមន៍តំបន់ការពារធម្មជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ | នាយកដ្ឋានស្រាវជ្រាវនិងអភិវឌ្ឍសហគមន៍ | ន/ដ្ឋានចំណុះអគ្គន/ដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | ០ | | ៣៩,៥០ | | ៣៩,៥០ | | ៣៩,៥០ | | ៣៩,៥០ | |
| ២.២.៣ | ធ្វើឱ្យប្រសើរឡើងនូវកិច្ចការពារសង្គមសម្រាប់សហគមន៍តំបន់ការពារធម្មជាតិ។ | នាយកដ្ឋានស្រាវជ្រាវនិងអភិវឌ្ឍសហគមន៍ | ន/ដ្ឋានចំណុះអគ្គន/ដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | ០ | | ១០,៥០ | | ១០,៥០ | | ១០,៥០ | | ១០,៥០ | |
| **២.៣** | **អនុវត្តន៍វិធានការទប់ស្កាត់ និងស្តារឡើងវិញដើម្បីបង្កើនភាពបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ** | | | **០** | | **២៥** | | **២៥** | | **២៥** | | **២៥** | |
| ២.៣.១ | ជំរុញការស្តារឡើងវិញតាមបែបធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិធ្វើជាមធ្យោបាយក្នុងការបង្កើនភាពបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានអនុសញ្ញាអន្តរជាតិ និងជីវចម្រុះ | ន/ដ្ឋានចំណុះអគ្គន/ដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | ០ | | ១៥ | | ១៥ | | ១៥ | | ១៥ | |
| ២.៣.២ | កំណត់ប្រភេទពូជរាតត្បាតដែលមាននឹងការរីកលូតលាស់របស់វានៅពេលដែលមានការប្រែប្រួលអាកាសធាតុ។ អភិវឌ្ឍន៍ | ន/ដ្ឋានអនុសញ្ញាអន្តរជាតិ និងជីវចម្រុះ | លេខាធិការដ្ឋានជីវសុវត្ថិភាព | ០ | | ១០ | | ១០ | | ១០ | | ១០ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បច្ចេកទេសឱ្យបានសមស្របសម្រាប់ការកំណត់អត្តសញ្ញាណ ការត្រួតពិនិត្យ និងការគ្រប់គ្រង។ | | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| **២.៤** | **ជំរុញ និងធ្វើឱ្យប្រសើរឡើងដល់សមត្ថភាពបន្សាំរបស់សហគមន៍ និងស្ថាប័នប្រព័ន្ធធម្មជាតិឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។** | | | **៥៦** | | **៥០** | | **៥០** | | **៦០** | | **០** | |
| ២.៤.១ | គ្រប់គ្រង និងអភិរក្សតំបន់ការពារធម្មជាតិ និងធ្វើឱ្យប្រសើរឡើងនូវតំបន់ការពារជីវចម្រុះនានា។ | ន/ដ្ឋានឧទ្យានជាតិ | ន/ដ្ឋានចំណុះអគ្គន/ដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | ៥៦ | | ៥០ | | ៥០ | | ៦០ | | ០ | |
| **២.៥** | **ផ្តល់ចំណេះដឹងវិទ្យាសាស្ត្រអំពីការប្រែប្រួលអាកាសធាតុដល់ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសហគមន៍** | | | **៣០** | | **៣៤** | | **៣២** | | **៣២** | | **០** | |
| ២.៥.១ | សិក្សាស្រាវជ្រាវពីសារតាបរិស្ថាននៃឧទ្យានជាតិ ដែនជម្រកសត្វព្រៃតំបន់ដីសើម ទីជម្រាល តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់ឆ្នេរ និងតំបន់ការពារបេតិកភ័ណ្ឌ។ | ន/ដ្ឋានឧទ្យានជាតិ | ន/ដ្ឋានវាយតម្លៃធនធានធម្មជាតិ | ៣០ | | ៣៤ | | ៣២ | | ៣២ | | ០ | |
| **យុទ្ធសាស្ត្រអាទិភាពទី៣៖**<br>**ការអភិវឌ្ឍបៃតងជាតិ និងការប្រែប្រួលអាកាសធាតុ** | | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | | | | | | | | | | | |
| **៣.១** | **ការគាំពារកិច្ចការរដ្ឋបាលទូទៅ** | | | **០** | | **៤០២** | | **៤០២** | | **៤០២** | | **៤០២** | |
| ៣.១.១ | បន្ទុកបុគ្គលិក។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | | ០ | | ៣១៤ | | ៣១៤ | | ៣១៤ | | ៣១៤ | |
| ៣.១.២ | បន្ទុកក្រៅបុគ្គលិក។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | | ០ | | ៨៨ | | ៨៨ | | ៨៨ | | ៨៨ | |
| **៣.២** | **ការអភិវឌ្ឍបរិស្ថានបៃតង និងធនធានធម្មជាតិ** | | | **០** | | **១៩២** | | **១៩២** | | **១៩២** | | **១៩២** | |
| ៣.២.១ | កសាងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការអភិវឌ្ឍបៃតង។ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសធាតុ និងន/ដ្ឋានផែនការនិងកិច្ចការច្បាប់ | ០ | | ១៥ | | ១៥ | | ១៥ | | ១៥ | |
| ៣.២.២ | ផ្សព្វផ្សាយគោលនយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងបរិស្ថានបៃតង និងធនធានធម្មជាតិ។ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ១៨ | | ១៨ | | ១៨ | | ១៨ | |
| ៣.២.៣ | បណ្តុះបណ្តាលបច្ចេកទេសអភិវឌ្ឍបៃតង និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ២៨ | | ២៨ | | ២៨ | | ២៨ | |
| ៣.២.៤ | រៀបចំសន្និសីទ វេទិកា សិក្ខាសាលា និងកិច្ចប្រជុំនានាពាក់ព័ន្ធនឹងការអភិវឌ្ឍបៃតង។ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ១០៣ | | ១០៣ | | ១០៣ | | ១០៣ | |
| ៣.២.៥ | សិក្សា និងស្រាវជ្រាវសក្តានុពល និងប្រសិទ្ធិភាពនៃការអនុ | អគ្គលេខាធិការដ្ឋានជាតិ | ន/ដ្ឋានប្រែប្រួល អាកាស | ០ | | ១៧ | | ១៧ | | ១៧ | | ១៧ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វត្តអភិវឌ្ឍន៍បៃតង។ | អភិវឌ្ឍន៍បៃតង | ជាតុ | | | | | | | | | | |
| ៣.២.៦ | តាមដាន និងវាយតម្លៃការអនុវត្តបច្ចេកទេសអភិវឌ្ឍបៃតង។ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសជាតុ | ០ | | ១១ | | ១១ | | ១១ | | ១១ | |
| **៣.៣** | **ការអភិវឌ្ឍសេដ្ឋកិច្ច និងវិនិយោគបៃតង** | | | **០** | | **៨១** | | **៨១** | | **៨១** | | **៨១** | |
| ៣.៣.១ | រៀបចំគោលការណែនាំពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងវិនិយោគបៃតង។ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសជាតុ | ០ | | ១៧ | | ១៧ | | ១៧ | | ១៧ | |
| ៣.៣.២ | ផ្សព្វផ្សាយគោលនយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការអភិវឌ្ឍបៃតង។ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសជាតុ | ០ | | ១១ | | ១១ | | ១១ | | ១១ | |
| ៣.៣.៣ | បណ្តុះបណ្តាលបច្ចេកទេសអភិវឌ្ឍបៃតង និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសជាតុ | ០ | | ២៨ | | ២៨ | | ២៨ | | ២៨ | |
| ៣.៣.៤ | រៀបចំកិច្ចប្រជុំ និងវាទិកាពិគ្រោះយោបល់នានាពាក់ព័ន្ធ នឹងការអភិវឌ្ឍបៃតងជាមួយវិស័យឯកជន | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសជាតុ | ០ | | ៨ | | ៨ | | ៨ | | ៨ | |
| ៣.៣.៥ | សិក្សាវាយតម្លៃប្រសិទ្ធិភាពនៃការប្រតិបត្តិសេដ្ឋកិច្ច និងវិនិយោគបៃតង។ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសជាតុ | ០ | | ៦ | | ៦ | | ៦ | | ៦ | |
| ៣.៣.៦ | តាមដាន និងវាយតម្លៃការអភិវឌ្ឍសេដ្ឋកិច្ច និងវិនិយោគបៃតង។ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ន/ដ្ឋានប្រែប្រួល អាកាសជាតុ | ០ | | ១១ | | ១១ | | ១១ | | ១១ | |
| **៣.៤** | **ការអភិវឌ្ឍបញ្ចេញកាបូនតិច** | | | **០** | **៤.៥០៦** | **៥២,៥** | **១២.០៦៤** | **៥២,៥** | **១២.០៥៤** | **៥២,៥** | **៧.៥៥៨** | **៥២,៥** | **៧.៥៥៨** |
| ៣.៤.១ | កែលម្អសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យ។ (គម្រោង៖ រៀបចំប្រព័ន្ធសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ជាតិនៅកម្ពុជា) | ន/ដ្ឋានប្រែប្រួល អាកាសជាតុ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ០ | ១០០ | ២ | ១០០ | ២ | ៩០ | ២ | | ២ | |
| ៣.៤.២ | សិក្សា និងវាយតម្លៃលើសក្តានុពលនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ | ន/ដ្ឋានប្រែប្រួល អាកាសជាតុ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ០ | | ២ | | ២ | | ២ | | ២ | |
| ៣.៤.៣ | រៀបចំរបាយការណ៍ពីរឆ្នាំម្តង (Biennial Update Report)។ | ន/ដ្ឋានប្រែប្រួល អាកាសជាតុ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ០ | ៤.៤០៦ | ១០ | ៤.៤០៦ | ១០ | ៤.៤០៦ | ១០ | | ១០ | |
| ៣.៤.៤ | រៀបចំ និងកែសម្រួលជាប្រចាំនូវ សកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់សមស្របថ្នាក់ជាតិ(NAMA)។ | ន/ដ្ឋានប្រែប្រួល អាកាសជាតុ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ០ | | ២០ | | ២០ | | ២០ | | ២០ | |
| ៣.៤.៥ | បញ្ជ្រាបវិធានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងផែនការថ្នាក់ជាតិ ក្រោមជាតិ និងតាមវិស័យ។ (គម្រោង៖ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមរយៈការជំរុញការប្រើប្រាស់ឡជីវម៉ាសពាណិជ្ជកម្ម) | ន/ដ្ឋានប្រែប្រួល អាកាសជាតុ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ០ | | ១៥ | ២.៤៣៣ | ១៥ | ២.៤៣៣ | ១៥ | ២.៤៣៣ | ១៥ | ២.៤៣៣ |
| ៣.៤.៦ | បង្កើត និងដាក់ឱ្យដំណើរការប្រព័ន្ធចុះបញ្ជីថ្នាក់ជាតិ និងយន្តការគ្រប់គ្រងឥណទានកាបូន សម្រាប់សកម្មភាពកាត់ | ន/ដ្ឋានប្រែប្រួល អាកាសជាតុ | អគ្គលេខាធិការដ្ឋានជាតិ អភិវឌ្ឍន៍បៃតង | ០ | | ១,៥០ | | ១,៥០ | | ១,៥០ | | ១,៥០ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ | | | | | | | | | | | | |
| ៣.៤.៧ | សម្របសម្រួលការអនុវត្តវិធានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យពាក់ព័ន្ធ។ (គម្រោង៖ កសាងប្រព័ន្ធបន្សាំនៅតំបន់ទីក្រុងតាមរយៈការបន្សាំស្ថានប្រព័ន្ធក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច) | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | 0 | | ១ | ៥.១២៥ | ១ | ៥.១២៥ | ១ | ៥.១២៥ | ១ | ៥.១២៥ |
| ៣.៤.៨ | តាមដាន និងវាយតម្លៃការអនុវត្តវិធានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | 0 | | ១ | | ១ | | ១ | | ១ | |
| **៣.៥** | **បន្សាំនឹងការប្រែប្រួលអាកាសធាតុ** | | | **០** | **៣.៧៨៣** | **៤២** | **៤.៥៣៣** | **៤២** | **៤.៥៣៣** | **៤២** | **៤.៥៣៣** | **៤២** | **៤.៥៣៣** |
| ៣.៥.១ | សិក្សាវាយតម្លៃភាពងាយរងគ្រោះ និងជម្រើសបន្សាំ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | 0 | | ២ | | ២ | | ២ | | ២ | |
| ៣.៥.២ | សហការក្នុងការវាយតម្លៃលើការបាត់បង់ និងខូចខាតបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ (loss and damage)។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | 0 | | ១ | | ១ | | ១ | | ១ | |
| ៣.៥.៣ | រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងម៉ូដែលអាកាសធាតុ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | 0 | | ២ | | ២ | | ២ | | ២ | |
| ៣.៥.៤ | សម្របសម្រួលការរៀបចំ និងអនុវត្តផែនការបន្សាំជាតិ (NAP)។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | 0 | | ២០ | | ២០ | | ២០ | | ២០ | |
| ៣.៥.៥ | បញ្ជ្រាបវិធានការបន្សាំទៅក្នុងផែនការថ្នាក់ជាតិ ក្រោមជាតិ និងតាមវិស័យ (គម្រោង៖ ការពង្រឹងភាពបន្សាំរបស់ប្រជាជនទីជនបទ និងប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិចំពោះហានិភ័យ និងការប្រែប្រួលអាកាសធាតុ) | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | 0 | ៣៧៨៣ | ១៥ | ៣៧៨៣ | ១៥ | ៣៧៨៣ | ១៥ | ៣៧៨៣ | ១៥ | ៣៧៨៣ |
| ៣.៥.៦ | សម្របសម្រួល និងចូលរួមអនុវត្តវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | 0 | 0 | ១ | ៧៥០ | ១ | ៧៥០ | ១ | ៧៥០ | ១ | ៧៥០ |
| ៣.៥.៧ | តាមដាន និងវាយតម្លៃការអនុវត្តវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | 0 | | ១ | | ១ | | ១ | | ១ | |
| **៣.៦** | **ការសម្របសម្រួល និងអភិវឌ្ឍន៍សមត្ថភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ** | | | **១៦០** | **៧៤០** | **៣០៣** | **២.៤៩២** | **៣០៣** | **៣.៣៥០** | **៣០៣** | **៣.២០៣** | **៣០៣** | **២.៣០០** |
| ៣.៦.១ | សហការជាមួយស្ថាប័នអប់រំ ក្នុងការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សា។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | 0 | | ២០ | | ២០ | | ២០ | | ២០ | |
| ៣.៦.២ | ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងពាក់ព័ន្ធការងារប្រែប្រួលអាកាសធាតុ រួមទាំងការបង្កើតមជ្ឈមណ្ឌលគ្រប់គ្រងចំណេះដឹង។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | 0 | | ៤០ | | ៤០ | | ៤០ | | ៤០ | |
| ៣.៦.៣ | កសាងសមត្ថភាពមន្ត្រីអង្គភាពប្រែប្រួលអាកាស ធាតុ នៅ | ន/ដ្ឋានប្រែប្រួល អាកាស | អគ្គលេខាធិការដ្ឋានជាតិ | 0 | | ៣០ | | ៣០ | | ៣០ | | ៣០ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | តាមក្រសួង/ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ | ជាតុ | អភិវឌ្ឍន៍បៃតង | | | | | | | | | | |
| ៣.៦.៤ | សម្របសម្រួល និងចូលរួមរៀបចំគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងផែនការពាក់ព័ន្ធនឹងការងារប្រែប្រួល អាកាសធាតុ ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ១០ | | ១០ | | ១០ | | ១០ | |
| ៣.៦.៥ | ពង្រឹងក្របខ័ណ្ឌស្ថាប័នជាតិ និងការសម្របសម្រួលអន្តរស្ថាប័នទទួលបន្ទុកការងារប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ១០ | | ១០ | | ១០ | | ១០ | |
| ៣.៦.៦ | វាយតម្លៃនិងជំរុញការអនុវត្តបច្ចេកវិទ្យាសមស្រប។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ២០ | | ២០ | | ២០ | | ២០ | |
| ៣.៦.៧ | ដឹកនាំការអនុវត្តកាតព្វកិច្ចក្រោមអនុសញ្ញាប្រែប្រួលអាកាសធាតុ រួមទាំងការរៀបចំរបាយការណ៍ជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ៥ | | ៥ | | ៥ | | ៥ | |
| ៣.៦.៨ | កសាងសមត្ថភាព និងពង្រឹងប្រពន្ធ័គាំទ្រថ្នាក់ជាតិ ដល់ការអនុវត្ត និងការសម្របសម្រួលសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុរួមចំណែកដល់ការអភិវឌ្ឍឆ្ពោះទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាពនិងពឹងផ្អែកលើចំណេះដឹងជាគោល។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ក្រសួងពាក់ពន្ធ អង្គការជាតិ អន្តរជាតិ និងសហគមន៍មូលដ្ឋាន | ១៦០ | ៧៤០ | ១៦០ | ២៤៩២ | ១៦០ | ៣៣៥០ | ១៦០ | ៣២០៣ | ១៦០ | ២៣០០ |
| ៣.៦.៩ | រៀបចំ និងដាក់ឱ្យដំណើរការនូវក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ៧ | | ៧ | | ៧ | | ៧ | |
| ៣.៦.១០ | បង្កើត និងដាក់ឱ្យដំណើរការនូវក្របខ័ណ្ឌជាតិសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ១ | | ១ | | ១ | | ១ | |
| ៣.៦.១១ | ចូលរួមរៀបចំវេទិកាបរិស្ថានជាតិប្រចាំឆ្នាំ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ១០០ | | ១០០ | | ១០០ | | ១០០ | |
| ៣.៦.១២ | ចូលរួមក្នុងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងថ្នាក់អន្តរជាតិលើការងារប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ៦០ | | ៦០ | | ៦០ | | ៦០ | |
| | **<u>យុទ្ធសាស្ត្រអាទិភាពទី៤៖</u>**<br>**ការអប់រំ និងផ្សព្វផ្សាយបរិស្ថាន** | **ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន** | | | | | | | | | | | |
| **៤.១** | **ការអប់រំបរិស្ថានក្នុងប្រព័ន្ធ** | | | **<u>១០០</u>** | | **<u>២០០</u>** | | **<u>២០០</u>** | | **<u>២០០</u>** | | **<u>២០០</u>** | |
| ៤.១.១ | បញ្ជ្រាបការងារអប់រំនិងខ្លឹមសារ/បញ្ហាបរិស្ថាន (បញ្ញតិបរិស្ថានទូទៅ ជីវៈចម្រុះ ការប្រែប្រួលអាកាសធាតុ បញ្ហាបំពុល ...ល។) ទៅក្នុងកម្មវិធីសិក្សាគ្រប់ភូមិសិក្សា(ចាប់ពី | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | ន/ដ្ឋានប្រែប្រួលអាកាសធាតុ, ន/ដ្ឋានជីវៈចម្រុះ/នាយកដ្ឋាន C | ២០ | | ៥០ | | ៥០ | | ៥០ | | ៥០ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថ្នាក់មធ្យមសិក្សា រហូតដល់ឧត្តមសិក្សា)។ | | | | | | | | | | | | |
| ៤.១.២ | សម្របសម្រួលនិងចលនាអនុវត្តសាលាមេត្រីបរិស្ថានគ្រប់ភូមិសិក្សានៅតាមរាជធានី-ខេត្ត រួមបញ្ចូលទាំងការរៀបចំក្លឹបបរិស្ថាននតាមសាលារៀន។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | | ២០ | | ៥០ | | ៥០ | | ៥០ | | ៥០ | |
| ៤.១.៣ | រៀបចំផលិត និងបោះពុម្ពផ្សាយឯកសារ-ឧបទេសអប់រំបរិស្ថាន (ឯកសារបោះពុម្ពផ្សាយ ឯកសារសោត-ទស្សន៍ និងសម្ភារៈឧបទេស) សម្រាប់គាំទ្រដល់ការងារអប់រំបរិស្ថានក្នុងប្រព័ន្ធ។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | នាយកដ្ឋានពាក់ព័ន្ធនានា | ២០ | | ៣០ | | ៣០ | | ៣០ | | ៣០ | |
| ៤.១.៤ | រៀបចំវគ្គបណ្តុះបណ្តុះបរិស្ថាន (បញ្ញតិបរិស្ថានទូទៅ ជីវៈចម្រុះ ការប្រែប្រួលអាកាសធាតុ បញ្ហាបំពុល ...ល។) ដល់គ្រូឧទេសនៅសាលាគរុកោសល្យ និងវិក្រឹតិការ។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | ន/ដ្ឋានប្រែប្រួលអាកាសធាតុ, ន/ដ្ឋានជីវៈចម្រុះ/នាយកដ្ឋាន C | ២០ | | ៤០ | | ៤០ | | ៤០ | | ៤០ | |
| ៤.១.៥ | រៀបចំវគ្គបណ្តុះបណ្តុះបរិស្ថាន (បញ្ញតិបរិស្ថានទូទៅ ជីវៈចម្រុះ ការប្រែប្រួលអាកាសធាតុ បញ្ហាបំពុល ...ល។) ដល់គ្រូឧទេស នៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | ន/ដ្ឋានប្រែប្រួលអាកាសធាតុ, ន/ដ្ឋានជីវៈចម្រុះ/នាយកដ្ឋាន C | ២០ | | ៣០ | | ៣០ | | ៣០ | | ៣០ | |
| **៤.២** | **ការងារអប់រំបរិស្ថានក្រៅប្រព័ន្ធ** | | | **១២០** | | **១៤០** | | **១៤០** | | **១៤០** | | **១៦០** | |
| ៤.២.១ | រៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងពីបញ្ហាការប្រែប្រួលអាកាសនិងវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុតាមសហគមន៍ ឬសាលារៀន...ល។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ២០ | | ២០ | | ២០ | | ២០ | | ៣០ | |
| ៤.២.២ | ផលិតឯកសារ (ទស្សនាវដ្តីកូនសៀវភៅបរិស្ថាន ...ល។) សម្រាប់ចុះអប់រំនិងលើកកម្ពស់ការយល់ដឹងពីបរិស្ថានដល់សិស្ស-និស្សិតនិងសាធារណជន | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | | ២០ | | ២០ | | ២០ | | ២០ | | ៣០ | |
| ៤.២.៣ | រៀបចំវេទិកាយុវជនប្រកួតពិភាក្សាបញ្ហាបរិស្ថានប្រចាំឆ្នាំ (រួមបញ្ចូលបញ្ញត្តិ និងដំណោះស្រាយលើបញ្ហាប្រែប្រួលអាកាសធាតុ)។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ៦០ | | ៦០ | | ៦០ | | ៦០ | | ៦០ | |
| ៤.២.៤ | លើកកម្ពស់ការយល់ដឹងរបស់មហាជនស្តីពីការប្រើប្រាស់និងផលិតកម្មប្រកបដោយចីរភាពដើម្បីគាំទ្រដល់ផលិតផលបៃតង។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ២០ | | ៤០ | | ៤០ | | ៤០ | | ៤០ | |
| **៤.៣** | **ការបណ្តុះបណ្តាលនិងកសាងចំណេះដឹងបរិស្ថាន** | | | **៨០** | | **១៥០** | | **១៥០** | | **១៥០** | | **១៥០** | |
| ៤.៣.១ | កសាងនិងពង្រឹងសមត្ថភាពមន្ត្រីបរិស្ថានថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្តីពីជំនាញគ្រប់គ្រងបរិស្ថាន រួមបញ្ចូលទាំងការបណ្តុះបណ្តាលពីរបៀបវាយតម្លៃហានិភ័យ ភាពងាយរង | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ២០ | | ៤០ | | ៤០ | | ៤០ | | ៤០ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | គ្រោះ និងភាពបន្សាំ និងធន់ទ្រាំទៅនឹងការប្រែប្រួលអាកាសធាតុ ។ | | | | | | | | | | | | |
| ៤.៣.២ | រៀបចំកម្មវិធីសិក្សា និងរបៀបវារៈសម្រាប់ការបណ្ដុះបណ្ដាលបរិស្ថានដោយរួមបញ្ចូលទាំងបញ្ញត្តិស្ដីពីការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ២០ | | ៤០ | | ៤០ | | ៤០ | | ៤០ | |
| ៤.៣.៣ | រៀបចំវេទិកាបណ្ដុះបណ្ដាល ឬការសិក្សាពីចម្ងាយ (distance learning) តាមរយៈអត្ថបទ មេរៀន ឬខ្សែវីដេអូ online ។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | | ២០ | | ៣០ | | ៣០ | | ៣០ | | ៣០ | |
| ៤.៣.៤ | បណ្ដុះបណ្ដាលពីរបៀបធ្វើលទ្ធកម្មបៃតងដល់មន្ត្រី រាជការជាពិសេសមន្ត្រីបរិស្ថាន (ឧទ្យានជាតិ ដែន ជម្រកសត្វព្រៃ តំបន់ដីសើម ទីជម្រាល តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង និងតំបន់ការពារបេតិកភណ្ឌ និងមន្ត្រីត្រួតពិនិត្យការបំពុលបរិស្ថាន)។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាននិងន/ដ្ឋានចំណុះអគ្គន/ដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | | ២០ | | ៤០ | | ៤០ | | ៤០ | | ៤០ | |
| **៤.៤** | **ការផ្សព្វផ្សាយនិងសហប្រតិបត្តិការ** | | | **២០** | | **១៣០** | | **១៣០** | | **១៧០** | | **១៩០** | |
| ៤.៤.១ | សហការជាមួយគ្រឹះស្ថានអប់រំនានាដើម្បីផ្ដល់អាហារូបករណ៍ និងផ្ដល់ឱកាស ដល់អ្នកស្ម័គ្រចិត្តដើម្បីសិក្សាស្រាវជ្រាវ និងបម្រើការងារផ្នែកប្រែប្រួលអាកាសធាតុដើម្បីគាំទ្រដល់សេចក្ដីត្រូវការជាអាទិភាពខ្ពស់ របស់ឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ដីសើម ទីជម្រាល តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់ការពារបេតិកភណ្ឌ និងផ្នែកត្រួតពិនិត្យការបំពុលបរិស្ថាន។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន និងន/ដ្ឋានចំណុះអគ្គន/ដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ០ | | ៥០ | | ៥០ | | ៥០ | | ៥០ | |
| ៤.៤.២ | ពង្រឹងអានុភាពការងារការប្រែប្រួលអាកាសធាតុតាមរយៈយុវជនអាសាស្ម័គ្រ និងបណ្ដាញយុវជនអសាស្ម័គ្រលើការងារបរិស្ថានរួមមានកិច្ចការពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របរួមទាំងបញ្ហាឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ...ល។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | ន/ដ្ឋានប្រែប្រួលអាកាសធាតុ | ២០ | | ៤០ | | ៤០ | | ៦០ | | ៨០ | |
| ៤.៤.៣ | លើកទឹកចិត្ត និងផ្ដល់ឱកាសដល់ក្រុមយុវជនដែលមានចំណាប់អារម្មណ៍ឱ្យចូលរួមក្នុងសកម្មភាពការងារប្រែប្រួលអាកាសធាតុនានា រួមទាំងវិធានការកាត់បន្ថយ វិធានការបន្សាំ និងវិធានការធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ។ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | | ០ | | ៤០ | | ៤០ | | ៦០ | | ៦០ | |
| **យុទ្ធសាស្ត្រអាទិភាពទី៥៖** | | | | | | | | | | | | | |

| ទំនើបនីយកម្មស្ថាប័ន | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **៥.១** | **កំណត់គ្របខណ្ឌការងាររបស់លេខាធិការដ្ឋានគណៈកម្មការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុសម្រាប់សម្របសម្រួលការអនុវត្តផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ** | **លេខាធិការដ្ឋាន គ.ជ.គ.ប.អ.** | | **០** | | **១៣៥** | | **១២៣** | | **៨៨** | | **១០៨** | |
| ៥.១.១ | សម្របសម្រួលការរៀបចំការងារអនុវត្តផែនការសកម្មភាពការប្រែប្រួលអាកាសធាតុប្រកបដោយ ប្រសិទ្ធិភាពខ្ពស់ | លេខាធិការដ្ឋាន គ.ជ.គ.ប.អ. | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ១០ | | ១០ | | ០ | | ០ | |
| ៥.១.២ | ផ្តួចផ្តើម និងពង្រឹងការងារគ្រប់គ្រងផ្នែករដ្ឋបាលក្នុងដំណើរការអនុវត្តផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ | លេខាធិការដ្ឋាន គ.ជ.គ.ប.អ. | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ១៥ | | ១៥ | | ១៥ | | ១៥ | |
| ៥.១.៣ | សម្របសម្រួល និងជួយដល់ភាគីអនុវត្តផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ ក្នុងការលើកគម្រោងស្នើសុំថវិកា | លេខាធិការដ្ឋាន គ.ជ.គ.ប.អ. | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ២០ | | ២០ | | ១៥ | | ១៥ | |
| ៥.១.៤ | ទំនាក់ទំនងជាមួយអ្នកផ្តល់ជំនួយសម្រាប់ រកធនធានដើម្បីអនុវត្តផែនការសកម្មភាពការប្រែប្រួលអាកាសធាតុរបស់ភាគីទាំងអស់ | លេខាធិការដ្ឋាន គ.ជ.គ.ប.អ. | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ៨ | | ៨ | | ៨ | | ៨ | |
| ៥.១.៥ | ទំនាក់ទំនង និងតាមដានការអនុវត្តផែនការសកម្មភាពការប្រែប្រួលអាកាសធាតុរបស់ភាគីទាំងអស់ | លេខាធិការដ្ឋាន គ.ជ.គ.ប.អ. | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ២០ | | ២០ | | ២០ | | ២០ | |
| ៥.១.៦ | រៀបចំលម្អិតយុទ្ធសាស្ត្រ និងផែនការសកម្មភាពការប្រែប្រួលអាកាសធាតុសម្រាប់ថ្នាក់ក្រោមជាតិដើម្បីងាយស្រួលក្នុងការអនុវត្ត។ | លេខាធិការដ្ឋាន គ.ជ.គ.ប.អ. | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ៣០ | | ២០ | | ០ | | ០ | |
| ៥.១.៧ | ជំរុញ និងបញ្ចូលផែនការសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការបរិស្ថានជាតិ | លេខាធិការដ្ឋាន គ.ជ.គ.ប.អ. | ន/ដ្ឋានផែនការ និងកិច្ចការច្បាប់ | ០ | | ២០ | | ០ | | ០ | | ០ | |
| ៥.១.៨ | ធ្វើរបាយការណ៍ វាយតម្លៃ និងធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ | លេខាធិការដ្ឋាន គ.ជ.គ.ប.អ. | ន/ដ្ឋានផែនការ និងកិច្ចការច្បាប់ | ០ | | ៣០ | | ៣០ | | ៣០ | | ៥០ | |
| **៥.២** | **គ្រប់គ្រងទិន្នន័យជាតិការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតង** | | | **០** | | **៤៣០** | | **៣៨០** | | **១៥០** | | **១៥០** | |
| ៥.២.១ | កំណត់វិសាលភាព និងកសាងប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់គ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតង | លេខាធិការដ្ឋាន គ.ជ.គ.ប.អ | ន/ដ្ឋានប្រែប្រួលអាកាសធាតុ អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍បៃតង | ០ | | ៣០០ | | ២៥០ | | ៥០ | | ៥០ | |
| ៥.២.២ | បញ្ចូលខ្លឹមសារការប្រែប្រួលអាកាសធាតុទៅក្នុងយុទ្ធសាស្ត្រការផ្សព្វផ្សាយតាមវិស័យរបស់ជាតិ។ | លេខាធិការដ្ឋាន គ.ជ.គ.ប.អ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាន | ០ | | ១០ | | ១០ | | ១០ | | ១០ | |
| ៥.២.៣ | សមាហរណកម្មលទ្ធផលនៃការអនុវត្តផែនការសកម្មភាព | លេខាធិការដ្ឋាន | ន/ដ្ឋានប្រែប្រួល អាកាស | ០ | | | | | | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប្រែប្រួលអាកាសធាតុទៅក្នុងប្រពន្ធ័ទិន្នន័យមូលដ្ឋានរបស់ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតង | គ.ជ.គ.ប.អ | ធាតុ | | | | | | | | | | |
| ៥.២.៤ | ផ្សព្វផ្សាយលទ្ធផលក្នុងការអនុវត្តផែនការសកម្មភាពប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងប្រពន្ធ័ទិន្នន័យមូលដ្ឋានរបស់ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតងក្នុងក្របខ័ណ្ឌជាតិជូនដល់សាធារណជន | លេខាធិការដ្ឋាន គ.ជ.គ.ប.អ | ន/ដ្ឋានអប់រំ និងផ្សព្វផ្សាយបរិស្ថាននិងនាយកដ្ឋានពាក់ព័ន្ធ | ០ | | ៣០ | | ៣០ | | ៣០ | | ៣០ | |
| ៥.២.៥ | ពង្រឹងសមត្ថភាពមន្ត្រីនៃលេខាធិការដ្ឋានគណៈកម្មការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុក្នុងការអភិវឌ្ឍព័ត៌មានវិទ្យាសាស្ត្រ ការគ្រប់គ្រង ប្រពន្ធ័ទិន្នន័យមូលដ្ឋាន ការបញ្ចេញនិងបំណាកស្រាយព័ត៌មានជូនសាធារណៈជន | លេខាធិការដ្ឋាន គ.ជ.គ.ប.អ | ន/ដ្ឋានប្រែប្រួល អាកាសធាតុ | ០ | | ៩០ | | ៩០ | | ៦០ | | ៦០ | |

# Cambodia and the GEF

Since joining the GEF, Cambodia received GEF grants totaling USD 38 Million that leveraged USD 99 Million in co-financing resources for 22 **national projects**. These include nine projects in climate change, eight in biodiversity, three in multi-focal areas, one in land degradation, and one in persistent organic pollutants.

Similarly, Cambodia participated in 19 **regional and global projects** financed by the GEF totaling USD 138 Million that leveraged USD 588 Million in co-financing resources. These include eight projects in international waters, four in biodiversity, 3 in multi-focal areas, two in climate change, and two in persistent organic pollutants.

Additionally, the **GEF Small Grants Programme (GEF SGP)** which started in Cambodia in 2004, has received financial support totaling USD 3 Million leveraging USD 7 Million in co-financing resources for 147 projects executed by civil society and community-based organizations.

During the current **GEF-5 replenishment period** (July 2010 – June 2014), Cambodia received an indicative allocation to formulate and execute projects for USD 3.8 Million in biodiversity, USD 2.2 Million in climate change, and USD 1.2 Million in land degradation.

More information about **Cambodia and the GEF** at: www.TheGEF.org/gef/country_profile/KH

**GEF projects in Cambodia include: Rural Electrification and Transmission, Tonle Sap Conservation Project, Strengthening the adaptive capacity and resilience of rural communities using micro watershed approaches to climate change and variability to attain sustainable food security.**

**Total GEF-financing in Cambodia | All amounts in USD**

| | Number of Projects | Total GEF Financing | Total Co-financing* |
|---|---|---|---|
| National Projects | 22 | 37,800,464 | 98,974,955 |
| Regional & Global Projects | 19 | 138,213,840 | 588,426,340 |
| GEF Small Grants Programme | 147 | 3,001,105 | 7,101,884 |
| Total | 188 | 179,015,409 | 694,503,179 |

* Funds from other sources different from the GEF

**Allocation and utilization of resources in Cambodia in GEF-5**| All amounts in USD**

| Focal Area | STAR GEF-5 Indicative allocation | Allocation utilized | Projects awaiting Council approval*** | Allocations yet to be programmed |
|---|---|---|---|---|
| Biodiversity | 3,850,000 | 3,850,000 | 0 | 0 |
| Climate Change | 2,210,000 | 500,000 | 0 | 1,710,000 |
| Land Degradation | 1,220,000 | 500,000 | 0 | 20,000 |
| Total | 7,280,000 | 5,550,000 | 0 | 1,730,000 |

** As of February 20, 2013 | *** Council will be held in June 2013

**Total of LDCF and SCCF financing in Cambodia | All amounts in USD**

| | Number of Projects | Total LDCF/SCCF financing | Total Co-financing |
|---|---|---|---|
| LDCF | 4 | 8,782,500 | 23,740,395 |
| SCCF | 0 | 0 | 0 |
| Total | 4 | 8,782,500 | 23,740,395 |

## GEF Partners in Cambodia

**GEF Agencies:** World Bank, United Nations Development Programme (UNDP), United Nations Environment Programme (UNEP), United Nations Industrial Development Organization (UNIDO), United Nations Food and Agriculture Organization (FAO), Asian Development Bank (ADB).

**National Executing Partners:** Royal Government of Cambodia, Ministry of Environment, Ministry of Industry, Mines and Energy (MIME), Ministry of Agriculture, Forestry and Fisheries (MAFF), Ministry of Water Resources Management (MoWRAM), Ministry of Agriculture and Rural Development (MARD), National Botanical Institute (NBI), Fauna and Flora International (FFI), Department of Pollution Control.

## Contact Points for the GEF in Cambodia

**Mr. Rithirak LONG**
**Political Focal Point**
Deputy Director General
Ministry of Environment
48 Samdech Preah Sihanouk, Tonle Bassac
Chamkarmon
Phnom Penh
Cambodia
Tel: +855 23 214 027
Fax: +855 23 219 287
Email: moeimo@online.com.kh, longrithirak@yahoo.com

**Mr. Lonh HEAL**
**Operational Focal Point**
Technical Director General
Ministry of Environment
48 Samdech Preah Sihanouk, Tonle Bassac
Chamkarmon
Phnom Penh
Cambodia
Tel: +855 12 923 526, 12 927 001
Fax: +855 23 987 880
Email: heal_lonhmoe@yahoo.com

## About the GEF

**The Global Environment Facility (GEF)** was established in 1991 as the financial mechanism of the main multilateral environmental agreements. Currently, the GEF is the largest public funder worldwide of projects aiming to generate global environmental benefits, while supporting national sustainable development initiatives.

The GEF has allocated **USD 11.5 billion**, supplemented by more than **USD 57 billion** in co-financing for over **3,215 projects**. Additionally, through its Small Grants Programme (SGP), the GEF has also made available more than **16,030 small grants** directly to civil society organizations totaling **USD 653.2 million**. The GEF unites 182 member governments – in partnership with international institutions, civil society organizations, and the private sector – and its resources go directly to developing countries for projects related to biodiversity, climate change, international waters, land degradation, persistent organic pollutants, and the ozone layer (the last concerning only countries with economies in transition).

**Civil society organizations (CSOs)** play an important role in the GEF, participating in project identification and execution, and influencing policy formulation. A formal dialogue and partnership between the diversity of CSOs worldwide and the GEF is conducted through the GEF NGO Network (www.gefngo.org)

**GEF Website:** TheGEF.org
**Social Media:**

- facebook.com/thegef1
- twitter.com/thegef
- youtube.com/gefsecretariat

**Production Date:** February 2013

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:១៣៧..សសរ**

ក្រសួងបរិស្ថាន
ចូល
លេខ:
ថ្ងៃទី ១៩ ខែ ០៩ ឆ្នាំ២០១៥
ម៉ោង ១០,០០

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៥ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- បានឃើញអនុក្រឹត្យលេខ៥៧អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៩៩អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

- បានឃើញអនុក្រឹត្យលេខ២៥១ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៩៩អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

# សម្រេច

**ប្រការ១ .-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ដែលមានសមាសភាពដូចខាងក្រោម៖

១- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រធានកិត្តិយស
២- ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ប្រធាន
៣- ឯកឧត្តម **ឌី សុគន្ធ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុប្រធាន
៤- ឯកឧត្តម **ឌិត ទីណា** រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល អនុប្រធាន
៥- ឯកឧត្តម **គន់ វ៉ាន់ថារ៉ា** រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម អនុប្រធាន
៦- ឯកឧត្តម **អ៊ុក ប្រជា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក
៧- ឯកឧត្តម **ឡេង សេង** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
៨- ឯកឧត្តម **គឹម សុវណ្ណា** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
៩- ឯកឧត្តម **រស់ សីលវ៉ា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
១០- ឯកឧត្តម **ញ៉ែម សារ៉ែន** អនុរដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក
១១- ឯកឧត្តម **ទឹង ស៊ីនី** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម សមាជិក
១២- ឯកឧត្តម **នុត ច័ន្ទសុខា** អនុរដ្ឋលេខាធិការក្រសួងផែនការ សមាជិក
១៣- ឯកឧត្តម **ឃួន ផុនរតនៈ** អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក
១៤- លោកជំទាវ **ទន់ សាអ៊ឹម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិកា
១៥- ឯកឧត្តម **លី ឈួន** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក
១៦- ឯកឧត្តម **ចិន សម្បត្តិថារ័ត្ន** អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
១៧- ឯកឧត្តម **លី ស៊ីមអ៊ាម** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
១៨- ឯកឧត្តម **អ៊ុង ផល្លី** អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន សមាជិក
១៩- លោកជំទាវ **ញ៉ែម មរកត** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី សមាជិកា
២០- ឯកឧត្តម **ម៉ា នរិទ្ធ** អគ្គលេខាធិការរងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សមាជិក
២១- ឯកឧត្តម **ហេង សុខណាង** អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
២២- ឯកឧត្តម **គល់ វឌ្ឍនា** អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សមាជិក។

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ពាក្យបំព្រួញ និងអក្សរកាត់

| | | |
|---|---|---|
| CC | Climate Change | ការប្រែប្រួលអាកាសធាតុ |
| CCAP | Climate Change Action Plan | ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ |
| CCCA | Cambodia Climate Change Alliance | សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា |
| CCSP | Climate Change Strategic Plan | ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ |
| CDM | Clean Development Mechanism | យន្តការអភិវឌ្ឍន៍ស្អាត |
| CH4 | | ឧស្ម័នមេតាន |
| CO2 | | ឧស្ម័នកាបូនិច |
| DCC | Climate Change Department | នាយកដ្ឋានប្រែប្រួលអាកាសធាតុ |
| EIA | Environmental Impact Assessment | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| EU | European Union | សហភាពអឺរ៉ុប |
| GEF | Global Environmental Facility | មូលនិធិបរិស្ថានពិភពលោក |
| INC | Intergovernmental Negotiating Committee for a Framework Convention on Climate Change | គណៈកម្មាធិការចរចារជាលក្ខណៈអន្តររដ្ឋាភិបាលសំរាប់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីបញ្ហាបម្រែបម្រួលអាកាសធាតុ |
| HCL | | អាស៊ីតក្លរីទ្រិច |
| H2O | | ចំហាយទឹក |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ |
| MIH | Ministry of Industry and Handicraft | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| MME | Ministry of Mines and Energy | ក្រសួងរ៉ែ និងថាមពល |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MOWRAM | Ministry of Water Resources and Meteorology | ក្រសួងធនធានទឹក និងឧតុនិយម |
| NCSD | National Council for Sustainable Development | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| N2O | | ឧស្ម័ននីត្រូអុកស៊ីត |
| REDD+ | Reducing Emissions from Deforestation and Forest Degradation | ការកាត់បន្ថយការបំភាយកាបូនពីការកាប់បំផ្លាញព្រៃឈើ |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |

| | | |
|---|---|---|
| Sida | Swedish International Development Cooperation | ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ |
| SO2 | | ឧស្ម័នស៊ុលផួរឌីអុកស៊ីត |
| UNCED | United Nations Conference on Environment and Development | សន្និសីទស្តីពីបរិស្ថាន និងការអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ |
| UNCHE | United Nations Conference on Human Environment | សន្និសីទស្តីពីបរិស្ថានមនុស្សរបស់អង្គការសហប្រជាជាតិ |
| UNDP | United Nations Development Program | កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ |
| UNFCCC | United Nations Framework Convention on Climate Change | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| UNEP | United Nations Environment Program | កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ |
| WMO | World Meteorological Organization | អង្គការឧតុនិយមពិភពលោក |
| WSSD | World Summit on Sustainable Development | កិច្ចប្រជុំកំពូលពិភពលោកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព |